# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## អង្គបុរេជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌ

លេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៦) អៀង ធីរិទ្ធ

**ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩**

**ម៉ោង ០៩: ០៣ នាទី**

**សវនាការជាសាធារណៈ**

**ចៅក្រមជំនុំជម្រះ៖**

លោក ប្រាក់ គឹមសាន ប្រធានអង្គបុរេ

លោក រ៉ូវ៉ាន់ ដោននីង

លោកស្រី ខាទីនខា ឡាហ៊ូស

លោក ន័យ ថុល

លោក ហួត វុទ្ធី

**ក្រឡាបញ្ជី៖**

លោក ជួន សុរាសី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូបឺត ពើទីត

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត

លោក តាន់ សេណារ៉ុង

កញ្ញា អានី អាម៉េដ

**មេធាវីការពារជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី ដាយអាណា អេលីស

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក ឡៅ ជុនធី

លោក គង់ ពិសី

លោក នី ចាន់ឌី

លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី

លោក យ៉ុង ផានិត

លោក គីម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោក ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

លោក ហ្វីលីព កាណុន

លោក ព្យែរ អូលីវីយ៉េ ស័រ

# កិច្ចដំណើរការនីតិវិធី

[០៩:០០:០៣]

**លោក ជួន សុភាសី៖**

បទបញ្ជាផ្ទៃក្នុងសវនាការ ដើម្បីរក្សាបាននូវរបៀបរាបរយសាធារណៈ សន្តិសុខ និងដំណើរការល្អក្នុងពេលសាលសវនាការនៅថ្ងៃទីម្ភៃបួន ខែកុម្ភៈ ឆ្នាំពីរពាន់ប្រាំបួន ។ ប្រធានអង្គបុរេជំនុំជម្រះបានដាក់នូវបទបញ្ជាដូចខាងក្រោម៖

១) អ្នកដែលមានបំណងចូលរួមស្តាប់ការសវនាការទាំងអស់ ត្រូវមានវត្តមានក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានមុនម៉ោងប្រាំបួនព្រឹក ។

២) មិនអនុញ្ញាតឲ្យយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីឌីអូ ឧបករណ៍ថតសំឡេង និង ឧបករណ៍បំពងសំឡេងគ្រប់ប្រភេទពីខាងក្រៅចូលក្នុងសាលសវនាការឡើយ លើកលែងតែមានការអនុញ្ញាតដោយអង្គបុរេជំនុំជម្រះ ។

៣) មិនអនុញ្ញាតឲ្យជក់បារី ឬយកចំណីអាហារ ឬភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការឡើយ ។

៤) មិនអនុញ្ញាតឲ្យយកអាវុធគ្រប់ប្រភេទចូលក្នុងសាលសវនាការ ។

៥) មិនអនុញ្ញាតឲ្យប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទ និងហាមឃាត់នូវរាល់ការថតរូបភាព ឬថតសំឡេងដោយទូរស័ព្ទក្នុងពេលសាលសវនាការ ។

៦) មិនអនុញ្ញាតឲ្យប្តូរកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ ។

៧) មិនអនុញ្ញាតឲ្យស្រែកឡូឡា ឬបង្កើតសំឡេងរំខានក្នុងសាលសវនាការ ។

៨) ការចេញចូលក្នុងសាលសវនាការត្រូវទាក់ទងសន្តិសុខ អ.វ.ត.ក ។

៩) មិនអនុញ្ញាតឲ្យអ្នកដែលមានអាយុក្រោម១៨ឆ្នាំ ចូលក្នុងសាលសវនាការឡើយ ។

ប្រធានអង្គបុរេជំនុំជម្រះអាចចាត់វិធានការភ្លាម ប្រឆាំងនិងអ្នកដែលបានប្រព្រឹត្តនឹងបទបញ្ជានេះ ឬអ្នកដែលបានប្រព្រឹត្តល្មើសផ្សេងៗទៀតក្នុងពេលសាលសវនាការ តាមទង្វើ ឬបទល្មើសដែលបានប្រព្រឹត្តជាក់ស្តែង ។

ភ្នំពេញថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៩

ប្រធានអង្គបុរេជំនុំជម្រះ

ហត្ថលេខា និងត្រា

ប្រាក់ គឹមសាន

**លោក ជួន សុភាសី៖**

សហព្រះរាជអាជ្ញាចូលកាន់ទីកន្លែង ។

សូមអញ្ជើញអ្នកសារព័ត៌មានចំនួនបួនរូប ចូលថតរូបក្នុងសាលសវនាការ ។

**លោក ជួន សុភាសី៖**

តុលាការ! សូមអញ្ជើញក្រោកឈរ!

[០៩:០២:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

សូមអ្នកសារព័ត៌មាន អញ្ជើញចេញ ។

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសបើកសវនាការ ដើម្បីជំនុំជម្រះរឿងព្រហ្មទណ្ឌលេខ ០០២/១៩-៩-២០០៧ អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ១៦ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលមានជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ ហៅ ភា, សញ្ជាតិ ខ្មែរ, ភេទស្រី, កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ៤៧បេ ផ្លូវលេខ២១, ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ ឪពុកឈ្មោះ ខៀវ អ៊ុន ស្លាប់, ម្តាយឈ្មោះ អ៊ុក ប៊ុន ស្លាប់ ។ ប្តីឈ្មោះ អៀង សារី មានកូនចំនួន៤នាក់ ។

ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។ មេធាវីការពារក្តីលោក ផាត់ ពៅស៊ាង និងកញ្ញា ដាយអាណា អេលីស អវត្ត-មាន ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក ហុង គឹមសួន, លោក ឡោ ជុនធី, លោក នី ចាន់ឌី, លោក គង់ ពិសី, លោក យុង ផានិត, លោក គីម ម៉េងឃី, កញ្ញា ម៉ុច សុវណ្ណារី, លោកស្រី ស៊ីលឃី

ស្ទូតហ្សីនស្គី, លោកស្រី ម៉ាទីន ហ្សាកឃីន, លោក ហ្វីលីព កាណុន, លោក ព្យែរ អូលីវីយ៉ែ ស័រ, លោកស្រី អេលីហ្សាប៊ែត វ៉ាប៊ឺសាន់ដ្រាណា, លោក អូលីយេ បាហ្សីញ និងលោក ដាវីដ ប្លេកមែន ។

ក្រឡាបញ្ជីអ្នកចូលរួមសវនាការមានវត្តមានគ្រប់ចំនួនហើយឬនៅ?

**លោក ដួន សុភាសី៖**

សូមគោរពតុលាការអ្នកចូលរួមក្នុងសវនាការមានវត្តមានហើយ តែសហមេធាវីការពារក្តីកញ្ញា ដាយអាណា អេលីស អវត្តមាន ។

**ប្រធានអង្គជំនុំ៖**

ការជំនុំជម្រះថ្ងៃនេះមានសមាសភាពដូចតទៅ៖

| | |
|---|---|
| លោក ប្រាក់ គីមសាន | ប្រធាន |
| លោក រ៉ូវ៉ាន់ ដោននីង | ចៅក្រម |
| លោក ន័យ ថុល | ចៅក្រម |
| លោកស្រី ខាទីនខា ឡាហ្វ៊ីស | ចៅក្រម |
| លោក ហ្សូត វុទ្ធី | ចៅក្រម |
| លោក លោក ប៉ែន ពេជ្រសាលី | ចៅក្រមបម្រុង |

ក្រឡាបញ្ជី៖

លោក ដួន សុភាសី

លោកស្រី អាននី ម៉ារីប៊ឺន

តំណាងអយ្យការ

| | |
|---|---|
| លោក សេង ប៊ុនឃាង | សហព្រះរាជអាជ្ញារង |
| លោក វាំងសង់ វ៉ាលដ៍អេសម៉ាអែល | សហព្រះរាជអាជ្ញារង |

**ប្រធានអង្គជំនុំ៖**

លោកស្រី អៀង ធីរិទ្ធ សូមអញ្ជើញក្រោកឈរ!

លោកស្រីឈ្មោះអ្វី?

**ជនត្រូវចោទ៖**

ខៀវ ធីរិទ្ធ ។

**ប្រធានអង្គជំនុំ៖**

មានឈ្មោះហៅក្រៅឬទេ?

**ជនត្រូវចោទ៖**

ហៅក្រៅឈ្មោះ ភា ។

**ប្រធានអង្គជំនុំ៖**

អាយុប៉ុន្មាន?

**ជនត្រូវចោទ៖**

៧៧ឆ្នាំ ។

**ប្រធានអង្គជំនុំ៖**

សញ្ជាតិអ្វី?

**ជនត្រូវចោទ៖**

ខ្មែរ ។

**ប្រធានអង្គជំនុំ៖**

កើតនៅភូមិណា?

**ជនត្រូវចោទ៖**

សង្កាត់លេខ៥ ក្រុងភ្នំពេញ ។

**ប្រធានអង្គជំនុំ៖**

មុខរបរធ្វើអ្វី?

**ជនត្រូវចោទ៖**

សាស្ត្រាចារ្យភាសាអង់គ្លេស ។

**ប្រធានអង្គជំនុំ៖**

ទីលំនៅមុនពេលចាប់ខ្លួននៅឯណា?

**ជនត្រូវចោទ៖**

ទីលំនៅ គឺនៅផ្ទះលេខ៤៧បេ ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

**ប្រធានអង្គជំនុំ៖**

ឪពុកឈ្មោះអ្វី?

**ជនត្រូវចោទ៖**

ខៀវ អ៊ុន ។

**ប្រធានអង្គជំនុំ៖**

ម្តាយឈ្មោះអ្វី?

**ជនត្រូវចោទ៖**

អ៊ុក ប៊ុន ។

**ប្រធានអង្គជំនុំ៖**

ប្តីលោកស្រីឈ្មោះអ្វី?

**ជនត្រូវចោទ៖**

អៀង សារី ។

**ប្រធានអង្គជំនុំ៖**

មានកូនប៉ុន្មាននាក់?

**ជនត្រូវចោទ៖**

៤នាក់ ។

**ប្រធានអង្គជំនុំ៖**

តើលោកស្រីមានពឹងអ្នកការពារ ឬមេធាវីដែរឬទេ?

**ជនត្រូវចោទ៖**

មាន, គឺមានលោកមេធាវី ផាត់ ពៅស៊ាង ដែលមាន-- ។ ហើយកញ្ញា ដាយអាណា អេលីស គាត់មិនបានមក ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបលោកស្រីថា តាមវិធាន២១.១(ឃ) លោកស្រីត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់លោកស្រីមិនទាន់ត្រូវបានរកឃើញ ។ លោកស្រីមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះលោកស្រី ។ លោកមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់លោកស្រី និងលោកស្រីមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ សូមអញ្ជើញអង្គុយចុះ ។

សូមអញ្ជើញលោកចៅក្រម ហួត វុទ្ធី អានរបាយការណ៍ ។

[០៩:១០:១៨]

**ចៅក្រម ហួត វុទ្ធី៖**

របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង៖

១) នីតិវិធី

២) ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

I) ក)សេចក្តីផ្តើម

អនុលោតាមវិធាន៧៧.១០ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រធានអង្គបុរេជំនុំជម្រះចាត់តាំងលោកចៅក្រម ហួត វុទ្ធី និងចៅក្រម រ៉ូវ៉ាន់ ដោននីង ធ្វើរបាយការណ៍បង្ហាញលម្អិតអំពីអង្គហេតុនិងអង្គច្បាប់ នៅក្នុងដីកាសម្រេចអំពីបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចេញដោយសហចៅក្រមស៊ើបអង្កេត ដែលដីកាបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះត្រូវបានប្តឹងឧទ្ធរណ៍ ។ ប្រធានអង្គបុរេជំនុំជម្រះក៏បានឲ្យចៅក្រមទាំងពីររូបពិនិត្យសំណុំរឿងលេខ០២ ចុះថ្ងៃទី១៩ ខែ០៩ ឆ្នាំ២០០៧ អ.វ.ត.ក-ក.ស.ច.អ ផងដែរ ។

អត្តសញ្ញាណសម្គាល់ជនត្រូវចោទ អៀង ធីរិទ្ធ ហៅ ភា ភេទស្រី កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ សញ្ជាតិខ្មែរ រស់នៅមុនពេលចាប់ខ្លួន នៅផ្ទះលេខ៤៧បេ ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ខៀវ អ៊ុន ស្លាប់ ម្តាយឈ្មោះ អ៊ុក ប៊ុន ស្លាប់ ។ អៀង ធីរិទ្ធ មានសហមេធាវីរបស់គាត់ គឺលោក ផាត់ ពៅស៊ាង និងកញ្ញា ដាយអាណា អេលីស ។

បទចោទប្រកាន់ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាត ការសម្លាប់បំផុតពូជ ការឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបទល្មើសចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

គោលបំណងនៃរបាយការណ៍ របាយការណ៍សហចៅក្រមរបាយការណ៍នេះ បង្ហាញលម្អិតអំពីអង្គហេតុ និងអង្គច្បាប់ ក្នុងសេចក្តីសម្រេចដែលប្តឹងឧទ្ធរណ៍ និងអង្គហេតុពាក់ព័ន្ធផ្សេងទៀតចំពោះមុខតុលាការ ។

របាយការណ៍នេះផ្តល់ជំនួយដល់អ្នកដែលមិនមែនភាគីនៃនីតិវិធីឲ្យយល់អំពីរឿងក្តីនៅចំពោះមុខតុលាការ ។

ខ) ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឲ្យបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើ អៀង ធីរិទ្ធ ដែលត្រូវឃុំខ្លួនចាប់តាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងរយៈពេលអតិបរមា១ឆ្នាំ ។ ដោយអនុលោមតាមបទប្បញ្ញាតិនៃវិធាន៦៣.៦(ក) នៃវិធានផ្ទៃក្នុង ។ សហចៅក្រមស៊ើបអង្កេតរកឃើញថា លក្ខខណ្ឌទីមួយ ដើម្បីចេញដីកាឲ្យឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងវិធានផ្ទៃក្នុង៦៣.៣(ក) ត្រូវបានបំពេញ ។ ដោយសារតែមានហេតុផលនាំជឿជាក់ថា ជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានចោទប្រកាន់ក្នុងដីកាសម្រេចនេះ ។ សហចៅក្រមស៊ើបអង្កេតបានផ្អែកទាំងស្រុងលើ ការវិភាគសំណុំរឿង រៀបចំឡើងដោយអង្គបុរេជំនុំជម្រះក្នុងពេលអង្គបុរេជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នដំបូង ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះបែបនេះ មិនមានភស្តុតាងណាមួយផ្សេងមកដោះបន្ទុកនៅឡើយទេ។ សហចៅក្រមស៊ើបអង្កេតរកឃើញថា គ្មានការផ្លាស់ប្តូរស្ថានភាព ចាប់តាំងពីអង្គបុរេជំនុំជម្រះបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីធានាវត្តមានជនត្រូវចោទក្នុងអំឡុងពេលដំណើរការនីតិវិធី និងការពារសន្តិសុខដល់ជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មូលហេតុទាំងបីដែលចែងក្នុងវិធានផ្ទៃក្នុង៦៣.៣(ខ) ត្រូវបាននៅតែបំពេញនៅឡើយ ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនអស់រយៈពេល១២ខែមិនមានលក្ខណៈហួសហេតុទេ បើគិតពីទំហំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញនៃអង្គហេតុនិងអង្គច្បាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត ។

សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមទៀតថា ការអនុវត្តសិទ្ធិនៅស្ងៀមរបស់ជនត្រូវចោទមិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ ។ ទោះបីជាសិទ្ធិនេះត្រូវបានទទួលស្គាល់និងមិនអាចជំទាស់បានក៏ដោយ ។

គ) បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ នៅថ្ងៃទី៩ ធ្នូ ឆ្នាំ២០០៨ សហមេធាវីការពារជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ ក្នុងបណ្តឹងនោះ សហមេធាវីការពារក្តីបានស្នើឲ្យអង្គបុរេជំនុំជម្រះ៖

១) សម្រេចថាលក្ខខណ្ឌតឹងរ៉ឹងសម្រាប់បន្តថិរវេលាឃុំខ្លួនជនត្រូវចោទ លែងជាលក្ខខណ្ឌត្រូវបំពេញទៀតហើយ ។

២) ចាត់ទុកមោឃៈចំពោះដីកាសម្រេចអំពីការបន្តថិរវេលាមួយឆ្នាំនៃការខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ។

៣) សម្រេចដោះលែងជនត្រូវចោទជាបន្ទាន់ តាមលក្ខខណ្ឌដែលអង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប ។

សហមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានថា ដីការបស់សហចៅក្រមស៊ើបអង្កេតមិនមានហេតុផលគ្រប់គ្រាន់ និងសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការអង្កេតរបស់ខ្លួនដោយយកចិត្តទុកដាក់ ។

ឃ) ចម្លើយតបរបស់សហព្រះរាជអាជ្ញា

សហព្រះរាជាអាជ្ញាបានសន្និដ្ឋានក្នុងចម្លើយតបថា បណ្តឹងឧទ្ធរណ៍គួរបដិសេធចោលទាំងស្រុង ដោយសារតែជនត្រូវចោទមិនបានបង្ហាញ អំពីការផ្លាស់ប្តូរស្ថានភាពណាមួយ ចាប់តាំងពី អៀង ធីរិទ្ធ ត្រូវបានចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនគាត់ ។

II- ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

ក) សេចក្តីសម្រេចដែលមានមូលហេតុមិនគ្រប់គ្រាន់

សហមេធាវីការពារក្តីបានលើកអំណះអំណាងដូចខាងក្រោម ដោយហេតុថាសហចៅក្រមស៊ើបអង្កេត ៖

១) មិនបានផ្តល់មូលហេតុគ្រប់គ្រាន់ចំពោះអំណះអំណាងរបស់ខ្លួន ។

២) បានផ្តល់ព័ត៌មានមិនពិតទាក់ទិននឹងភស្តុតាងដែលត្រូវលើកឡើងប្រឆាំងនឹងជនត្រូវចោទ ។

៣) បានផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានមិនពិត ស្តីពីសិទ្ធិពិនិត្យសំណុំរឿងរបស់ជនត្រូវចោទ ។

ដីកាសម្រេចអំពីការបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នខ្វះខាតនូវអំណះអំណាង ដែលរំលោភលើវិធាន៦៣.៧ នៃវិធានផ្ទៃក្នុង និងគោលការណ៍ច្បាប់ទូទៅដែលបានបញ្ជាក់ខាងលើ ។ កង្វះខាតបែបនេះគួរនាំឲ្យមានមោឃៈនូវដីកាសម្រេចអំពីការបន្តថិរវេលាឃុំខ្លួននេះ ។

សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដីកាសម្រេចបន្តថិរវេលាឃុំខ្លួន ធ្វើឡើងដោយសហចៅក្រម

ស៊ើបអង្កេតគឺមានលក្ខណៈគ្រប់គ្រាន់ សមល្មម ។ សហចៅក្រមស៊ើបអង្កេតដាក់ចេញ ដោយយកមកពិចារណាមូលហេតុ ផ្នែកច្បាប់ និងអង្គហេតុមុននឹងចេញដីកាបន្តថិរវេលានៃការឃុំខ្លួន ហើយក៏មិនបានជាប់កាតព្វកិច្ចត្រូវបញ្ជាក់អំពីកត្តានានាទាំងអស់នោះដែរ ។

ផ្ទុយពីអ្វីដែលមេធាវីការពារក្តីលើកឡើង ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន មិនមានព័ត៌មានខុសណាមួយទេ ហើយការពិតម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានទទួលសិទ្ធិពិនិត្យធាតុផ្សំទាំងអស់នៃសំណុំរឿងតាមរយៈមេធាវីការពារក្តីរបស់ខ្លួន ។

ខ) ការយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តកាតព្វកិច្ចស៊ើបអង្កេតដោយយកចិត្តទុកដាក់ជាពិសេសនោះទេ ។ ដោយសារតែសហចៅក្រមស៊ើបអង្កេតខកខានមិនបានប្រមូលភស្តុតាងដាក់បន្ទុកលើជនត្រូវចោទ ដើម្បីគាំទ្របទចោទដែលចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងអំឡុងពេលជនត្រូវចោទបានឃុំខ្លួន ។

សហមេធាវីការពារក្តីបានតវ៉ាថា សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តកិច្ចស៊ើបអង្កេត ដោយយកចិត្តទុកដាក់ ដោយត្រូវបង្ហាញឲ្យឃើញតាមរយៈការប្រមូលភស្តុតាង អំឡុងពេលជនត្រូវចោទកំពុងជាប់ឃុំ មិនមែនតាមរយៈវិសាលភាពនៃកិច្ចស៊ើបអង្កេតរបស់កិច្ចស៊ើបអង្កេតនោះទេ ។

[០៩:២០:១៤]

សហមេធាវីការពារក្តីបានលើកឡើងថា កិច្ចស៊ើបអង្កេតគ្របដណ្តប់លើអង្គហេតុស្មុគស្មាញមួយចំនួន ប៉ុន្តែប្រសិនបើសហចៅក្រមស៊ើបអង្កេតក្នុងរយៈពេលមួយឆ្នាំនេះ ។ មិនអាចមានលទ្ធភាពបង្ហាញភស្តុតាងដាក់បន្ទុកណាមួយលើជនត្រូវចោទ ក្រៅពីអំណះអំណាងជនត្រូវចោទជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនោះ ដូច្នេះបានសេចក្តីថា ភាពស្មុគស្មាញនិងវិសាលភាពនៃកិច្ចស៊ើបសួរ គឺមិនមែនជាបញ្ហាជាប់ពាក់ព័ន្ធអ្វីទៅនឹងបញ្ហានេះទេ ឬមិនមាននិយាមគ្រប់គ្រាន់ទេ ។

សហមេធាវីការពារក្តីបានតវ៉ាបន្ថែមទៀតថា ការដាក់ចេញនូវដីកាសម្រេចអំពីនៃការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដោយទម្លាក់កំហុសចំពោះការយឺតយ៉ាវទៅលើមេធាវីការពារក្តីនោះ គឺជាការរំលោភបំពានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។

សហព្រះរាជអាជ្ញាសន្និដ្ឋានតបថា មេធាវីការពារក្តីមិនបានបង្ហាញឲ្យឃើញរយៈពេលនៃការឃុំខ្លួននោះ បានធ្វើឲ្យកូនក្តី អង្គជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ឬដើម្បីបង្ហាញថាតើអាចផ្តល់ការ

ឃុំខ្លួន ។

សហព្រះរាជអាជ្ញាបានបន្តទៀតថា ថិរវេលានៃការឃុំខ្លួនមុនពេលជំនុំជម្រះគឺមានលក្ខណៈសមស្រប ដោយសារតែបទចោទអំពីបទឧក្រិដ្ឋធ្ងន់ធ្ងរ លក្ខណៈស្មុគស្មាញនៃរឿងក្តី កម្រិតស៊ើបសួរកំពុងតែអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ។

[០៩:២២:០៣]

សហព្រះរាជាអាជ្ញាសន្និដ្ឋានថា ការធ្វើឲ្យខូចនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទដូចជាការលើកឡើង ហាក់ដូចជា ផ្អែកទៅលើការអានដីកាស្រេចបន្តថិរវេលានៃការឃុំខ្លួនមិនបានត្រឹមត្រូវ ។

សិទ្ធិនៅស្ងៀមមិនឆ្លើយតបត្រូវបានទទួលស្គាល់ និងមិនមានជំទាស់ពីសហចៅក្រមស៊ើបអង្កេតទេ ។ ទោះបីយ៉ាងណាក៏ដោយ អវត្តមាននៃកិច្ចសហការរបស់ជនត្រូវចោទមិនបានជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងដោះបន្ទុកឡើយ ។

គ) មានមូលហេតុត្រូវរកឃើញនិងជឿជាក់ថា ជននេះធ្លាប់ប្រព្រឹត្តបទល្មើសមួយ ឬច្រើនដូចមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។

សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បញ្ហាចម្បងក្នុងការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តការឃុំខ្លួននោះ តើលក្ខខណ្ឌនានាដូចកំណត់ក្នុងវិធាន៦៣.៣ ត្រូវបានបំពេញ ឬយ៉ាងណានោះទេ ។

សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ក្នុងករណីដែលអង្គបុរេជំនុំជម្រះអាចធ្វើការវិភាគផ្ទាល់ខ្លួន និងដោះស្រាយវិការៈនៅក្នុងដីកាសម្រេចនោះ តាមរយៈការដាក់ជួសនូវសំអាងហេតុរបស់ខ្លួនផ្ទាល់ក៏ទឡ្ហីករណ៍ភាគច្រើនដែលលើកឡើងដោយជនត្រូវចោទក្នុងពាក្យបណ្តឹងឧទ្ធរណ៍របស់គាត់មិនពាក់ព័ន្ធជាសារវន្តនោះទេ ។

សហព្រះរាជអាជ្ញាបានបង្ហាញថា មេធាវីការពារក្តីមិនបានធ្វើការតវ៉ាប្រឆាំងនឹងអាទិភាពនៃមូលហេតុរកឃើញនាំឲ្យជឿជាក់ថា ជនត្រូវចោទអាចប្រព្រឹត្តបទឧក្រិដ្ឋដូចបានកំណត់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។ តាមយោបល់របស់សហព្រះរាជអាជ្ញារកឃើញ អង្គបុរេជំនុំជម្រះដែលថាលក្ខខណ្ឌដែលចែងក្នុងវិធាន៦៣.៣(ក) ត្រូវបានបំពេញ ។ ត្រូវបានបញ្ជាក់និងអះអាងបន្ថែម និងការប្រមូលភស្តុតាងថ្មីចាប់តាំងពីការចេញដីកាសម្រេចនោះមក ។

ឃ) ការពិចារណាអំពីមូលហេតុ ដែលធ្វើការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការចាំបាច់

សហមេធាវីការពារក្តីបានលើកឡើងអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតបានខកខានក្នុងការញែកហេតុផល ផ្តល់ភស្តុតាងណាក្នុងដីកាសម្រេចបន្តការឃុំខ្លួនរបស់ខ្លួន ដែលបញ្ជាក់ថា មានហានិភ័យពិតប្រាកដមែន ដែលថាសាក្សីទាំងអស់អាចប្រកែកមិនព្រមចូលក្នុងកិច្ចដំណើរការនីតិវិធី ប្រសិនបើជនត្រូវចោទបានត្រូវដោះលែងនោះ ។

សហមេធាវីការពារក្តីបានលើកឡើងថា បទដ្ឋានដំបូងនៃការបង្ហាញភស្តុតាងលែងមានសុពលភាពគ្រប់គ្រាន់ក្រោយពីឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលមួយឆ្នាំហើយនោះ ។

សហព្រះរាជអាជ្ញាបានឆ្លើយតបថា ជនត្រូវចោទមិនបានបង្ហាញអំពីការផ្លាស់ប្តូរស្ថានភាព ដើម្បីបង្ហាញថា លក្ខខណ្ឌចាំបាច់នៃការឃុំខ្លួនគាត់ដែលចែងក្នុងវិធាន៦៣.៣(ខ) និងមិនបានបំពេញទៀតឡើយ និងមិនបានតវ៉ាជំទាស់ថា លក្ខខណ្ឌទាំងបួនក្នុងចំណោមលក្ខខណ្ឌទាំងប្រាំមិនត្រូវបានបំពេញនោះទេ ។

សហព្រះរាជអាជ្ញាសន្និដ្ឋានថា អាកប្បកិរិយារំលោភបំពានរបស់ជនត្រូវចោទក្នុងពេលសវនាការរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ និង ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ គឺមានលក្ខណៈគំរាមកំហែងនិងប៉ុនប៉ងបំភិតបំភ័យភាគីនានា និង/ឬ ចំពោះចៅក្រមដែលគួរត្រូវយកចិត្តទុកដាក់ ។ ក្នុងពេលធ្វើការវាយតម្លៃអំពីហានិភ័យផ្សេងៗដែលអាចកើតឡើងដល់សាក្សីនិងជនរងគ្រោះនានា និងសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទដែលមានចែងក្នុងវិធាន៦៣(ខ)(៤) និងវិធាន៦៣(ខ)(៥) ។
[០៩:២៦:២៧]

សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា សេចក្តីថ្លែងការណ៍ថ្មីនេះ និងអាកប្បកិរិយារបស់ជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានបង្ហាញឲ្យឃើញថា ការដោះលែងណាមួយក្នុងចំណោមជនត្រូវចោទទាំងប្រាំរូបអាច ធ្វើឲ្យប្រែក្លាយទៅជាអំពើហិង្សាសំដៅប្រឆាំងចំពោះអតីតមេដឹកខ្មែរក្រហមទាំងនោះ រួមមានជនត្រូវចោទ ក្រុមមេធាវីការពារក្តី ។

ភ្នំពេញថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩

សហចៅក្រមរបាយការណ៍

ចៅក្រម ហ្គួត វុទ្ធី, ចៅក្រមរ៉ូវ៉ាន់ ដោននីង

[០៩:២៧:១១]

**ប្រធានអង្គជំនុំ៖**

ជនត្រូវចោទលោកស្រី អៀង ធីរិទ្ធ សូមអញ្ជើញក្រោកឈរ!

តើលោកស្រីចង់និយាយទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រីដោយខ្លួនឯងផ្ទាល់ ឬមួយលោកស្រីចង់ឲ្យមេធាវីរបស់លោកស្រីនិយាយក្នុងនាមលោកស្រី ។

**ជនត្រូវចោទ៖**

-- ភាពទន់ខ្សោយខ្លាំងណាស់ ។ ខ្ញុំសូមជូនឲ្យលោកមេធាវី លោកនិយាយជំនួសខ្ញុំចុះ ។

**ប្រធានអង្គជំនុំ៖**

បាទ, អញ្ជើញអង្គុយចុះ ។

សូមអញ្ជើញលោកមេធាវីការពារឲ្យជនត្រូវចោទឡើងធ្វើសេចក្តីសន្និដ្ឋាន ។ លោកមានរយៈពេលមួយម៉ោងសម្រាប់សហមេធាវី ។ សូមអញ្ជើញ ។

[០៩:២៨:០៩]

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គបុរេជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល ។ ខ្ញុំបាទឈ្មោះ ផាត់ ពៅស៊ាង ជាសហមេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ ខ្ញុំបាទមុននឹងធ្វើសេចក្តីសន្និដ្ឋានការពារ ។ ខ្ញុំបាទសូមការអនុញ្ញាតឲ្យកូនក្តីខ្ញុំបាទគាត់អញ្ជើញទៅក្រោយ ។ គាត់អង្គុយនៅក្រោយពីព្រោះអី គាត់ទៅក្រោយទៅ គាត់ស្រួលសម្រួលឥរិយាបថ ដោយសារគាត់មានហៅថា អាការៈមិនស្រួល ។

**ប្រធានអង្គជំនុំ៖**

តុលាការអនុញ្ញាតឲ្យ ។

**លោក ផាត់ ពៅស៊ាង៖**

ជាបន្តទៅទៀត គឺខ្ញុំបាទសុំធ្វើសេចក្តីសន្និដ្ឋានការពារ ដោយមានទាំងអស់គឺថា១៣ចំណុច ។ គឺថាក្នុងចំណុចនីមួយៗ ខ្ញុំបាទនឹងធ្វើការរៀបរាប់លម្អិតជាបន្តបន្ទាប់ ។

គឺជាបឋមខ្ញុំបាទសូមអនុញ្ញាតជម្រាបនូវចំណុចទីមួយ ។

[០៩:២៩:៣៨]

១) សេចក្តីផ្តើម

គឺមួយមេធាវីការពារក្តីពុំមានចេតនាថ្លែងសារឡើងវិញឲ្យបានលម្អិតអំពីអំណះអំណាង ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ ។ ប៉ុន្តែ នឹងព្យាយាមពន្យល់អំពីការស្រាយបំភ្លឺនូវបញ្ហាមួយចំនួនដូចខាងក្រោម ព្រមទាំងឆ្លើយតបទៅនឹងអំណះអំណាងដែលបានលើកឡើងក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា ។

មេធាវីការពារក្តីមិនមានបំណងចង់ពិភាក្សាលើភស្តុតាង ដែលមាននៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនឬជំទាស់តវ៉ាទៅនឹងសេចក្តីយោងមិនត្រឹមត្រូវដែលមាននោះទេ ។ ការពិភាក្សាទៅលើសារធាតុនៃភស្តុតាង និងតម្រូវឲ្យតុលាការរៀបចំធ្វើសវនាការជាអសាធារណៈ ហើយទោះក្នុងករណីណាក៏ដោយវាមិនមែនជាពេលវេលាដើម្បីពិភាក្សាអំពីភាពជឿទុកចិត្តនៃភស្តុតាងដែលបានបង្ហាញដោយ ក.ស.ច.ស ដែលបានសំអាងជាសំខាន់ទៅលើតែចម្លើយរបស់ជនជាប់ចោទប៉ុណ្ណោះទេ ។

ដូច្នេះ មេធាវីការពារក្តីនឹងផ្តោតតែទៅលើអំណះអំណាងផ្នែកច្បាប់ ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប៉ុណ្ណោះ ហើយនិងធ្វើការពិភាក្សាលើអង្គសេចក្តីនេះ លុះត្រាតែតុលាការស្នើសុំឲ្យយើងដូច្នោះ ។ អំណះអំណាងទាំងនេះ នឹងកំណត់ទៅលើកម្មវត្ថុដូចខាងក្រោម៖

ក) ចរិតលក្ខណៈ និងវិសាលភាពនៃនីតិវិធីពិនិត្យបណ្តឹងឧទ្ធរណ៍

ខ) លក្ខខណ្ឌតម្រូវរបស់វិធាន៦៧.៣ នៃវិធានផ្ទៃក្នុងទាក់ទងទៅនឹងសេចក្តីសម្រេចមានសំអាងហេតុ ។

គ) ពុំមានការប្រែប្រួលកាលៈទេសៈជាក់ស្តែងដែលតម្រូវដូចបានអះអាងដោយសហព្រះរាជាអាជ្ញានោះឡើយ ។

ឃ) លក្ខខណ្ឌតម្រូវនៃការយកចិត្តទុកដាក់ពិសេស ។

ង) យុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលពាក់ព័ន្ធជាមួយជាពិសេសជាមួយដំណើរការនីតិវិធីនេះ ។

ច) ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនសមហេតុសមផល ។

ឆ) កង្វះខាតភស្តុតាងដាក់បន្ទុកលើជនត្រូវចោទ ។

ជ) ការបកស្រាយគ្មានយុត្តិកម្មរបស់សហព្រះរាជអាជ្ញាទៅលើអាកប្បកិរិយារបស់ជនត្រូវចោទ

ឈ) អាកប្បកិរិយារបស់ជនរងគ្រោះមួយចំនួន ។

[០៩:៣២:៤៩]

ញ) សិទ្ធិរបស់ជនត្រូវចោទ មិនឆ្លើយនឹងសំណួរ និងមិនសហការឲ្យបានសកម្មជួយមួយនឹងកិច្ចស៊ើបប្រឆាំងលើខ្លួន ។

ដ) លទ្ធភាពនៃការឃុំខ្លួននៅផ្ទះ ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដែលផ្តល់ការធានាដូចគ្នានឹងការឃុំខ្លួនបណ្តោះអាសន្នដែរ ដោយរំខានតិចតួចដល់សុខមាលភាពរបស់ជនត្រូវចោទ ។

មេធាវីការពារក្តីយល់ឃើញជាបឋមថា ការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺមិនមានភាពស្របច្បាប់តទៅទៀតឡើយ ។ ដោយហេតុថា ការិយាល័យចៅក្រមស៊ើបអង្កេតខកខានមិនបានអនុវត្តការយកចិត្តទុកដាក់ពិសេសនៅក្នុងកិច្ចស៊ើបសួររបស់ខ្លួន ទៅលើឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទថាប្រព្រឹត្តឡើងដោយជនត្រូវចោទ ។

មេធាវីការពារក្តីសូមស្នើថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបង្ហាញថា ជនត្រូវចោទធ្វើជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅក្នុងអំឡុងពេលពាក់ព័ន្ធដូចដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ ភស្តុតាងបែបនេះ បានដាក់បញ្ចូលទៅក្នុងសំណុំរឿងមុនការចាប់ខ្លួនអ្នកស្រីទៅទៀត ។ ហើយក៏មិនមានជាដុំកំភួនបានដាក់បញ្ចូលទៅក្នុងសំណុំរឿង នៅក្នុងអំឡុងពេលដែលឃុំខ្លួនគាត់ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៧ រហូលមកដល់បច្ចុប្បន្ននេះ ។

ការិយាល័យសហចៅក្រមស៊ើបអង្កេត មានពេលវេលាជាង១ឆ្នាំនិង៣ខែ ដើម្បីស្វែងរកភស្តុតាងគាំទ្រដល់ការចោទប្រកាន់ ។ នៅពេលនេះ ពួកគេមិនបានស្វែងរកភស្តុតាងណាមួយដែលជនជាប់ចោទដោយផ្ទាល់ជាមួយឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ ។ នៅពេលអវត្តមាននូវភស្តុតាងបែបនេះ លក្ខខណ្ឌតម្រូវដំបូងសម្រាប់បន្តការឃុំខ្លួនបណ្តោះអាសន្នគឺ មិនអាចឆ្លើយបតបានតទៅទៀតទេ ។

II. ចរិតលក្ខណៈ និងវិសាលភាពនៃការពិនិត្យបណ្តឹងឧទ្ធរណ៍

តួនាទីរបស់អង្គបុរេជំនុំជម្រះ គឺត្រួតពិនិត្យ និងតាមដានការស៊ើបអង្កេតរបស់ការិយាល័យរបស់ចៅក្រមស៊ើបអង្កេតក្នុងគោលបំណងការពារសិទ្ធិរបស់ជនត្រូវចោទ ។ នៅកថាខណ្ឌទី៥ នៃចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាចោទប្រកាន់ថា វាមិនពាក់ព័ន្ធនោះទេ ថាតើសហចៅក្រមស៊ើបអង្កេតធ្វើឲ្យមានកំហុសខាងច្បាប់ ឬអង្គហេតុក្នុងដីកាសម្រេចរបស់ខ្លួនដោយសារតែអង្គបុរេជំនុំជម្រះនូវតែអាចធ្វើ

វិភាគដោយខ្លួនឯង និងកែប្រែកំហុសនោះ ដោយដាក់បញ្ចូលមូលហេតុរបស់ខ្លួនផ្ទាល់ ។

អំណះអំណាងនេះ បានធ្វើឲ្យនិយមន័យរបស់វិធាន៦៣.៧ នូវកម្រិតនៃសហចៅក្រមស៊ើបអង្កេតទៅជាឥតប្រយោជន៍ ប៉ុន្តែវិធាននេះ អនុវត្តចំពោះតុលាការគ្រប់កម្រិតទាំងអស់ រួមទាំង ក.ស.ច.ស ផងដែរ ។ ក្រោមលក្ខខណ្ឌនៃវិធាន ៦៣.៧ សេចក្តីសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវបានសំអាងហេតុចំពោះការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ហើយជាសេចក្តីសម្រេចមានអាជ្ញាបញ្ញាប្រសិនបើមានការរំលោភបំពានណាមួយត្រូវតែបានត្រួតពិនិត្យ ដោយអង្គបុរេជំនុំជម្រះ ។

មេធាវីការពារក្តីសូមលើកឡើងថា វាពិតជាមានពាក់ព័ន្ធដែលថា សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសជាច្រើនលើអង្គហេតុនិងអង្គច្បាប់ ក្នុងដីកាសម្រេចរបស់ខ្លួន ហើយអាស្រ័យអង្គហេតុនេះ អង្គបុរេជំនុំជម្រះត្រូវតែបដិសេធដីកាសម្រេចនេះចោល ។

[០៩:៣៦:៥៨]

III. សេចក្តីសម្រេចពុំមានសំអាងហេតុគ្រប់គ្រាន់

វិធាន៦៣.៧ នៃវិធានផ្ទៃក្នុងចែងថា ដីកាសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានសំអាងហេតុចំពោះការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។

មេធាវីការពារក្តីសូមលើឡើងថា បទប្បញ្ញត្តិនេះត្រូវបានរំលោភបំពានជាច្រើនលើក ច្រើនសានៅក្នុងឱកាសជាច្រើនដងនៅទូទាំងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ។ សហចៅក្រមស៊ើបង្កេតខកខានមិនបានផ្តល់សំអាងគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់របស់ខ្លួន ហើយផ្តល់ព័ត៌មានមិនត្រឹមត្រូវទាក់ទងនឹងភស្តុតាងប្រឆាំងនឹងជនត្រូវចោទ ។

ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ពុំបានផ្តល់សំអាងឲ្យបានគ្រប់គ្រាន់នោះទេ ដែលជាការផ្ទុយទៅនឹងវិធាន៦៣.៧ នៃវិធានផ្ទៃសក្នុង និងគោលការណ៍ទូទៅរបស់ច្បាប់ ។ ការខកខានបែបនេះ អាចឈានទៅរកការច្រានចោលនូវដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

ជាបឋម សហព្រះរាជអាជ្ញាបានបកស្រាយមិនត្រឹមត្រូវនូវកថាខណ្ឌទី៨ នៃចម្លើយតបរបស់ខ្លួនចំពោះវិធាន៦៣ ដែលថា សហចៅក្រមស៊ើបអង្កេតតម្រូវឲ្យតែកំណត់ខាងអង្គច្បាប់និងអង្គហេតុដែលច្បាប់ និងអង្គហេតុដែលត្រូវពិចារណា ហើយដោយគ្រាន់តែការយោងជាទូទៅ ទៅលើសំណុំរឿង និងកាលៈទេសៈដទៃទៀត គឺគ្រប់គ្រាន់ហើយ ។

វិធាន៦៣.៧ តម្រូវយ៉ាងច្បាស់លាស់ឲ្យសហចៅក្រមស៊ើបអង្កេតយោងទៅលើភស្តុតាងដែលយកមកសំអាងនូវក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន ។ ដើម្បីឲ្យស៊ីចង្វាក់ជាមួយនឹងយុត្តិសាស្ត្រពីតុលាការជាច្រើនផ្សេងទៀត អ្វីដែលតម្រូវនោះ គឺសេចក្តីសម្រេចដោយសំអាងហេតុ ។ ដោយហេតុថាច្បាប់តម្រូវយ៉ាងច្បាស់ថា សេចក្តីសម្រេចត្រូវតែមានសំអាងហេតុ ហើយការយោងជាទូទៅ ទៅលើសំណុំរឿងមិនគ្រប់គ្រាន់ទេ ដោយសារតែខ្វះភាពជាក់លាក់ ។ សហព្រះរាជអាជ្ញាបដិសេធថា ដីកាសម្រេចឃុំខ្លួនអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនមានកំហុសនោះទេ កថាខណ្ឌទី៩ នៃចម្លើយតប ។ ប៉ុន្តែ ខ្លួនបានប៉ុនប៉ងផ្តល់ការយោងចំពោះភស្តុតាងដែលថា ដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនមិនខ្វះនូវសំអាងហេតុទេ ។

[០៩:៣៩:៣៤]

IV. ពុំមានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងដែលតម្រូវ

សហព្រះរាជអាជ្ញាបានថ្លែងនៅក្នុងកថាខណ្ឌទី១៣ និង៤៥ នៃចម្លើយតបរបស់ខ្លួនថា ស្ថានភាពរបស់ជនត្រូវចោទត្រូវតែបានប្រៀបធៀបជាមួយនឹងស្ថានភាពរបស់ចោទ នៅចំពោះមុខតុលាការ *អាយស៊ីស៊ី អាយស៊ីធីវ៉ាយ អាយស៊ីធីអរ* និងតុលាការពិសេសសេរ៉ាឡេអូន ដែលនៅទីនោះជនត្រូវចោទត្រូវតែបង្ហាញពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ។

អ្វីដែលសហព្រះរាជអាជ្ញាមិនបានលើកឡើងនោះគឺសច្ចធានៅអ.វ.ត.ក គឺត្រូវតែមានសេរីភាព ហើយមិនមែនជាការឃុំខ្លួននោះទេ ។ ដូចមានចែងនៅក្នុងមាត្រា២០៣ នៃក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖ ...

វិធាន៨២.១ នៃវិធានផ្ទៃក្នុងចែងថា ត្រូវមានសេរីភាពជារហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះសាលាដំបូង ។ លើកលែងតែមានការបង្គាប់ឲ្យមានឃុំខ្លួនបណ្តោះអាសន្នដូចមានចែងក្នុងវិធាននេះ ដែលពិតជាបានលើកឡើងពីសច្ចធានៃសេរីភាពយ៉ាងច្បាស់ ។ មាត្រា៩.៣ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិពលរដ្ឋ *អាយស៊ីធី អាយស៊ីស៊ីភីអរ* ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃ២៦ ខែសីហា ឆ្នាំ១៩៩២ ថា ការឃុំមនុស្សដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែ ការដាក់ឲ្យនៅក្រៅឃុំត្រូវតែមានការធានា ការចូលខ្លួនរបស់ជននោះនៅពេលដែលមានសវនាការបទដ្ឋានគ្រប់គ្រងនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន នៅតុលាការដទៃទៀត គឺមិនអាចអនុវត្តចំពោះមុខអ.វ.ត.ក

បានឡើយ ។ សហចៅក្រមស៊ើបអង្កេតត្រូវបង្ហាញឲ្យឃើញថា មានមូលដ្ឋានដើម្បីបន្តការឃុំខ្លួននៅដំណាក់កាលនៃនីតិវិធីនេះ ហេតុដូច្នេះបន្ទុកមិនត្រូវធ្លាប់មកលើមេធាវីការពារក្តីនទេ ។

មេធាវីការពារក្តីមិនត្រូវបានបង្ហាញពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ដូចបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះឡើយ ។ នៅក្នុងពន្យារពេលចរិតលក្ខណៈនៃដំណាក់កាលស៊ើបសួរបានបង្កឲ្យជនត្រូវចោទទទួលរងនូវការឃុំខ្លួនក្នុងរយៈពេលវែងរហូតដល់បច្ចុប្បន្ននេះ ហើយបញ្ហានេះបង្កើតដោយឯងៗនៅការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង ។

[០៩:៤២:២៣]

V. បទដ្ឋាននៃការយកចិត្តទុកដាក់ពិសេស

សហចៅក្រមស៊ើបអង្កេតបានប្រើនៅក្នុងដីកាសម្រេចស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅបទដ្ឋាននៃការយកចិត្តទុកដាក់គ្រប់គ្រាន់នៅក្នុងការសម្រេចថា តើខ្លួនប្រតិបត្តិតាមដំណើរការមួយក្នុងពេលវេលាសមហេតុសមផលដែរឬយ៉ាងណា? សហចៅក្រមស៊ើបអង្កេតត្រូវធ្វើឲ្យប្រាកដថា កិច្ចស៊ើបសួររបស់ខ្លួនត្រូវបានធ្វើឡើងគ្រប់ជ្រុងជ្រោយ ។

មេធាវីការពារក្តីសូមទាញហេតុផលថា បទដ្ឋានត្រឹមត្រូវមួយគឺ មិនមែនជាអ្វីដែលហៅថាការយកចិត្តទុកដាក់គ្រប់គ្រាន់ដែលអនុវត្តន៍ដោយសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែត្រូវជាបទដ្ឋានខ្ពស់ជាងនេះ គឺបទដ្ឋាននៃការយកចិត្តទុកដាក់ពិសេសដែលត្រូវបានកំណត់ជាច្រើនលើក ច្រើនសាដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ។ នៅក្នុងកថាខណ្ឌនៃ១៧ នៃចម្លើយតបរបស់ខ្លួនជាភាសាអង់គ្លេស អត្ថបទដើម សហព្រះរាជអាជ្ញាបានចោទប្រកាន់ទាំងភ័ន្តច្រឡំនិងគ្មានមូលដ្ឋានថា មេធវីការពារក្តីបានយោងទៅលើបទដ្ឋាននៃការយកចិត្តទុកដាក់ហ្មត់ចត់ដាច់ណាត់ ។ មេធាវីការពារក្តីមិនបានប្រើវាក្យសព្ទនេះទេ ហើយក៏មិនបានលើកឡើងពីបទដ្ឋានដែលមិនអាចធ្វើឲ្យបានសម្រេចនោះដែរ ។ មេធាវីការពារក្តីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តមិនត្រឹមត្រូវនូវបទដ្ឋានកម្រិតទាបថា ការយកចិត្តទុកដាក់គ្រប់គ្រាន់ជាជាងបទដ្ឋាននៃការយកចិត្តទុកដាក់ពិសេស ។ ចំពោះការអនុវត្តបទដ្ឋានត្រឹមត្រូវមួយសហព្រះរាជអាជ្ញាបានយល់ព្រមនៅក្នុង *ហ្វូតណូត* ៧៦ ថា ល្បឿននៃការស៊ើបអង្កេតមិនបានធ្វើឲ្យមានសុទិដ្ឋនិយមសោះ នៅក្នុងអំឡុងពេល១ឆ្នាំដំបូងនៃការឃុំខ្លួនជនត្រូវចោទ ។

សហព្រះរាជអាជ្ញាបានលើកឡើងថា ឥឡូវនេះដីកាដំណោះស្រាយលើសំណុំរឿងលេខ០០១ ត្រូវបានចេញហើយ គេរំពឹងថា ល្បឿននៃការស៊ើបអង្កេតនឹងជឿនលឿនទៅមុខយ៉ាងលឿននៅថ្ងៃអនាគត។

VI. យុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប

សហព្រះរាជអាជ្ញាបដិសេធអំពីភាពអាចអនុវត្តបាននូវយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបនៅក្នុងការសម្រេចថា តើកិច្ចស៊ើបសួរលើសរយៈពេលសមហេតុសមផលដែរឬយ៉ាងណា? ដោយមិនស្វែងរកការណែនាំពីតុលាការសិទ្ធិមនុស្សអឺរ៉ុប សហព្រះរាជអាជ្ញាបានលើកឡើងថា *អាយស៊ីធីវ៉ាយ* និង *អាយស៊ីធីអរ* អាចផ្តល់ការគាំទ្របែបនេះបាន ។ តាមការពិត *អាយស៊ីធីវ៉ាយ* និង *អាយស៊ីធីអរ* បានយកយុត្តិសាស្ត្ររបស់តុលាការសិទ្ធមនុស្សអ៊ឺរ៉ុប ជាគោលការណ៍ណែនាំក្នុងបញ្ហាសិទ្ធិមនុស្ស ដែលពាក់ព័ន្ធជាមួយដំណើរការនីតិវិធី ដូចដែល *អាយស៊ីស៊ី* និងតុលាការពិសេសសេរ៉ាឡេអូន បានធ្វើរួចមកហើយ ។ ពុំមានមូលដ្ឋានទាល់តែសោះ ដែលថាសហព្រះរាជអាជ្ញាមិនអាចស្វែងរកការណែនាំពីសាលក្រមរបស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបនោះ ។

[០៩:៤៥:៣៩]

មេធាវីការពារក្តីសូមលើកឡើងថា ករណីយុត្តិសាស្ត្ររបស់*អាយស៊ីធីវ៉ាយ* និង *អាយស៊ីធីអរ* ពាក់ព័ន្ធតិចតួចចំពោះបញ្ហាជាក់លាក់នេះ ដោយសារតែការឃុំខ្លួនបណ្តោះអាសន្ននៅតុលាការអាដហុកគ្រប់គ្រាន់ដោយវិធានខុសៗគ្នា ។ ការឃុំខ្លួនបណ្តោះអាសន្ននៅតុលាការអាដហុក គឺជាគោលការណ៍ ហើយការដោះលែងឲ្យនៅក្រៅឃុំជាករណីពិសេស ។ ក្របខណ្ឌច្បាប់ទាំងមូលរបស់ អ.វ.ត.ក គឺផ្អែកទៅលើការសន្មតថា ជនត្រូវចោទត្រូវតែដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើយុត្តិកម្មអំពីការឃុំខ្លួនបណ្តោះអាសន្ន ។ អាស្រ័យហេតុនេះ វាពិតជាមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង បើប្រៀបធៀបជាមួយនឹងគោលនយោបាយរបស់តុលាការអាដហុកជាច្រើននោះ ។

បន្ថែមពីលើនេះ ប្រព័ន្ធនៅ*អាយស៊ីធីវ៉ាយ* និង *អាយស៊ីធីអរ* គឺអាស្រ័យនឹងប្រព័ន្ធច្បាប់ខំមិនឡជាជាងប្រព័ន្ធច្បាប់ស៊ីវិលឡ ។ ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញវិញ អាស្រ័យទៅលើប្រព័ន្ធច្បាប់ស៊ីវិល ។ យុត្តិសាស្ត្ររបស់តុលាការសិទ្ធមនុស្សអ៊ឺរ៉ុប ដែលមេធាវីការពារក្តីលើកមកសំអាងនៅក្នុងបណ្តឹងរបស់ខ្លួនគឺ ទាក់ទងទៅនឹងប្រទេសដែលប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិល ឧទាហរណ៍ ប្រទេសបារាំង អាល្លឺម៉ង់ និង អូទ្រីស ។ ហេតុដូច្នេះ មេធាវីការពារយល់ឃើញថា ការពឹងផ្អែកលើយុត្តិសាស្ត្រខាងលើ គឺមានលក្ខណៈសមហេតុផល ហើយទាក់ទងនឹងបញ្ហាបច្ចុប្បន្ននេះទៀតផង ហើយក៏អាចផ្តល់ជាការណែនាំដល់អង្គបុរេជំនុំជម្រះដែរ ។

សហព្រះរាជអាជ្ញា បានតវ៉ានៅក្នុងកថាខណ្ឌទី១៧ នៃចម្លើយតបរបស់ខ្លួនថា មេធាវីការពារក្តីអាចជ្រើសរើសយក ករណីយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ដើម្បីធ្វើយុត្តិកម្មលើភាពអាចអនុវត្តបាននៃបទដ្ឋាននៃការយកចិត្តទុកដាក់ពិសេស ។ ហេតុផលដែលថា សហព្រះរាជអាជ្ញាអាចគិតថា មានបទដ្ឋានផ្សេងៗដែលត្រូវបានអនុវត្តជាច្រើនដង ប៉ុន្តែមេធាវីការពារក្តីមិនបានដឹងពីករណីណាមួយដែលបទដ្ឋានមានកម្រិតទាបត្រូវបានអនុវត្តនោះឡើយ ។

[០៩:៤៨:០០]

បន្ថែមពីលើនេះ សហព្រះរាជអាជ្ញាខកខានមិនបានសំអាង ករណីយុត្តិសាស្ត្រណាមួយដើម្បីបង្ហាញថាតុលាការអ៊ឺរ៉ុប បានអនុវត្តបទដ្ឋានខុសៗគ្នា ។ មេធាវីការពារក្តីសូមលើកឡើងថា តុលាការអ៊ឺរ៉ុបបានប្រើបទដ្ឋាននៃការយកចិត្តទុកដាក់នេះជាញឹកញាប់នៅក្នុងរឿងក្តីខ្លួន ដែលពាក់ព័ន្ធជាមួយចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងមិនគ្រប់គ្រាន់នៅក្នុងយុត្តិសាស្ត្រជាក់លាក់ ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញានោះ ។

ក្នុងកថាខណ្ឌទី១៨ និងកថាខណ្ឌទី១៩ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបមិនជាប់ពាក់ព័ន្ធនោះទេ ដោយសារតែចរិតលក្ខណៈខុសគ្នាជាមូលដ្ឋានរវាងតុលាការអ៊ឺរ៉ុប និងអ.វ.ត.ក ។ ចរិតលក្ខណៈរបស់ស្ថាប័នទាំងពីរនេះគឺខុសគ្នា ប៉ុន្តែតុលាការអ៊ឺរ៉ុបកំណត់ពីបទដ្ឋានជាអប្បបរមាស្តីពីសិទ្ធិមនុស្សដែលរដ្ឋជាសមាជិករបស់ខ្លួនគួរតែប្រកាន់ខ្ជាប់។ បទដ្ឋានជាអតិបរមាមួយ ដែលយើងខ្ញុំដាក់ជូននេះ គួរតែត្រូវបានយកមកពិចារណាដោយតុលាការមួយដែលមានលក្ខណៈអន្តរជាតិ តួយ៉ាងដូចជា អ.វ.ត.ក ។ និងជាពិសេស នៅក្នុងស្ថានភាពឧក្រិដ្ឋកម្មអន្តរជាតិស្មុគស្មាញស្ថិតនៅក្រោមកិច្ចស៊ើបសួរ ហើយវាចាំបាច់បំផុតដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទត្រូវបានការពារ ។

នៅកថាខណ្ឌទី១៩ សហព្រះរាជអាជ្ញាបានបញ្ជាក់អះអាងថា រឿងក្តីរបស់ជនត្រូវចោទមានលក្ខណៈស្មុគស្មាញជាងរឿងក្តីដែលបានប្តឹងនៅចំពោះមុខតុលាការអ៊ឺរ៉ុប តាមពិតទៅមានយុត្តាធិការជាតិជាច្រើនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ រួមទាំងឧក្រិដ្ឋកម្មសង្គ្រាម និងរឿងក្តីព្រហ្មទណ្ឌស្មុគស្មាញធ្ងន់ធ្ងរដទៃទៀត ដែលរឿងក្តីទាំងអស់នេះជាកម្មវត្ថុនៃការពិនិត្យពិច័យរបស់តុលាការអ៊ឺរ៉ុបនេះ ។

[០៩:៥០:០០]

ដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា យុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុប ដែលបានលើកឡើង

នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺជាប់ពាក់ព័ន្ធ និងអាចផ្តល់នៅការណែនាំដ៏មានប្រយោជន៍សម្រាប់តុលាការនេះ ។

៧) ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនសមហេតុផល

នៅក្នុងកថាខណ្ឌទី២៦នៃចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងថា វិធាន៦៣ នៃវិធានផ្ទៃក្នុងកំណត់ពីថិរវេលាឃុំខ្លួនបណ្តោះអាសន្នជាអប្បបរមាចំនួនបីឆ្នាំ ។ បញ្ជាក់ថាថិរវេលាឃុំខ្លួនបណ្តោះអាសន្នទាំងឡាយ ដែលមានរយៈពេលតិចជាងបីឆ្នាំ ត្រូវតែមានលក្ខណៈសមហេតុសមផល ។ ជំហរនេះ គឺជាការភ័ន្តច្រឡំដោយខ្លួនឯងតែម្តង ក្នុងករណីដែលសេរីរបស់បុគ្គលម្នាក់ត្រូវបានគំរាមកំហែង នោះសង្គមទាំងមូលដែលប្រកាន់ខ្ជាប់នីតិរដ្ឋត្រូវផ្តល់នូវលក្ខណៈវិនិច្ឆ័យ ដើម្បីពិចារណាពីភាពសមហេតុផលនៃការបដិសេធសេរីភាពរបស់បុគ្គលណាម្នាក់ ។ លក្ខណៈវិនិច្ឆ័យនៃការយកចិត្តទុកដាក់ពិសេស ផ្តល់នូវការការពារមួយដែលធានាថា ថិរវេលានៃការឃុំខ្លួនមិនត្រូវប្រែក្លាយទៅជាសមហេតុសមផលនោះទេ ។

នៅក្នុងកថាខណ្ឌទី១៨ និង២៨ ការិយាល័យសហព្រះរាជអាជ្ញាលើកឡើងថា ការចោទប្រកាន់ពីបទសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់មួយនៃការទទួលខុសត្រូវបានធ្វើឲ្យដំណើរការនីតិវិធីមានភាពស្មុគស្មាញ ។ ចំណុចនេះ គឺមិនសមហេតុសមផលទាល់តែសោះ ហើយមិនគួរត្រូវយកមកប្រើប្រាស់ធ្វើជាយុត្តិកម្ម សម្រាប់ការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះទេ ។

[០៩:៥១:៥០]

ការិយាល័យសហព្រះរាជ្ញា បានសំអាងទៅលើចំណុចមួយចំនួន សូមមើលកថាខណ្ឌទី២២, ២៧ និង២៨ នៃចម្លើយតបរបស់ខ្លួន ដើម្បីអះអាងថា ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទរយៈពេលមួយឆ្នាំ គឺមិនមែនមិនសមហេតុសមផលនោះទេ ។ រយៈពេលនៃការឃុំខ្លួនបណ្តោះនោះ មិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះទេ ។ ផ្ទុយទៅវិញ ការពន្យារពេលលើសពីរយៈពេលមួយឆ្នាំ ដែលមេធាវីការពារក្តីជំទាស់តវ៉ាទៅវិញនោះទេ ដោយអះអាងថា មានលក្ខណៈមិនសមហេតុសមផលនៅគ្រប់កាលៈទេសៈទាំងអស់ និងបានបង្ហាញពីកង្វះខាតក្នុងការបំពេញកិច្ច ដោយអាជ្ញាធរស៊ើបសួរនៅក្នុងអំឡុងពេលនៃការឃុំខ្លួនដំបូង ។

[០៩:៥២:៤៤]

៨) កង្វះភស្តុតាង

នៅក្នុងកថាខណ្ឌទី៣៩ ការិយាល័យសហព្រះរាជអាជ្ញាមិនបានផ្ដល់មូលដ្ឋានអង្គហេតុណាមួយ ដោយគ្រាន់តែសំអាងទៅលើសំណុំរឿងចំពោះជំនឿដែលខ្លួនបានលើកឡើងថា ភស្តុតាងប្រឆាំងនឹងជនត្រូវចោទ បានកើនឡើងច្រើនទាំងបរិមាណ និងស្ថានទម្ងន់នៅក្នុងប៉ុន្មានខែថ្មីៗនេះ ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្ដោតលើការស៊ើបសួររបស់ខ្លួន ទៅលើការស្វែងរកភ័ស្តុតាងនៅសំណុំរឿងលេខ០០១ នៅក្នុងឆ្នាំទី១ នៃការឃុំខ្លួនជនត្រូវចោទ និងមិនបានផ្ដល់ភ័ស្តុតាងផ្ទាល់ប្រឆាំងមកលើជនត្រូវចោទនោះទេ ។ ក្នុងន័យនេះ នឹងដូចដែលបានលើកឡើងពីមុនរួចមកហើយ សហព្រះរាជអាជ្ញាលើកឡើងយ៉ាងច្បាស់នៅក្នុងអក្សរក្នុងលេខយោងទី៧៦ នៃចម្លើយតបរបស់ខ្លួនថា ក្នុងពេលឥឡូវនេះ ដីកាដំណោះស្រាយលើសំណុំរឿងលេខ០០១ ត្រូវបានចេញរួចហើយ ។ ខ្លួនរំពឹងថា ល្បឿននៃកិច្ចស៊ើបសួរនឹងមានសន្ទុះលឿនយ៉ាងខ្លាំងនៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ ប៉ុន្តែខ្លួនបានយល់ស្របថា ល្បឿនស៊ើបសួរមិនទាន់បានពេញនៅឡើយទេគិតមកទល់នឹងពេលនេះ ។

[០៩:៥៤:០៥]

នៅក្នុងកថាខណ្ឌទី២៩ សហព្រះរាជអាជ្ញាអះអាងថា ភ័ស្តុតាងដែលសហចៅក្រមស៊ើបអង្កេតប្រមូលបានគ្របដណ្ដប់ទៅលើគ្រប់ទម្រង់ និងប្រភេទទាំងអស់នៃការចូលរួមចំណែករបស់ដើមបណ្ដឹងឧទ្ធរណ៍នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានភ័ស្តុតាងនៃ *គ្រីនបារ* ភ័ស្តុតាងដែលភ្ជាប់ គ្រីនបារទៅនឹងរចនាសម្ព័ន្ធដឹកនាំ ដែលដើមបណ្ដឹងឧទ្ធរណ៍បានអនុវត្តនូវសិទ្ធិអំណាចក្នុងការបញ្ជា ។ ភ័ស្តុតាងដែលគាំទ្រអំពីការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ភ័ស្តុតាងដែលគាំទ្រអំពីធាតុផ្សំនានា ខាងយុត្តាធិការដូចជា វាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលជាដើម ។ ដូចគ្នានឹងការិយាល័យសហចៅក្រមស៊ើបអង្កេតដែរ សហព្រះរាជអាជ្ញាខកខានមិនបានផ្ដល់ប្រភពណាមួយដើម្បីគាំទ្រដល់ ការអះអាងបែបនេះនោះទេ ប្រសិនបើបញ្ហានេះវាដូច្នោះមែននោះ រឿងក្ដីនេះនឹងត្រូវបានរួចរាល់សម្រាប់ការបើកសវនាការក្នុងពេលឆាប់ៗនេះទៅហើយ ។ សហចៅក្រមស៊ើបអង្កេតបានយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការប្រមូលភ័ស្តុតាងនៅក្នុងរឿងក្ដីរបស់ ឌុច តែខកខានមិនបានប្រមូលភ័ស្តុតាងផ្ទាល់ដែលដាក់បន្ទុកមកលើជនត្រូវចោទ ។ ដូច្នេះ វាកំពុងបង្ហាញពីការខ្វះការយកចិត្តទុកដាក់ពិសេសក្នុងការបំពេញទៅលើរឿងក្ដីរបស់ជនត្រូវចោទ នៅក្នុងសំណុំរឿងលេខ០០២ ។

អង្គបុរេជំនុំជម្រះ បានចេញសេចក្ដីសម្រេចកាលពីលើកមុនថា ដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនជនត្រូចោទជាបណ្ដោះអាសន្ន គឺជាការត្រឹមត្រូវ សហមេធាវីការពារក្ដីមិនអាចទៅ

នៅពីក្រោយហេតុផល ដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចមុនៗនោះទេ ។ មេធាវីការពារក្តីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានឆ្លើយតប ទៅនឹងលក្ខខណ្ឌសមស្របនោះទេ ដោយខ្លួនខកខាន មិនបានផ្តល់ភ័ស្តុតាងផ្ទាល់ប្រឆាំងលើជនត្រូវចោទនៅក្នុងឆ្នាំដែលរូបគាត់ឋិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននោះ ។ ការបន្តថិរវេលានៃការឃុំខ្លួនបន្ថែមទៀត លក្ខខណ្ឌតម្រូវត្រូវតែខ្ពស់ដើម្បីឲ្យ ក.ស.ច.ស រកភ័ស្តុតាងដាក់ចូលក្នុងសំណុំរឿង ។

[០៩:៥៦:២៧]

ឥឡូវនេះ ពេលវេលាមួយឆ្នាំបានកន្លងផុតទៅហើយ ដូច្នេះលក្ខខណ្ឌតម្រូវត្រូវតែមានកម្រិតខ្ពស់ ក.ស.ច.ស ត្រូវតែផ្តល់នូវភស្តុតាងផ្ទាល់ប្រឆាំងមកលើអ្នកស្រី ។ ក.ស.ច.ស មិនមានលទ្ធភាពធ្វើដូច្នេះឡើយ ហើយថាភស្តុតាងដែលខ្លួនបានរកឃើញ នៅក្នុងការពាក់ព័ន្ធទៅនឹងជនត្រូវចោទនោះ គឺពាក់ព័ន្ធត្រឹមអង្គហេតុដែលថា អ្នកស្រីធ្លាប់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្នុងរបបនោះប៉ុណ្ណោះ ដែលវាមិនពាក់ព័ន្ធអ្វីទៅនឹងបទឧក្រិដ្ឋដែលចោទមកលើអ្នកស្រីនោះទេ ។

៩) ការបកស្រាយអំពីអាកប្បកិរិយារបស់ជនត្រូវចោទ

សហព្រះរាជអាជ្ញាអះអាងក្នុងកថាខណ្ឌទី៤៧ ថាជនត្រូវចោទអាចប្រកែកថា ខ្លួនគ្មានពិរុទ្ធភាពដូចដែលគាត់បានលើកឡើងក្នុងសវនាការមុនៗនោះ អាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់គាត់ ប្រសិនបើគាត់ត្រូវបានដោះលែងមែននោះ ។ មេធាវីការពារក្តីសូមជំទាស់ថា ពុំមានមូលដ្ឋានអាចដឹងបានសម្រាប់ការព្រួយបារម្ភស្មានៗបែបនេះទេ បញ្ហាគឺនៅត្រង់ថា តើការដោះលែងជនត្រូវចោទឲ្យឋិតនៅក្រៅឃុំបណ្តោះអាសន្ន វាពិតជាបង្កហានិភ័យមកលើសាក្សី ការថែរក្សាភស្តុតាង និងរក្សាសណ្តាប់ធ្នាប់ដែរឬយ៉ាងណានោះ? សហព្រះរាជអាជ្ញា បានរកការសំអាងដែលមិនត្រឹមត្រូវ និងមិនសមស្របមកលើអាកប្បកិរិយារបស់ជនត្រូវចោទក្នុងសវនាការលើកមុន ។ យើងសូមស្នើឲ្យតុលាការ កុំយកមកពិចារណាចំពោះបញ្ហានេះ ដោយសារការអះអាងរបស់ ក.ស.ព វាមិនពាក់ព័ន្ធឡើយ។

១០) ការគំរាមកំហែងរបស់ជនរងគ្រោះមកលើ លោក នួន ជា និង លោក ខៀវ សំផន

យើងស្នើសុំឲ្យតុលាការ កុំយកមកពិចារណាចំពោះបញ្ហាដែលបានលើកឡើងក្នុងកថាខណ្ឌទី៥២ របស់ចម្លើយតបរបស់ ក.ស.ព ដោយសារការអះអាងបែបនេះ វាមិនពាក់ព័ន្ធឡើយនៅក្នុងសំណុំរឿង ។ ជនត្រូវចោទបានរស់នៅ និងបានធ្វើដំណើរយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេលដ៏ច្រើនឆ្នាំមុននឹងការចាប់ខ្លួននិងឃុំខ្លួនគាត់ ដោយមិនមានឧបទ្ទវហេតុអ្វីមកប៉ះពាល់មកដល់សន្តិ-

សុខរបស់គាត់ឡើយ ។ ចម្លើយរបស់សហព្រះរាជអាជ្ញា ដែលសំអាងទៅលើអត្ថបទរៀបរៀងដោយ រ៉ុកសាវ៉ា អក្សរក្នុងលេខយោង១០៨ មេធាវីការពារក្តីបានលើកឡើងពីការខកខានរបស់អត្ថបទនេះក្នុងសារណារបស់ខ្លួនដែលមានចុះកាលបរិច្ឆេទ ពុំមានមូលដ្ឋានដែលតុលាការអាចចាត់ទុកអត្ថបទនេះជាឯកសារ ដែលត្រូវតែធ្វើតាមនោះទេ យើងសុំរំឮកដល់តុលាការអំពីការសន្មតទុកជាមុនថាគ្មានទោសដរាបណាតុលាការមិនទាន់រកឃើញថាមានពិរុទ្ធភាព ។ លើសពីនេះទៅទៀត ពុំមានភស្តុតាងដែលថាជនរងគ្រោះដោយសារអំពើហិង្សាបានប្រព្រឹត្តសកម្មភាពខុសច្បាប់ប្រឆាំងមកលើចារីដែលត្រូវបានចោទប្រកាន់នោះទេ ។

[០៩:៥៩:៤៥]

១១) សិទ្ធិនៅស្ងៀមមិនឆ្លើយតបនិងមិនសហការក្នុងដំណើរការនីតិវិធី

នៅក្នុងការជំទាស់តវ៉ារបស់មេធាវីការពារក្តីទៅនឹងគោលបំណងរបស់សហចៅក្រមស៊ើបអង្កេតដើម្បីពន្យារការបន្តការឃុំខ្លួនបណ្តោះអាសន្ន អ្នកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ មេធាវីការពារក្តីបានបញ្ជាក់ថា មេធាវីការពារក្តីមិនបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរនោះទេ ចំណុចនេះ គឺមិនបាននាំទៅដល់ការពន្យារណាមួយនៅក្នុងដំណើរការនីតិវិធីនោះឡើយ ។ មេធាវីការពារក្តី មិនស្ថិតនៅក្រោមកាតព្វកិច្ចណាមួយដើម្បីស្នើសុំឲ្យមានកិច្ចស៊ើបអង្កេតនោះទេ ។

ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបានភ័ន្តច្រឡំចំពោះការលើកឡើងនៅក្នុងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នថា ឥរិយាបទរបស់មេធាវីការពារក្តី ដែលមិនទាន់ស្នើសុំឲ្យបើកកិច្ចស៊ើបសួរណាមួយនៅឡើយនោះ មិនបានចូលរួមចំណែកដល់ការពន្លឿនដំណើរការនីតិវិធីនោះទេ ។

[១០:០១:០៣]

មេធាវីការពារក្តី សូមរំឮកតុលាការឡើងវិញដោយក្តីគោរពថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលបន្ទុកនៃការប្រមូលភ័ស្តុតាង គឺដំបូងឡើយតែពឹកផ្អែកទៅលើអាជ្ញាធរស៊ើបអង្កេត មិនមែនពឹងផ្អែកមកលើមេធាវីការពារក្តីនោះទេ ។ ទោះបីជា សហចៅក្រមស៊ើបអង្កេតទទួលជោគជ័យ ឬមិនបានជោគជ័យនៅក្នុងការស្វែងរកភ័ស្តុតាងក៏ដោយ ក៏មេធាវីការពារក្តីមិនមានកាតព្វកិច្ចណាមួយក្នុងការស្នើសុំឲ្យបើកកិច្ចស៊ើបសួរនោះទេ ។ ការដែលមេធាវីការពារក្តី មិនបានធ្វើសំណុំបែបបទនោះ មិនអាចត្រូវបានយកមកធ្វើសំអាងឲ្យត្រឹមត្រូវ ដើម្បីរិះគន់មេធាវីការពារតាមមធ្យោបាយណាមួយឡើយ ។

១២) អំណះអំណាងផ្សេងៗទៀត គឺការដោះលែងដោយដាក់ឲ្យឋិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

ជាជម្រើស មេធាវីការពារក្តីសុំដោះលែងជនត្រូវចោទ ដោយដាក់ឲ្យឋិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ។ មេធាវីការពារក្តីសូមរក្សាទុកនូវចំណុចទាំងអស់ដែលបានលើកឡើងយ៉ាងពេញលេញនៅក្នុងបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី របស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានន័យថា ជាគោលការណ៍កាលណាមានលទ្ធភាពដែលជាវិធានណាដែលផ្តល់នូវការអន្តរាយតិចតួច ដែលប្រសើរជាងការឃុំខ្លួនបណ្តោះអាសន្ន ។

មេធាវីការពារក្តីសូមស្នើថា ជនត្រូវចោទគួរតែទទួលបាននូវការដោះលែង ដោយដាក់ឲ្យឋិតក្រោមត្រួតពិនិត្យរបស់តុលាការ ឲ្យសមស្របទៅនឹងលក្ខខណ្ឌដែលចាំបាច់ ឬតម្រូវឲ្យឋិតនៅក្នុងទម្រង់មួយនៃការឃុំខ្លួនក្នុងផ្ទះ ។ មេធាវីការពារក្តីបានលើកឡើងនូវសំណើជាលក្ខខណ្ឌនៃការដោះលែងដោយឋិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍កាលពីលើកមុន ។

[១០:០៣:០៩]

១៣) សេចក្តីសន្និដ្ឋាន

ជនត្រូវចោទ ឋិតនៅក្នុងការឃុំខ្លួនអស់រយៈពេល១៥ខែ មកហើយ ហើយកិច្ចស៊ើបសួរបាននឹងកំពុងបន្តសម្រាប់រយៈពេលវែង ដែលគួរពិចារណា ។ យើងស្នើសុំឲ្យអង្គបុរេជំនុំជម្រះ ថ្លឹងថ្លែងពីផលប្រយោជន៍សាធារណៈ ក្នុងការធានាឲ្យមានសវនាការមួយប្រព្រឹត្តឡើងដោយមានវត្តមានជនត្រូវចោទ ដោយមិនមានការជ្រៀតជ្រែកទៅនឹងការចាត់ចែងយុត្តិធម៌ប្រឆាំងទៅនឹងសច្ចធារ នៃសេរីភាពសម្រាប់ជនត្រូវចោទ ដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស ។ លក្ខខណ្ឌនៃវិធាន៦៣.៣ នៃវិធានផ្ទៃក្នុងមិនបានផ្តល់នូវមូលដ្ឋានឲ្យបានគ្រប់គ្រាន់សម្រាប់ការបន្ថែមថិរវេលានៃការឃុំខ្លួនជាបន្តទៅទៀតនោះទេ ។ សហចៅក្រមស៊ើបអង្កេត មិនបានឈានទៅដល់កម្រិតនៃការយកចិត្តទុកដាក់ពិសេស ដែលបានតម្រូវឲ្យមាននៅក្នុងកិច្ចស៊ើបសួររបស់ខ្លួន ទៅលើរឿងប្រឆាំងមកលើជនត្រូវចោទ ។ វាមិនមែនជាចម្លើយទៅនឹងកង្វះការយកចិត្តទុកដាក់ជាពិសេស ដើម្បីលើកឡើងថា ជនត្រូវចោទដទៃទៀត ត្រូវបានស៊ើបសួរមកហើយនោះទេ ។ សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចបំពេញភារកិច្ច ដោយមានការ

យកចិត្តទុកដាក់ពិសេសទៅលើរឿងក្តីរបស់ជនត្រូវចោទ ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ ទាក់ទងទៅនឹងសិទ្ធិពិនិត្យមើលសំណុំរឿង មិនបានស្វែងរកនូវចំណុចនេះទេ ។

ក្នុងសេចក្តីសន្និដ្ឋាននេះ មេធាវីការពារក្តីសូមស្នើសុំឲ្យដោះលែងជនត្រូវចោទជាបណ្តោះអាសន្ន ។ សូមអរគុណ ។

[១០:០៤:៥៦]

**ប្រធានអង្គបុរេ៖**

តុលាការសម្រាក១៥នាទី ។

*[អង្គសវនាការសម្រាកនៅម៉ោង១០:០៥នាទីដល់ម៉ោង ១០:២៦:០០]*

**លោក ជួន សុវាសី៖**

តុលាការ! សូមអញ្ជើញក្រោកឈរ!

[១០:២៦:០៦]

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ ។

សូមអញ្ជើញ សហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋាន ។ លោកមានរយៈពេលមួយម៉ោងសម្រាប់ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ។

សូមអញ្ជើញ ។

**លោក សេង ប៊ុនឃាង៖**

សូមគោរពអង្គបុរេជំនុំជម្រះ! តាំងនាមអយ្យការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខ្ញុំសូមតម្កល់ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីជនត្រូវចោទ អៀង ធីរិទ្ធ នៅដដែល ហើយសូមធ្វើសេចក្តីសន្និដ្ឋានសង្ខេបបន្ថែមដូចតទៅ៖

ការកាន់អំណាចរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីថ្ងៃទី១៧ មេសា ១៩៧៥ រហូត

ដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ បានធ្វើឲ្យប្រជាជនកម្ពុជាទូទាំងប្រទេសរាប់លាននាក់ទទួលនូវភាពអយុត្តិធម៌ អមនុស្សធម៌ និងទទួលទារុណកម្មគ្រប់បែបយ៉ាង ។ ទណ្ឌកម្មទាំងអស់នេះ បណ្តាលឲ្យប្រជាជនប្រហែលពីរលាននាក់ត្រូវបានបាត់បង់ជីវិត ចំណែកឯអ្នកនៅរស់រានមានជីវិតក៏ត្រូវបានទទួលរងនូវការឈឺចាប់ខ្លោចផ្សាភិតភ័យនិងបាក់ស្បាតផងដែរ អំពើទាំងនេះបានបន្សល់ទុកនូវក្មេងកំព្រា ជនពិការ និងស្ត្រីមេម៉ាយជាច្រើននាក់ គ្មានអ្នកជួយទំនុកបម្រុង ជាពិសេសបានបំផ្លាញចោលនូវរចនាសម្ព័ន្ធសង្គមកម្ពុជាទាំងស្រុង ហើយបន្ទុកទាំងនេះត្រូវធ្លាក់មកលើសង្គមកម្ពុជាបច្ចុប្បន្នជាអ្នកទទួលរ៉ាប់រង ។ ភ័ព្វសំណាងល្អ ដោយមិនចង់ឲ្យមាននិទ្ទណ្ឌភាពនៅក្នុងសង្គម ទើបរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានបង្កើតឲ្យមានតុលាការនេះឡើង ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងកម្ពុជាប្រជាធិប-តេយ្យកាន់អំណាច ។ រហូតមកទាល់ពេលនេះ តុលាការនេះបានធ្វើការកំណត់មុខសញ្ញាតាមរយៈការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលលម្អិតអំពីអង្គហេតុនានារបស់ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ និងបានចាប់ឃុំខ្លួនជនត្រូវចោទចំនួនប្រាំរូប ដែលជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាក់លាក់ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ។ នៅក្នុងនេះក៏មានជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធផងដែរ ។ ជនត្រូវចោទឈ្មោះ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមមាត្រា៥, មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ សម្រាប់រយៈពេលអតិបរមាមួយឆ្នាំ ។ ចាប់តាំងពីពេលនោះមក ជនត្រូវចោទបានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន ដោយសារទំហំធំនៃកិច្ចស៊ើបសួរភាពស្មុគស្មាញនៃអង្គហេតុនិងអង្គច្បាប់ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងបញ្ហាផ្សេងៗទៀតនោះ ។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានសម្រេចបន្តថិរវេលានៃការឃុំខ្លួនជនត្រូវចោទសម្រាប់ រយៈពេលអតិបរមាមួយឆ្នាំបន្ថែមទៀត ។

[១០:៣០:០៩]

អង្គបុរេជំនុំជម្រះជាទីគោរព! ដោយសារការពន្យារពេលវេលានៃការឃុំខ្លួននេះហើយ ទើបសហមេធាវីការពារក្តីជនត្រូវចោទ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការសម្រេចនេះ មកអង្គបុរេជំនុំជម្រះ ។ ដោយសហមេធាវីការពារក្តី បានស្នើសុំឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ និងស្នើសុំឲ្យកូនក្តីរបស់ខ្លួន ដោះលែងកូនក្តីរបស់

ខ្លួនដោយស្ថិតឲ្យនៅក្រោមលក្ខខណ្ឌទាំងឡាយសមហេតុផលដែលធានាដល់ការចោទប្រកាន់ ។ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី ក៏បានលើកនូវអំណះអំណាងមួយចំនួនរបស់ខ្លួនថា ដីកាសម្រេចបន្តចិរវេលាឃុំខ្លួនធ្វើឡើងដោយមិនសមមិនមានហេតុផលគ្រប់គ្រាន់ ។ ដីកាសម្រេចបន្តចិរវេលាឃុំខ្លួនមានព័ត៌មានមិនពិតជាច្រើន ។ សហចៅក្រមស៊ើបអង្កេតបានប្រើបទដ្ឋានមិនត្រឹមត្រូវ ។ សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទ ។ ដីកាសម្រេចបន្តចិរវេលាឃុំខ្លួនមិនបញ្ជាក់ពីហានិភ័យណាមួយដែលថា ជនត្រូវចោទអាចជះឥទ្ធិពលទៅលើសាក្សីនោះគ្មានភស្តុតាងមូលដ្ឋានច្បាស់លាស់ និងស្នើឲ្យអង្គបុរេជំនុំជម្រះដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យដោយមានលក្ខខណ្ឌ ។ នៅក្នុងករណីនេះ តំណាងអយ្យការយល់ឃើញថា ដីកាសម្រេចបន្តការឃុំខ្លួនធ្វើដោយសហចៅក្រមស៊ើបអង្កេតគឺ មានលក្ខណៈគ្រប់គ្រាន់នឹងសមល្មម ។ សហចៅក្រមស៊ើបអង្កេតបានលើកយកមកពិចារណាអំពីអង្គហេតុនិងអង្គច្បាប់ មុននឹងចេញដីកាសម្រេចបន្តឃុំខ្លួនលើជនត្រូវចោទ ។ សហចៅក្រមស៊ើបអង្កេតអាចអនុវត្តកាតព្វកិច្ចនេះ ដោយយោងទៅលើសំណុំរឿងនឹងកាលៈទេសៈទូទៅ និងកាលៈទេសៈដទៃទៀត ហើយសហចៅក្រមស៊ើបអង្កេតក៏មិនជាប់កាតព្វកិច្ចត្រូវបញ្ជាក់ពីកត្តានានាទាំងអស់នោះដែរ ។

[១០:៣២:១៤]

ដូចនៅក្នុងកថាខណ្ឌទី៦៤ ដល់ទី៦៦ នៃសាលដីកាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង សារី ។ អង្គបុរេជំនុំជម្រះបានកំណត់ថា សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចផ្ដល់ការយល់ឃើញរបស់ខ្លួនលើកត្តាទាំងអស់ឡើយ ។ ដោយសារកាតព្វកិច្ចនេះបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានបង្ហាញអង្គច្បាប់និងអង្គហេតុ ដែលត្រូវយកមកពិចារណាមុននឹងចេញសេចក្ដីសម្រេច ។ សហចៅក្រមស៊ើបអង្កេតអាចអនុវត្តកាតព្វកិច្ចនេះ ដោយយោងលើសំណុំរឿងក្នុងកាលៈទេសៈទូទៅ និងកាលៈទេសៈដទៃទៀត ។

ម្យ៉ាងទៀត ការបន្តចិរវេលានៃការឃុំខ្លួននេះ គឺមានលក្ខណៈសមស្របអាចទទួលយកបាន បើយើងពិនិត្យទៅមើលភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ភាពស្មុគស្មាញនៃសំណុំរឿងកម្រិតនៃការស៊ើបសួរកំពុងតែអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទបានប្រឈមមុខនឹងបទចោទជាច្រើន ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវនៃចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវក្នុងបណ្ដាញឧក្រិដ្ឋកម្មមានលក្ខណៈទូលំទូលាយនឹងជាប្រព័ន្ធ ។ វិធានផ្ទៃ

ក្នុងក៏បានអនុញ្ញាតឲ្យមានការបន្តឃុំខ្លួនជនត្រូវចោទផងដែរ ដោយផ្អែកលើកាលៈទេសៈនានានៃរឿងក្តី និងយុត្តិសាស្ត្រអន្តរជាតិ បើយើងពិនិត្យលើពីការវាយតម្លៃភាពសមស្របពីការឃុំខ្លួនបណ្តោះអាសន្ន តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី *អាយស៊ីធីវ៉ាយ* បានពិចារណាអំពីរយៈពេលនៃការឃុំខ្លួន ដែលមានរយៈពេលវែងជាងរយៈពេលសមស្របឆ្ងាយណាស់ ដោយយោងទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ។ យុត្តិសាស្ត្ររបស់តុលាការសហគមន៍អឺរ៉ុប ក្នុងករណី *ហាជីណាស់ តាស៊ី* ទល់នឹងប្រទេសក្រិច គឺជនត្រូវចោទត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ហើយពឹងផ្អែកទាំងស្រុងទៅលើអ្វីដែលបានឮនាពេលសវនាការ ដើម្បីរៀបចំបណ្តឹងឧទ្ធរណ៍របស់ខ្លួន ។ ពោលគឺមិនបានទទួលនូវសេចក្តីសម្រេច ដែលជាអត្ថបទពេញលេញទេ ។ ដូច្នេះ បើប្រៀបធៀបជាមួយករណីជនត្រូវចោទ អៀង ធីរិទ្ធ គឺខុសគ្នា ដោយសារតែជនត្រូវចោទ អៀង ធីរិទ្ធ បានទទួលនូវសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតពេញលេញដែលអនុញ្ញាតឲ្យគាត់មានសិទ្ធិបណ្តឹងឧទ្ធរណ៍ ។ ម្យ៉ាងវិញទៀត សេចក្តីសម្រេចបន្តចិរវេលាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត គឺបានបង្ហាញច្បាស់លាស់រួចទៅហើយនៅក្នុងកថាខណ្ឌទី២០ ទី២៧ ទី២៩ និងទី៣៤ ថាហេតុអ្វីបានជាត្រូវការឃុំខ្លួនជនត្រូវចោទ អៀង ធីរិទ្ធបន្តនោះ ?

[១០:៣៥:១៤]

ដូច្នេះ ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ គឺមិនមែនមិនសមស្របនោះទេ ។ ហេតុដូច្នេះបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ដែលថា ដីកាសម្រេចបន្តការឃុំខ្លួនមានការខ្វះខាតលើមូលហេតុ ដែលធ្វើការចោទប្រកាន់ទូទៅដោយមិនបានផ្តល់ប្រភពសម្រាប់ការចោទប្រកាន់នោះមិនត្រឹមត្រូវទេ ។ ចំពោះការលើកឡើងថា ដីកាសម្រេចបន្តការឃុំខ្លួនមានព័ត៌មានមិនពិតនោះ តំណាងអយ្យការពិនិត្យឃើញថា ដីកាសម្រេចបន្តការឃុំខ្លួននេះ មិនមានព័ត៌មានណាខុសទេ ។ ទាក់ទងទៅនឹងឯកសារលេខD៨៨ ដែលជាការសួរចម្លើយរបស់ជនត្រូវចោទក្នុងសំណុំរឿង០០១ ទោះបីជាឯកសារនេះ មិនបានចង្អុលចំឈ្មោះជនត្រូវចោទ អៀង ធីរិទ្ធ ក៏ដោយ ប៉ុន្តែវាជាការជាប់ទាក់ទងជាមួយជនត្រូវចោទគឺពិតជាមានយ៉ាងជាក់ស្តែង ព្រោះឯកសារនេះ បានបង្ហាញយ៉ាងច្បាស់លាស់ពីឈ្មោះក្រសួងសង្គមកិច្ច ដែលជាក្រសួងរបស់ជនត្រូវចោទកំពុងគ្រប់គ្រង ។ លើសពីនេះទៀត ឯកសារមួយទៀត គឺជាការស្តាប់ចម្លើយសាក្សីមួយរូបដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ។ សាក្សីនោះ បានបញ្ជាក់ថាបានបញ្ជាក់អំពីទំនាក់ទងរវាងជនត្រូវចោទនឹងមន្ទីរស-២១ ព្រមទាំងលទ្ធភាពរបស់ជនត្រូវចោទក្នុងការ

ទទួលបានចម្លើយសារភាពពីមន្ទីរស-២១ផងដែរ ។ ចំពោះការអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា ដីកាបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានផ្ទុកព័ត៌មានមិនពិត ទាក់ទងទៅនឹងសិទ្ធិស្តីពីការពិនិត្យមើលសំណុំរឿងរបស់ជនត្រូវចោទនោះមិនត្រឹមត្រូវទេ ។ ម៉្យាងវិញទៀត វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ បានផ្តល់សិទ្ធិដល់ភាគីនានាត្រូវទទួលបាននូវឯកសារគ្រប់យ៉ាងពីក្នុងសំណុំរឿង ដោយផ្ទាល់សម្រាប់សហព្រះរាជអាជ្ញា និងតាមរយៈមេធាវីការពារក្តីសម្រាប់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ ជនត្រូវចោទក៏ត្រូវទទួលបាននូវធាតុផ្សំទាំងអស់នៃសំណុំរឿងតាមរយៈសហមេធាវីការពារក្តីរបស់ខ្លួនហើយដែរ ។ បើយោងតាមវិធាន២២.៣ នៃវិធានផ្ទៃក្នុងចែងថា មេធាវីការពារក្តីដែលបានទទួលស្គាល់អាចទទួលបានច្បាប់ចម្លងនៃសំណុំរឿង ឬកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី និងយកឯកសារនេះ រួមជាមួយឯកសារដែលពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួន ។ បន្ថែមពីនេះទៀត វិធាន៩.២១ នៃវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង បានអនុញ្ញាតឲ្យសមាជិកក្រុមមេធាវី និងជនជាប់ឃុំបញ្ជូនឯកសារទៅវិញទៅមកក្នុងអំឡុងពេលជួបសួរសុខទុក្ខ ដោយអនុលោមទៅលើដីការបស់តុលាការ ។ លើសពីនេះទៀត កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចទាក់ទងនឹងសំណុំរឿងលេខ០០១ ដោយបានអនុញ្ញាតឲ្យមេធាវីការពារក្តី ធ្វើការផ្តល់ឲ្យជនជាប់ឃុំនូវឯកសារថតចម្លងនៃសំណុំរឿង ដោយមានលក្ខខណ្ឌកម្រិតមួយចំនួនពោលគឺធ្វើការផ្តល់ឯកសារដោយផ្ទាល់ដៃ និងយកត្រឡប់មកវិញនៅរៀងរាល់ល្ងាច ។ យោងតាមសេចក្តីសម្រេចនេះ មេធាវីការពារក្តីជនជាប់ឃុំក្នុងសំណុំរឿងលេខ០០២ ក៏ត្រូវបានអនុញ្ញាតឲ្យទទួលអត្ថប្រយោជន៍ទាំងនេះជាបណ្តោះអាសន្នផងដែរ ។

[១០:៣៩:០៦]

ដូច្នេះ វាច្បាស់ណាស់ថា ជនត្រូវចោទពិតជាទទួលបាននូវឯកសារគ្រប់យ៉ាងពីសំណុំរឿង រួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីជាក់លាក់ ក៏ដូចជាបណ្តឹងនិងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ លើកលែងតែសហមេធាវីការពារក្តីជនត្រូវចោទមិនបានទៅសួរសុខទុក្ខកូនក្តីរបស់ខ្លួន ឬមិនបានពិភាក្សាអំពីភស្តុតាងនៅក្នុងសំណុំរឿងជាមួយកូនក្តីរបស់ខ្លួន ឬក៏មិនបានធ្វើការទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួន ។ ម៉្យាងទៀត យើងគួរពិនិត្យមើលផងដែរ នូវការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតដើម្បីឆ្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តីកន្លងមក ដែលស្នើសុំឲ្យជនត្រូវចោទទទួលបាននូវឯកសារសំណុំរឿងនៅក្នុងមន្ទីរឃុំឃាំង គឺនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ។

សហចៅក្រមស៊ើបអង្កេតបានសុំឲ្យប្រធានមន្ទីរឃុំឃាំងពិនិត្យមើលថាតើឯកសារច្បាប់ចម្លងនៃសំណុំរឿងអាចទុកក្នុងបន្ទប់មួយដាច់ដោយឡែកនៃមន្ទីរឃុំឃាំង សម្រាប់ធ្វើការពិគ្រោះយោបល់ដោយមានការត្រួតពិនិត្យ ឬមួយក៏រក្សាទុកច្បាប់ចម្លងនៃឯកសារទាំងនោះនៅក្នុងទូដែលអាចចាក់សោបានសម្រាប់ជនជាប់ឃុំម្នាក់ៗនៅខាងក្នុង ឬខាងក្រៅបន្ទប់ឃុំខ្លួនរបស់ពួកគេបានដែរឬមួយយ៉ាង?

ជាលទ្ធផលនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ប្រធានមន្ទីរឃុំឃាំងបានឆ្លើយតបវិញថា មិនមានបន្ទប់នៅទំនេរទេ សម្រាប់ទុកដាក់ឯកសារច្បាប់សម្លងនៃសំណុំរឿង ។ ប៉ុន្តែ មានទូមួយចាក់សោរបានដោយមាន៤ថត សម្រាប់ទុកដាក់ឯកសារខ្លះៗនៃសំណុំរឿង អាចទុកក្នុងបន្ទប់ជនជាប់ឃុំម្នាក់ៗបាន ។ បន្ទាប់មកនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចស្ដីពីការមើលឯកសារដោយជនជាប់ឃុំ និងបានលើកឡើងថា ដោយសារនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានបន្ទប់មានទំហំធំអាចរក្សាទុកឯកសារនៃសំណុំរឿងទាំង មូលបាន និងភាពលំបាកសម្រាប់បុគ្គលផ្នែកគ្រប់គ្រងតុលាការក្នុងការធ្វើបច្ចុប្បន្នភាពឯកសារសំណុំរឿង ហើយក៏មិនអាចរក្សាឯកសារទាំងនោះឲ្យបានល្អគ្មានអ្នកណាប៉ះពាល់ ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ព្រមឲ្យមេធាវីការពារក្ដីជនជាប់ឃុំទាំងអស់ ជាអ្នកទទួលខុសត្រូវក្នុងការផ្ដល់ជូនដល់កូនក្ដីរបស់ខ្លួននូវឯកសារថតចម្លងនានានៃសំណុំរឿង និងសិទ្ធិក្នុងការទាក់ទងចាំបាច់សម្រាប់រៀបចំ ការការពារក្ដី ហើយនិងជាអ្នកយកឯកសារទាំងនេះត្រឡប់មកវិញ ។ មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតក៏បានអនុញ្ញាតឲ្យមានការផ្ដល់ទូសម្រាប់ដាក់ឯកសារ ដែលអាចចាក់សោបានទៅឲ្យជនជាប់ឃុំម្នាក់ៗ ដើម្បីទុកជាឯកសារទាំងនេះនៅក្នុងបន្ទប់របស់ខ្លួនសម្រាប់រយៈពេលយូរតាមការចាំបាច់ និងប្រើប្រាស់វាទាំងនៅក្នុងបន្ទប់ និងនៅពេលជួបជាមួយមេធាវីរបស់ខ្លួន ។ ហេតុដូច្នេះឃើញថា វាមិនត្រឹមត្រូវទេដែលសហមេធាវីការក្ដីបានអះអាងថាកង្វះខាតក្នុងការទទួលឯកសារសំណុំរឿងនោះ ។ ទាក់ទងនឹងការយកចិត្តទុកដាក់ហ្មត់ចត់ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនមែនគ្មានមូលហេតុនោះទេ ហើយក៏គ្មានកង្វះការយកចិត្តទុកដាក់ដោយសហចៅក្រមស៊ើបអង្កេតដែរ ។

[១០:៤២:៤៧]

បទដ្ឋាននៃការយកចិត្តទុកដាក់វិសេស ដូចដែលបានលើកឡើងដោយសហមេធាវីការពារក្ដីមិនចាប់ពាក់ព័ន្ធគ្នាទេនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះ ។ ដោយសារលក្ខណៈស្មុគស្មាញ ជាក់លាក់ និងចម្រុះនៃការស៊ើបសួរនៅក្នុងយុត្តាធិការរបស់ខ្លួន

បើយើងពិនិត្យទៅមើលករណីរបស់ *វេនហ្វ៊ិស* ទល់នឹងប្រទេសអាល្លឺម៉ង់ តុលាការសហគមន៍អឺរ៉ុ សម្រាប់សិទ្ធិមនុស្ស បានលើកឡើងថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នសម្រាប់រយៈពេល៣ឆ្នាំ គឺជាការសមស្របដោយសារភាពស្មុគស្មាញនៅក្នុងសំណុំរឿង និងដោយសារការពន្យារពេលមិនអាច ជៀសវាងបាននោះ រយៈពេលនៃការស៊ើបអង្កេត និងសវនាការត្រូវបានបង្ហាញថាគឺសមហេតុផល ។ ម្យ៉ាងទៀត ជនត្រូវចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងកំពុងត្រូវបាន ស៊ើបសួរអំពីថាបានរៀបចំផែនការញុះញង់ បញ្ជា ជួយជំរុញ បានប្រព្រឹត្ត ឬទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មផ្សេងៗដែលប្រឆាំងនឹងមនុស្សជាតិ ។ បន្ថែមពីនេះទៀត ជនត្រូវចោទត្រូវបានដាក់បញ្ចូលក្នុង បទចោទស្តីពីការប្រព្រឹត្ត ដែលជាការរួមចំណែករបស់ជនត្រូវចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ក្នុង ឋានៈជាសហចារីដែលបណ្តាលឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋជាក់ស្តែងជាច្រើននៅទូទាំងប្រទេសកម្ពុជា ហើយដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផងដែរ ។ បទឧក្រិដ្ឋ ទាំងនេះ គឺឋិតក្នុងចំណោមបទឧក្រិដ្ឋធ្ងន់ធ្ងរ និងស្មុគស្មាញ ហើយជនត្រូវចោទអាចប្រឈមមុខនឹងការជាប់ពន្ធនាគារអស់មួយជីវិតប្រសិនជាកាត់ឲ្យជាប់ទោស ។ រហូតមកដល់ពេលនេះ សហចៅក្រម ស៊ើបអង្កេតបានខិតខំធ្វើការស្វែងរកនូវភស្តុតាងនានា ហើយទទួលបាននូវភស្តុតាងដាក់បន្ទុកលើជនត្រូវចោទ ដែលជាហេតុធ្វើឲ្យមានការកើនឡើងទាំងទំហំនិងទាំងស្ថានទម្ងន់ ។ ជាក់ស្តែងសហចៅក្រមស៊ើបអង្កេតបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនសម្រាប់សំណុំរឿងលេខ០០២ ។ មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតខ្លួនឯង និងអ្នកស៊ើបអង្កេតរបស់ខ្លួនបានធ្វើការសម្ភាសន៍សាក្សីជាង១០០នាក់ ដែលទាក់ទងទៅនឹងជនត្រូវចោទទាំងអស់ក្នុងអំពើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ។ បន្ថែមពីលើនេះ ទៀត ឯកសារក្នុងសំណុំរឿងលេខ០០១ ដែលពាក់ព័ន្ធច្រើនទៅនឹងជនត្រូវចោទ អៀង ធីរិទ្ធ ត្រូវបាន ផ្ទេរទៅក្នុងសំណុំរឿងលេខ០០២រួចហើយដែរ ។ លើសពីនេះទៀត ការិយាល័យសហព្រះរាជអាជ្ញា ក៏បានចូលរួមចំណែកដល់ការស៊ើបសួរផងដែរ ដោយការដាក់ឯកសារភស្តុតាងជាច្រើនចាប់តាំងពីពេល ដាក់ដីកាសន្និដ្ឋានឲ្យស៊ើបសួរនិងពីពេលចាប់ខ្លួនជនត្រូវចោទរួចមក ។ ភស្តុតាងដែលសហចៅក្រម ស៊ើបអង្កេតប្រមូលបាន ក៏ដូចជាភស្តុតាងដែលបានដាក់បញ្ចូលតាមសំណើរបស់សហព្រះរាជអាជ្ញា គឺ គ្របដណ្តប់ទៅលើគ្រប់ទម្រង់ និងប្រភេទទាំងអស់នៃការចូលរួមចំណែករបស់ជនត្រូវចោទ នៅក្នុង ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលត្រូវចោទប្រកាន់ រួមមានភស្តុតាងដែលរកបានពីទីកន្លែងកើតហេតុនៃ បទល្មើស ភស្តុតាងដែលជាប់ទីកន្លែងកើតហេតុទៅនឹងរចនាសម្ព័ន្ធនៃការដឹកនាំ ដែលជនត្រូវបានអនុវត្ត

នូវសិទ្ធិអំណាចក្នុងការបញ្ជា ភស្តុតាងដែលគាំទ្រអំពីការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្ម រួមភស្តុតាងដែលគាំទ្រអំពីធាតុផ្សំនានាខាងយុត្តាធិការ ដូចជាអំពីវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលជាដើម ។

[១០:៤៦:៤០]

ម្យ៉ាងទៀត នៅក្នុងដីកាសម្រេចបន្តធិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតក៏បានលើកឡើងថាកិច្ចស៊ើបសួររបស់ខ្លួនមានការជឿនលឿន ចាប់តាំងពីសវនាការលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨មក ដោយសារតែភស្តុតាងថ្មីៗជាច្រើនបន្ថែមទៀតត្រូវបានប្រមូលរួច ។ ដូច្នេះ ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនៅការយកចិត្តទុកដាក់ហ្មត់ចត់របស់ខ្លួននៅក្នុងកិច្ចដឹកនាំ កិច្ចស៊ើបសួររបស់ខ្លួនហើយ ។

ទាក់ទងទៅនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបៈ សិទ្ធិនៅស្ងៀមមិនឆ្លើយតប ត្រូវបានការពារដោយច្បាប់ជាធរមាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាបទដ្ឋានអន្តរជាតិមួយដែលអង្គជំនុំជម្រះវិសាមញ្ញនេះត្រូវអនុវត្តតាម ។ បើយើងពិនិត្យមើលករណីរបស់ *អេកូល* ទល់នឹងប្រទេសអាល្លឺម៉ង់ បង្ហាញឲ្យឃើញថាតុលាការសហគមន៍អឺរ៉ុប នៅក្នុងករណីរបស់ *អេកូល* បានសម្រេចថាវាមានការរំលោភទៅលើមាត្រា៦នៃអនុសញ្ញាសហគមន៍អឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ដោយសារតែប្រភេទនៃការពន្យារពេលដំណើរការនីតិវិធីមិនសមរម្យនៅចំពោះតុលាការជាតិ ។ យ៉ាងណាក៏ដោយ តុលាការប្រទេសអាល្លឺម៉ង់បានធ្វើការសង្កេតដោយសេរីអំពីអង្គហេតុនោះ ដោយត្រឹមតែថាទង្វើផ្ទាល់ខ្លួនរបស់ *អេកូល* គឺជាការព្រួយបារម្ភប៉ុណ្ណោះ ។ ចំណែកឯ យុត្តិសាស្ត្ររបស់តុលាការសហគមន៍អឺរ៉ុបក្នុងករណី *វ៉ែនឌីឡូ* ទល់នឹងប្រទេសបារាំង បានគាំទ្រអំពីជំហររបស់សហចៅក្រមស៊ើបអង្កេត ។ តុលាការបានកត់សម្គាល់ថាអ្នកដាក់ពាក្យប្ដឹងក្នុងករណីនេះ បានបង្ហាញពីភាពរហ័សរហួនតិចតួចរបស់ខ្លួនក្នុងការដាក់សារណានៅចំពោះអាជ្ញាធរជាតិ ហើយតុលាការនេះបានបញ្ចប់សេចក្ដីសង្កេតរបស់ខ្លួនថា ដូច្នេះវាហាក់ដូចជាភាគីបានធ្វើអ្វីៗជាច្រើន ដើម្បីពន្យាពេលដំណើរការនីតិវិធីប៉ុណ្ណោះ ។

[១០:៤៨:៥២]

នៅក្នុងសេចក្ដីសម្រេចបន្តធិរវេលាឃុំខ្លួនសហចៅក្រមស៊ើបអង្កេតគ្រាន់តែបានលើកឡើងថា ការអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់ និងដែលមិនអាចប្រកែកបាន គឺមិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ ព្រោះតួនាទីរបស់សហចៅក្រមស៊ើប

អង្កេតគឺជាអ្នកប្រមូលភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។ ចំពោះភស្តុតាងដោះបន្ទុក គឺជនត្រូវចោទមានភារកិច្ចល្អប្រសើរជាងគេបំផុត ដើម្បីជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរក ។

ជាទូទៅ ក្នុងករណីមិនមានកិច្ចសហប្រតិបត្តិការពីជនត្រូវចោទនោះទេ ការស៊ើបសួរគឺចាំបាច់ត្រូវតែប្រើរយៈពេលយូរជាងការមិនដែលមិនមានជនត្រូវចោទជាអ្នកផ្តល់ភស្តុតាងនេះ ។ ម្យ៉ាងទៀត ដីកាសម្រេចបន្តការឃុំខ្លួន មិនបានរំលោភទៅលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនត្រូវចោទទេ ហើយសិទ្ធិនេះក៏ត្រូវទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតផងដែរ ។ ហេតុដូច្នេះ សូមស្នើដល់អង្គបុរេអង្គជំនុំជម្រះបដិសេធចោលនូវការលើកឡើងរបស់សហមេធាវីការពារក្តី ដែលថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ ។ ជាបន្តទៀត ខ្ញុំសូមអនុញ្ញាតឲ្យសហការីអន្តរជាតិរបស់ខ្ញុំ ដើម្បីធ្វើសេចក្តីសន្និដ្ឋានបន្ត សូមអរគុណ ។

[១០:៥០:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ បាទ, សូមអញ្ជើញបន្ត ។

**លោក វ៉ាំងសង់ ឌឺ វ៉ាលឌ៍ ដេស្សាងលេ៖**

លោកប្រធាន លោកចៅក្រមជាទីគោរព! មេធាវីការពារ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសារព័ត៌មាន គឺថាយើងមានការសង្ស័យទាក់ទងទៅនឹង ហើយនិងអ្នកស៊ើបអង្កេតមួយចំនួនអំពីការសម្រេចអនាគតនៅក្នុងការរៀបចំសវនាការ ទាក់ទងទៅនឹងការជំនុំជម្រះជនត្រូវចោទ៥រូបនៅក្នុងករណីទី២ ។ មូលដ្ឋានដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននៅប្រធាន-- ទាក់ទងទៅនឹងបញ្ហានិទ្ទណ្ឌភាព ហើយនិងការរង់ចាំការជំនុំជម្រះដ៏យូរ ។ ខ្ញុំសូមសម្តែងចំណុចមួយទៀត អំពីការសម្រេចជាផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត ដែលថា ការសម្រេចហ្នឹងគឺថាគាំទ្រដោយភាគីទាំងអស់ ហើយនឹងដំណើរនៅក្នុងអង្គជំនុំជម្រះហ្នឹង ហើយត្រូវតែអនុវត្ត ហើយនឹងត្រូវធ្វើឲ្យបានល្អនៅក្នុងវិធាន គោរពទៅតាមគោលការណ៍ពេលវេលា ហើយនិងគោរពសិទ្ធិរបស់មេធាវីការពារ ហើយយើងត្រូវចងចាំថាផលប្រយោជន៍ដែលថាការពិត ហើយនិងការពិតខាងតាមយុត្តិសាស្ត្រ ហើយត្រូវតែពិនិត្យហើយអាចនឹងមានលទ្ធភាពនៅក្នុងដំណើរការនេះ ហើយវាជាសារសំខាន់ណាស់សម្រាប់អនាគតប្រទេសជាតិ ហើយនិងយុត្តិធម៌កម្ពុជា ហើយនិងយុត្តិធម៌អន្តរជាតិផងដែរ ។

[១០:៥២:០៨]

បន្ទាប់អំពីបញ្ហាដែលទាក់ទងទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារ ខ្ញុំលើកឡើងលក្ខខណ្ឌ២ដែលកំណត់ឡើងនូវ២.២(ក) និង៦២.២(ខ) ដែលត្រូវបានគោរព-- ជាមូលហេតុដ៏សមស្របដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននៃជនត្រូវចោទដែលសម្រាប់គាំទ្រ ។ ខ្ញុំសូមសង្កត់ធ្ងន់អំពីអង្គហេតុថា ការពិនិត្យអំពីវត្តមាននៃលក្ខខណ្ឌទាំងពីរនោះ គឺបញ្ហាទាក់ទងទៅនឹងក្នុងការពិនិត្យនៃការឃុំខ្លួនបណ្តោះអាសន្នដោយសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គបុរេជំនុំជម្រះ ហើយនេះជាបញ្ហាដ៏សំខាន់ហើយដូចគ្នានេះដែរ យើងបានកត់សម្គាល់ថា មេធាវីការពារ ដែលបានផ្តល់ គឺថាមិនមែនជាលក្ខខណ្ឌថ្មីអ្វីនោះទេ ប៉ុន្តែជាបញ្ហាអង្គហេតុនិងអង្គច្បាប់ ដែលថាសហចៅក្រមស៊ើបអង្កេតបានពិនិត្យ ។

នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង ហើយនៅក្នុងការអះអាងនេះមិនមានទម្ងន់ទេ ហើយនិងដើម្បីស្នើរបស់ចៅក្រមស៊ើបអង្កេត ឬក៏បានច្រានចោលនោះមិនទំនងជាសមស្របទេនៅក្នុងដំណើរការនីតិវិធី ដែលថាមេធាវីការពារនោះយល់ច្រឡំអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះ គឺថាទាក់ទងទៅនឹងវិការៈនៃនីតិវិធី ។ ទាក់ទងនៅក្នុងវិសាលភាពនេះ គឺថាបណ្តឹងឧទ្ធរណ៍ចំពោះអង្គបុរេទាំងទងនឹងវិធានផ្ទៃក្នុង ហើយមូលហេតុរបស់ យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះនោះ គឺថាអង្គបុរេជំនុំជម្រះ ទី១) ពិចារណាអំពីសំណុំរឿងនៅក្នុងរឿងក្តីនៅក្នុងពេលសវនាការ គឺមិនមែនពេលដែលសហចៅក្រមស៊ើបអង្កេតពិនិត្យអង្កេតនោះទេ ហើយហ្នឹងគឺថាអាចនឹងពិនិត្យមើលនូវអ្វីដែលសហចៅក្រមស៊ើបអង្កេត ហើយនិងពិនិត្យមើលនូវកំហុសឆ្គងនៅក្នុងដំណើរការនីតិវិធី ហើយវាមានការឆ្គាំឆ្គងដែរទេ? ហើយនឹងគ្រាន់ថា យើងពិនិត្យឃើញថា បណ្តឹងឧទ្ធរណ៍របស់មេធាវីមិនមានខ្លឹមសារនោះទេ ។ ការសម្រេចនៃអង្គជំនុំជម្រះនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ននោះ ព្រមទាំងសេចក្តីសម្រេចទាក់ទងពីការពន្យារថិរវេលានៃការឃុំខ្លួននេះ ហើយយើងមានការយោងទៅការកន្លងទៅនៃពេលវេលាដើម្បីបញ្ជាក់មូលហេតុនៃមូលដ្ឋានដែលថា អង្គជំនុំជម្រះ ហើយចៅក្រមស៊ើបអង្កេតមិនត្រឹមត្រូវនោះទេ ។

[១០:៥៥:០២]

ប្រសិនបើ សហចៅក្រមស៊ើបអង្កេតពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដោយមិនបានពិនិត្យការជំទាស់របស់អគ្គមេធាវីការពារទេ ។ អ៊ីចឹងហើយបញ្ហាទាក់ទង ឬព័ត៌មានទាក់ទង គឺត្រូវផ្តល់មូលដ្ឋាន គឺមូលដ្ឋានដែលថាសហចៅក្រមស៊ើបអង្កេតនោះមានមូលដ្ឋាននៅក្នុងសេចក្តីសម្រេច ហើយនិងក្នុងរបស់ខ្លួនដែលមានមូលហេតុនោះ ។

ឥឡូវនេះខ្ញុំនឹងធ្វើការពិនិត្យមើលវិធាន៦៣.៣.ខ ហើយខ្ញុំមើល ខ្ញុំមិនស្នើឲ្យមានការសវនាការជាអសាធារណៈដោយសារយើងបានផ្តល់ឯកសារគ្រប់គ្រាន់ហើយនៅក្នុងសារណាលាយលក្ខណ៍អក្សរ ។

ខ្ញុំទាក់ទងទៅនឹងហេតុដែលយើងជឿជាក់ថា ដែលថាជនត្រូវចោទបានប្រព្រឹត្តបទល្មើសនោះ ។ អ៊ីចឹងហើយការស៊ើបអង្កេតនៅតែបន្តនៅឡើយ ។ ព័ត៌មានអង្គហេតុដែលបញ្ជាក់បង្ហាញថា ដែលថាជនត្រូវចោទ គឺថាជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានចែងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬក៏ត្រូវបានប្រព្រឹត្តបទល្មើស ឬក៏ថាបណ្តឹងឧទ្ធរណ៍មិនបានដាក់សេចក្តីសន្និដ្ឋានជាក់លាក់ទាក់ទងទៅនឹងមូលដ្ឋានឲ្យគ្រប់គ្រាន់ដែលជឿបានថា ។ ប៉ុន្តែ មិនបានវិភាគនូវភស្តុតាង នូវឯកសារស៊ើបអង្កេតដែលមានចែងនោះ គឺថាមេធាវីការពារបានការយោងដោយផ្ទាល់ គិតទៅភស្តុតាងមួយចំនួន គឺថា ការពន្យារថិរវេលានោះមិនមានភស្តុតាង ឬក៏គាំទ្រផ្ទាល់ទៅនឹងការចោទប្រកាន់នោះ ។ ហើយដែលគាំទ្រដោយសហចៅក្រមស៊ើបអង្កេត យើងពិចារណាថា ភស្តុតាងដែលបានបញ្ជូន និងគាំទ្រនៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ គឺវាមានគ្រប់គ្រាន់ ហើយបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលច្បាប់តម្រូវ ។

ទោះបីមួយឆ្នាំក្រោយហើយក្តី ភស្តុតាងទាំងអស់នេះវាសារសំខាន់ និងមានការគាំទ្រ ខ្ញុំមិនត្រឡប់ទៅរកភស្តុតាងដែលបានពិភាក្សារួចហើយ យូរហើយពីឆ្នាំមុននោះ ដែលថាទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ។ ប៉ុន្តែ គឺថាវាមានតម្លៃក្នុងការសង្កត់ធ្ងន់នូវភស្តុតាងមួយចំនួនដែលខ្ញុំបានលើកឡើងពីឆ្នាំទៅ វាគឺថាជាលក្ខណៈទូទៅ វាការចោទឡើងរបស់មេធាវីការពារ ដែលថាមេធាវី ដែលថាមិនមានការប្រុងប្រយ័ត្ននៅក្នុងការស៊ើបអង្កេតនោះ ។ ខ្ញុំក៏រំឭកឡើងថានៅថ្ងៃទី៩ ខែកក្កដា អង្គជំនុំជម្រះក៏បានបន្ទាប់ពីមានដំណើរការនីតិវិធីហើយនិងការវិភាគទៅលើឯកសារស៊ើបអង្កេតនៅថ្ងៃទី២១ ឧសភា ២០០៨ គឺថាមានមូលហេតុឲ្យយើងជឿថា ជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋដែលចោទ ដែលបានរងការចោទប្រកាន់ ។ គឺថាខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍នេះ គឺថាយើងមានបញ្ហាមួយចំនួន មូលហេតុដែលបញ្ជាក់នៅក្នុងអង្គជំនុំជម្រះនោះ ។ លើសពីនេះទៅទៀត ដូចសហសេវិករបស់ខ្ញុំបានបញ្ជាក់ពីខាងដើម ឯកសារស៊ើបអង្កេតកំពុងបន្ត គឺថាវាមានរឹងមាំជាងពីខែវិច្ឆិកា ឆ្នាំ២០០៨ ដែលថាជនត្រូវចោទត្រូវបានចាប់ខ្លួន ហើយយើងបានទទួលនូវភស្តុតាង ហើយគឺថាវាមានស្ថានទម្ងន់កាន់តែខ្លាំងពេលដែលយើងប្រមូលភស្តុតាង ហើយជាពិសេសនោះ គឺថាដីកាឃុំខ្លួន ចៅក្រមសហចៅក្រមស៊ើបអង្កេតបានចេញដីកាឲ្យស៊ើបសួរជំនួសជាច្រើន ។ ដីកាចាត់ឲ្យសួរជំនួសនេះគឺថាមាន គឺ

ថាប្រមូលបានលទ្ធផលមួយចំនួន ទាំងកំណត់ហេតុសួរចម្លើយសាក្សី ហើយនិងអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តដូចដែលសហព្រះរាជអាជ្ញា បានដាក់ជូនទៅនឹងតុលាការពីមុនមកហើយ ។

[១០:៥៨:០៧]

ភស្តុតាងពាក់ព័ន្ធនានា ទាក់ទងទៅនឹងសំណុំរឿងទីមួយត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងទីពីរ ទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី៣១ ខែ៥ ឆ្នាំ២០០៨ និងនៅថ្ងៃទី២៨ ខែ១០ ឆ្នាំ២០០៨ ផងដែរ ។ ហើយភស្តុតាងផ្សេងៗទាក់ទងទៅមន្ទីស-២១ ទាក់ទងទៅនឹង ឌុច ដែលបទសម្ភាសន៍នានាត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលជាចំណុចសំខាន់មួយទាក់ទងទៅនឹងជនត្រូវចោទ ។ ហើយចាប់តាំងពី មានភស្តុតាងជាច្រើន ហើយនិងបុគ្គលិកនៅក្រោមក្រសួងដែលគាត់បានធ្វើហ្នឹង ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ហើយត្រូវបានឃុំឃាំងខ្លួននៅទីនោះ ត្រូវបានសម្លាប់នៅទីនោះ ។

របាយការណ៍ គឺមានចំនួនភស្តុតាងគ្រប់គ្រាន់ទាក់ទងទៅនឹងចំណុចនេះ ទាក់ទងទៅនឹងតួនាទីរបស់ជនត្រូវចោទ នៅក្នុងការរៀបចំអ្នកធ្វើការនៅក្រោមបង្គាប់របស់គាត់នៅក្នុងការបញ្ជូនទៅមន្ទីរស-២១ ។ ហើយដែលតាមសារចម្លើយសារភាពដែលយើងមាន គឺទាក់ទងទៅនឹងការធ្វើទារុណកម្មនៅមន្ទីរស-២១ផងដែរ ។ ភស្តុតាងទាំងនេះ គឺជាការពិតដែលបានធ្វើឡើងទៅតាមសេចក្តីរាយការណ៍ដែលបានធ្វើឡើងដោយ ឌុច នៅក្នុងសំណុំរឿងទាំងពីរ ។

ចំណុចទីបី គឺខាងសហព្រះរាជអាជ្ញា ក៏បានផ្តល់នូវការភស្តុតាង ផ្តល់ភស្តុតាងជាច្រើនទាក់ទងទៅនឹងសំណុំរឿងនេះ ហើយនិងភស្តុតាងជាច្រើនត្រូវបានបញ្ចូលទាក់ទងទៅនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងចាប់តាំងពីធ្វើការចាប់ខ្លួនជនត្រូវចោទមកម្ល៉េះ ។ ទាក់ទងទៅនឹងចំណុចនេះ ខ្ញុំចង់ឲ្យពិនិត្យមើលទៅលើភស្តុតាងដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នៅក្នុង*ហ្វូតណូត* លេខ៨០ ដែលរួមបញ្ចូលទាំង ខ្ញុំមិនចង់និយាយព័ត៌មានសម្ងាត់នៅពេលនេះទេ គឺទាក់ទងនឹងបទសម្ភាសន៍រវាងជនត្រូវចោទរវាង *អេលីហ្សាប៊េត បេកឃ័រ* កាលពីឆ្នាំ៨០ ហើយនិងមានអត្ថបទសារព័ត៌មានប្រហែលជាជាង ៥០០ ទាក់ទងទៅនឹងការចោទប្រកាន់ទៅលើជនត្រូវចោទនេះ ហើយនិងលំដាប់កាលប្រវត្តិនៃការចោទប្រកាន់ផ្សេងៗមកលើជនត្រូវចោទ មុនពេល និងក្នុងកំឡុងពេល និងបន្ទាប់ពីពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញថា គឺមានការបន្ត និងជម្រៅនៃការប្រព្រឹត្តិរបស់កម្ពុជារបស់ខ្មែរក្រហម ។

[១១:០១:២០]

យើងក៏បានបញ្ចូលផងដែរនូវបញ្ជីឈ្មោះជនជាប់ចោទនៅក្នុងមន្ទីរស-២១ដែលបង្ហាញថា មនុស្ស រាប់រយនាក់ស្ថិតនៅក្រោមអំណាចរបស់ក្រសួងសង្គមកិច្ចហ្នឹងឯងត្រូវបានឃុំខ្លួន ត្រូវបានធ្វើ ទណ្ឌកម្ម និងសម្លាប់នៅមន្ទីរនោះ ។ ហើយកាលពីថ្ងៃទី១៨ ខែ៥ ឆ្នាំ២០០៨ ឯកសារដែលខ្ញុំបាននិយាយ ហ្នឹងឯង គឺឯកសារដែលបានធ្វើឡើងកាលពីខែ៥ហ្នឹងឯង គឺខ្ញុំនិយាយអំពីចំណុចសំខាន់មួយ គឺបទសម្ភាសន៍សំខាន់ មួយដែលបានបញ្ជាក់ថា ចម្លើយសារភាពរបស់សមាជិក ឬរបស់បុគ្គលិកនៃក្រសួងសង្គមកិច្ច ដែលគេ បានទទួលនៅមន្ទីរស-២១ហ្នឹង គឺត្រូវបានបញ្ជូនទៅឲ្យជនត្រូវចោទរួចហើយ ។

ឥឡូវទាក់ទងទៅនឹងដំណើរការស៊ើបអង្កេត របស់ខាងសហចៅក្រមស៊ើបអង្កេតមកដល់ពេល នេះ គឺមានការប្រមូលចំនួនបទសម្ភាសន៍ចំនួន២៨៦ ទាក់ទងទៅនឹងបទឧក្រិដ្ឋកម្មដែលជនត្រូវចោទទាំង ប្រាំនាក់ ត្រូវបានចោទប្រកាន់នោះ ដែលថាប្រព្រឹត្ត បានប្រព្រឹត្តនៅក្នុងសំណុំរឿងទីពីរ គឺជាឯកសារ ដែលមានចំនួនកើនឡើងដ៏ច្រើនបំផុត ហើយយើងអាចធ្វើការទាត់ចោលទេដូចថាខាងក្រុមមេធាវីការពារ ក្តីបានលើកឡើងនោះ ។ ចំនួនឯកសារជាច្រើន បទសម្ភាសន៍ជាច្រើនទាំងអស់ហ្នឹង ដែលទាំងអស់ហ្នឹង គឺពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានលើកឡើង ។

ដូច្នេះ វាពាក់ព័ន្ធទៅក្នុងសំណុំរឿងនេះ ហើយទាក់ទងទៅនឹងអ្វីដែលខាងមេធាវីការពារក្តីបាន លើកឡើង ហើយខាងសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការងារយកចិត្តទុកដាក់ក្នុងការស៊ើបអង្កេត របស់ខ្លួននោះ ។ ប៉ុន្តែ ព័ត៌មាននេះគឺជាព័ត៌មានដែលត្រឹមត្រូវ ដែលគេបានប្រមូលនៅក្នុងអំឡុងពេលនេះ ហើយទាក់ទងទៅនឹងការឆ្លើយតបទៅនឹងបណ្តឹងនោះ យើងបានផ្តល់នូវបញ្ជីចម្លើយបទសម្ភាសន៍ជាច្រើន ទាក់ទងទៅនឹង អៀង ធីរិទ្ធ គឺនៅហ្វូតណូត លេខ៨៣ ហើយក្នុងចំណោមបទសម្ភាសន៍ ១៦៧ ដែល ត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ដោយអនុវត្តទៅតាមដីកាឲ្យចាត់ការឲ្យស៊ើបសួរជំនួសនោះឯង។

មានព័ត៌មានផងដែរទាក់ទងទៅនឹងតួនាទីរបស់ជនត្រូវចោទ ដែលគាត់បានប្រព្រឹត្តទៅនៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ហើយខាងមេធាវីការពារក្តីបានលើកឡើងថា ចម្លើយសារភាពថ្មីៗទាំងនោះ និងភស្តុតាងដែលជាឯកសារ ឬក៏ជាវីដេអូ គឺមិនមែនចំណែកទាក់ទងពាក់ព័ន្ធផ្ទាល់នោះទេ ។ ហើយ តួនាទីរបស់គាត់នៅក្នុងបទឧក្រិដ្ឋក្នុងករណីទាំងនោះទេ ។ ហើយដូច្នេះគាត់ចង់លើកអំពីបញ្ហាឧក្រិដ្ឋកម្ម ផ្សេងៗដែលបានកើតឡើងនៅក្នុងទូទាំងប្រទេសនោះ ហើយនិងនៅក្នុងអ្វីដែលយើងដាក់នូវការសន្និដ្ឋាន បញ្ជូនរឿងបន្ថែមនោះ ។

ដូច្នេះ មិនមែនជាការចាំបាច់ក្នុងការពិនិត្យមើលទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ខ្លួន ឬក៏ការ

ទទួលស្គាល់ផ្ទាល់ខ្លួននោះទេ ។ ប៉ុន្តែយើងអាចពិនិត្យមើលទៅលើការបញ្ជាឲ្យប្រព្រឹត្ត ឬធ្វើជាសហចារី ឬក៏ជាអ្នកទទួលខុសត្រូវទៅលើបទឧក្រិដ្ឋក្នុងនាមយើងជាអ្នកបញ្ជា ឬក៏ជាអ្នកមានឋានៈខ្ពស់គឺទាក់ទងទៅនឹង គឺមាត្រាទី២៩ នៃច្បាប់អ.វ.ត.ក ។ យើងក៏អាចចូលរួមនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដោយចូលជាសហឧក្រិដ្ឋកម្មរួម ហើយនេះគឺជាករណីដែលយើងបានលើកឡើងនៅពេលនេះ។ គួរតែពិនិត្យឡើងដែលថាភស្តុតាងដែលបានប្រមូលឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេតមកដល់ពេលនេះ គឺពាក់ព័ន្ធទៅក្នុងចំណុចនេះ ហើយមានពាក់ព័ន្ធទៅនឹងជនត្រូវចោទ ។

[១១:០៤:៥២]

លើសពីនេះទៅទៀត យើងគួរតែធ្វើការសង្កត់បញ្ជាក់ផងដែរនៅក្នុងសំណុំរឿងបែបនេះ គឺជារឿងដែលមានស្មុគស្មាញ ហើយថា សហចៅក្រមស៊ើបអង្កេតហ្នឹង គឺបានប្រើឆន្ទានុសិទ្ធិរបស់គាត់ទាក់ទងទៅនឹងរបៀបនៃការធ្វើការស៊ើបអង្កេតរបស់ពួកគាត់ ។ ហើយគាត់ហ្នឹងគឺជាស្ថាប័នតែមួយគត់ក្នុងការដែលបញ្ចេញយុទ្ធសាស្ត្រ ក្នុងការប្រើ ក្នុងការទាក់ទងការធ្វើការស៊ើបអង្កេតរបស់ខ្លួន ដើម្បីឲ្យបានច្បាស់លាស់ ហើយដោយយកចិត្តទុកដាក់ផងដែរដោយមិនយកចិត្តទៅលើចំណុច ឬក៏ផ្នែកណាមួយនោះទេ ។ អ៊ីចឹងតម្រូវការនៃការធ្វើការឲ្យបានលឿន ឬមានប្រសិទ្ធភាពនោះ គឺថាត្រូវធ្វើការបង្រួបបង្រួមទៅលើកាតព្វកិច្ចរបស់ចៅក្រមផងដែរនៅក្នុងការស៊ើបអង្កេតទៅលើអង្គហេតុផ្សេងៗទាក់ទងទៅនឹងអង្គហេតុទាំងឡាយដែលបានលើកឡើង និងទៅលើខាងផ្នែកផ្សេងៗគឺទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ។ ទាក់ទងទៅនឹងរបៀបដែលពួកគាត់បានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតនោះ គឺមិនមែនជាបញ្ហាដែលថាសហព្រះរាជអាជ្ញាធ្វើនោះទេ ។ ប៉ុន្តែ គឺជាគោលការណ៍ដែលខាងសហចៅក្រមស៊ើបអង្កេតគាត់ជាអ្នកធ្វើ ទាក់ទងទៅនឹងអំពើឧក្រិដ្ឋអស់ទាំងនោះ ពួកគេគួរតែប្រមូលនូវភស្តុតាងដែលថាតើឧក្រិដ្ឋកម្មហ្នឹងពិតជាបានកើតមែនឬក៏យ៉ាងណា? ប៉ុន្តែ ពួកគេក៏ត្រូវប្រមូលភស្តុតាងផងដែរទាក់ទងទៅនឹងផ្នែកណាមួយ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនត្រូវចោទត្រូវបានចោទប្រកាន់នោះ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងភស្តុតាងទាក់ទងទៅនឹងការវាយលុកជាប្រព័ន្ធ ឬក៏មានក៏លក្ខណៈជាទូលំទូលាយមកលើជនស៊ីវិល ។

ដូច្នេះ គឺអាស្រ័យទៅលើខាងសហចៅក្រមស៊ើបអង្កេតក្នុងការប្រមូលភស្តុតាងនានាទាក់ទងទៅនឹងឧក្រិដ្ឋកម្មអស់ទាំងនេះ ហើយនិងទៅលំដាប់លំដោយនៃការគ្រប់គ្រងខាងអំណាចនៃកម្ពុជាប្រជាធិបតេយ្យដែលជនជាប់ចោទហ្នឹងគឺមានតួនាទីដ៏សំខាន់នៅក្នុងនោះ ។ ទាក់ទងទៅនឹងទំហំនៃឧក្រិដ្ឋកម្មដែល

បានប្រព្រឹត្តនៅទូទាំងប្រទេសនោះ ក្នុងរយៈពេលដ៏វែងអន្លាយបែបនេះ និងដែលពិចារណាទៅលើជនរងគ្រោះជាច្រើន និងសាក្សីជាច្រើនដែលបានប្រព្រឹត្តឡើងនោះ គឺយុទ្ធសាស្ត្រដែលខាងសហចៅក្រមស៊ើបអង្កេតប្រើក្នុងការប្រមូលនោះគឺជាឆន្ទានុសិទ្ធិរបស់គាត់ ។

ដូច្នេះហើយគឺថា យើងមិនអាចនិយាយបានថា មិនមានការយកចិត្តទុកដាក់ត្រឹមត្រូវពីខាងគាត់នោះទេ ។ ទោះបីជាការយកចិត្តទុកដាក់ហ្នឹងធម្មតា ឬក៏ពិសេសដូចដែលខាង មេធាវីការពារក្តីបានលើកឡើងក៏ដោយនោះ ។

ដូច្នេះ មកដល់ពេលនេះ គឺថាខាងមេធាវីការពារក្តីបានខកខានមិនបាននិយាយនូវអ្វីដែលជាការយកចិត្តទុកដាក់ជាពិសេសនោះទេ ។

[១១:០៧:៣០]

តាមពិតទៅការស៊ើបអង្កេតនោះ នៅតែបន្តរហូតដល់ឆ្នាំ២០០៨ ហើយលោកចៅក្រមនឹងបានឃើញថាបទសម្ភាសន៍ផ្សេងៗដែលបានប្រមូលរៀងរាល់ខែនោះ ហើយត្រូវបានបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ ។ នេះជាចំណុចត្រឹមត្រូវផងដែរ ទៅតាមដែលខ្ញុំយល់ដែលថា សហចៅក្រមស៊ើបអង្កេតបានផ្តោតយកចិត្តទុកដាក់នៅក្នុងរយៈពេលប៉ុន្មានខែទៅមុខទៀត ទៅលើក្នុងការបង្កើនការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ បាទមកលើជនដែលត្រូវចោទនីមួយៗ ទាក់ទងទៅនឹងលក្ខខណ្ឌផ្សេងទៀតដែលទាក់ទងទៅនឹងវិធាន៦៣.៣នោះ ដែលខ្ញុំលើកឡើងនោះ គឺក្នុងការឆ្លើយតបទៅនឹងការឆ្លើយនោះ ការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ គឺជាវិធានការចាំបាច់ទាក់ទងទៅនឹងវិធាន៦៣.៣(ខ) លោកនៅចាំដែរថានៅក្នុងការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ទាក់ទងទៅនឹងលក្ខខណ្ឌទាំងប្រាំដែលមានចែងនៅក្នុងវិធាននោះ ដែលបានកើតមានឡើងកាលពីថ្ងៃទី២១ឆ្នាំទៅនោះ ។ ការលើកឡើងពីទឡ្ហីករណ៍ទាំងនោះបានលើកឡើងហើយ ខ្ញុំមិនចង់លើកឡើង ពន្យល់ពីអ្វីដែលបានលើកឡើង ឬក៏បានតវ៉ាកាលពីមុនមកនោះទេ ។ ប៉ុន្តែ ខ្ញុំចង់ឲ្យអស់លោក លោកស្រី យកចិត្តទុកដាក់ទៅលើចំណុចលក្ខខណ្ឌបី ទាក់ទងទៅនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៦៣.៣(ខ)៖

ចំណុចទីមួយគឺថា ខាងមេធាវីការពារក្តីមិនបានធ្វើការតបតវ៉ាទៅនឹងអាទិភាពនៃចំណុចទាំងប្រាំនេះទេ គឺចំណុចទីពីរ ទីបី នៃលក្ខខណ្ឌទាំងនោះ គឺទាក់ទងទៅនឹងតម្រូវការនៃតម្រូវការឃុំឃាំងខ្លួនបណ្តោះអាសន្នដើម្បីរក្សានូវភស្តុតាង ឬក៏ចៀសវាងការបំផ្លាញទៅលើភស្តុតាង ដើម្បីធានាថាជនត្រូវចោទមានវត្តមាននៅមុខតុលាការ ។

ដូច្នេះហើយ ដូចដែលខាងមេធាវីការពារក្តីមិនបានធ្វើការតវ៉ាទៅលើតម្រូវការនៃការបន្តការឃុំខ្លួនបណ្តោះអាសន្នទៅលើមូលហេតុទាំងបីនេះទេ ហើយដោយមិនមានវត្តមាននៃការតវ៉ាក្នុងការផ្តល់ហេតុផលដែលខាងអង្គបុរេជំនុំជម្រះបានរៀបចំឆ្លើយតបនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពីខែ៧ឆ្នាំទៅនោះ ។ បើសិនជាខ្ញុំមិនបាននិយាយអំពីចំណុចនេះទេ គឺថាខ្ញុំមិនបំពេញតួនាទីរបស់ខ្ញុំទេ គឺខ្ញុំចង់លើកឡើងដើម្បីអះអាងទៅលក្ខខណ្ឌដែលខ្ញុំបានលើកឡើងកាលពីមុនមកនោះ ។

[១១:១០:០០]

កាលៈទេសៈទីពីរដែលខ្ញុំចង់លើកនេះ ខាងមេធាវីការពារក្តីបានធ្វើការតវ៉ាតែទៅលើចំណុចតែមួយប៉ុណ្ណោះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់គេ គឺមេធាវីការពារក្តីបានលើកឡើងថា នៅក្នុងការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នដែលខាងសហចៅក្រមស៊ើបអង្កេតបានធ្វើហ្នឹង គឺថាខាងសហចៅក្រមមិនបានបង្ហាញអំពីហានិភ័យពិតប្រាកដដែលអាចកើតឡើងនៅពេលដែលជនត្រូវចោទត្រូវបានដោះលែងដោយអត់មានឥទ្ធិពលទៅលើសាក្សីនោះ ។

នៅក្នុងសេចក្តីសម្រេចរបស់លោក កាលពីខែ៧ លោកបានលើកឡើងថា ចំណុចទាំងប្រាំទាក់ទងទៅនឹងវិធាននេះឯង គឺថាត្រូវយកមកពិចារណាឡើងវិញ ។ ហើយថាតើ ចំណុចទាំងប្រាំហ្នឹងត្រូវបានបំពេញ ឬក៏អត់នោះ?

នេះគឺជាលក្ខខណ្ឌដែលទាក់ទងទៅនឹងសុវត្ថិភាពរបស់ជនត្រូវចោទ ។ ហើយខាងមេធាវីការពារក្តីមិនបានធ្វើអធិប្បាយទៅលើចំណុចទាំងនេះទេ ដោយហេតុថាមានភស្តុតាងថ្មីទៀត ដែលត្រូវពិចារ-ណាហើយមានន័យថា ឥឡូវនេះដោយហេតុភស្តុតាងថ្មីហ្នឹង គឺលក្ខខណ្ឌទាំងអស់ហ្នឹងត្រូវបានបំពេញ ។ គឺថាមានភស្តុតាងថ្មី គឺវាអាស្រ័យទៅលើអាកប្បកិរិយារបស់ជនត្រូវចោទ ទាក់ទងទៅនឹងសវនាការអសាធារណៈដែលបានកើតឡើងមកពីមុន កាលពីខែ៥នោះ ហើយនិងកាលពីខែ៧ឆ្នាំ២០០៨ ផងដែរ ។ ហើយនិងក៏ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍ ហើយនិងអាកប្បកិរិយារបស់ជនរងគ្រោះ និងជនដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតមានឡើងនៅពេលធ្វើសន្និសីទក្រោយពីសវនាការបានបញ្ចប់កាលពីរយៈពេលកន្លងមកនោះ ។

គឺទាក់ទងទៅនឹងសិទ្ធិបកប្រែ ហើយពេលនុ៎ងឯងគឺជនរងគ្រោះហ្នឹង ខឹងសម្បាទាក់ទងទៅនឹងចំណុចនេះ ហើយនិងមានការកង្វល់ក្នុងចិត្តជ្រាលជ្រៅ ដែលជាការពិនិត្យឲ្យយើងឃើញទៅលើទាក់ទងទៅនឹងបញ្ហាសន្តិសុខរបស់ជនត្រូវចោទផងដែរ ។

ដំបូងខ្ញុំចង់និយាយត្រឡប់ទៅវិញ ទៅលើអាកប្បកិរិយារបស់ជនត្រូវចោទ ទាក់ទងទៅនឹងអ្នកដែលចូលរួមនៅក្នុង-- ដើមបណ្តឹងរដ្ឋប្បវេណី គូភាគីពាក់ព័ន្ធ ហើយនិងចៅក្រមដែលគាត់បានប្រព្រឹត្តនៅពេលសវនាការកាលពីលើកមុននោះ ។

គឺពួកគាត់បាន-- ជនត្រូវចោទហ្នឹងហើយបានធ្វើការស្រែកមកខាងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងនិយាយ ។ នេះហើយគឺជាការលើកឡើងធ្វើឲ្យខាងប្រធានចៅក្រមហ្នឹងឯង ប្រធានតុលាការបានធ្វើការព្រមានដើម្បីឲ្យជនត្រូវចោទហ្នឹងឯង ត្រូវស្ងៀមស្ងាត់ បើមិនអ៊ីចឹងទេនឹងត្រូវដកចេញពីបន្ទប់សវនាការ ។

[១១:១២:៣៥]

ការរំខានគ្រាន់តែកើតឡើងញឹកញាប់បែបនេះ ដែលបានធ្វើឡើងនៅក្នុងសវនាការអសាធារណៈនោះ នៅខណៈដែលជនត្រូវចោទ មិនត្រូវបានអញ្ជើញឲ្យធ្វើការថ្លែងការណ៍នោះទេ ជាការបង្ហាញថាជនត្រូវចោទហ្នឹងមិនអាចទទួលយកបាន ក្នុងការប្រឈមមុខទល់ជាមួយនឹងជនរងគ្រោះនោះទេ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅនៅក្នុងរបបនោះ ដែលគាត់ជាផ្នែកមួយនៃរបបនោះ ។ ហើយមានន័យថាអ្វីដែលគាត់ធ្វើ គឺវាហួសពីតួនាទីនៅក្នុងរបបនោះឯង ។

នៅក្នុងអំឡុងពេលនៃសវនាការកាលពីខែ៥ ឆ្នាំ២០០៨ហ្នឹងឯង ជនត្រូវចោទបានព្យាយាមធ្វើការគំរាមកំហែង ឬក៏សម្លុតមកលើខាងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ នេះគឺមិនមែនជាអំពើដែលកើតមានឡើងភ្លាមៗនោះទេ ទាក់ទងទៅនឹងអ្វីដែលជាការពិត ដែលគាត់មិនចង់ទទួលនោះ ហើយនិងការចោទប្រកាន់ទៅលើបទឧក្រិដ្ឋ ។ នេះគឺជាអ្វី? ជាអត្តចរិតផ្ទាល់របស់គាត់។ គាត់ជាស្ត្រីម្នាក់នៅក្នុងរបបខ្មែរក្រហម ហើយនេះគឺព្យាយាមលើកទីមួយក្នុងបានបញ្ចេញអំណាចឥទ្ធិពលមកលើអ្នកដែលព្យាយាមធ្វើការបកស្រាយទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនោះ ហើយក្នុងការបដិសេធរបស់គាត់ទៅលើឧក្រិដ្ឋដែលបានកើតឡើង ហើយទាក់ទងនឹងឧបទ្ទវហេតុដែលបានកើតឡើងក្នុងពេលសវនាការមុនៗនោះ ដែលធ្វើឡើងកាលពីខែ៧ឆ្នាំទៅ គឺការចោទប្រកាន់របស់គាត់គឺការព្យាយាមធ្វើការគំរាមកំហែង និងអ្វីដែលគាត់បានធ្វើហ្នឹងគឺមានការចុះផងដែរនៅក្នុងសារព័ត៌មានទាក់ទងទៅនឹងការវាយប្រហារទៅលើលោក យុ ឆាំង ។

[១១:១៤:២៩]

ខ្ញុំសូមបន្ថែមថា ការជំនុំជម្រះនៅក្នុងថ្ងៃ៩ កក្កដា នៅក្នុងសេចក្តីសម្រេចសវនាការសាធារណៈ

នោះខ្ញុំដឹងថា អ្នកទាំងអស់នេះ កត្តាទាំងអស់នេះក៏គប្បីតែពិចារណាថា អង្គជំនុំជម្រះនឹងវាយតម្លៃភាពគ្រោះថ្នាក់ជាក់លាក់ ដែលថាជនត្រូវចោទអាចនឹងដាក់សម្ពាធទៅលើជនរងគ្រោះ សាក្សី ប្រសិនបើឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ។ គាត់អាចនឹងបញ្ជា ឬក៏-- នេះជាបញ្ហាមួយ ឬក៏ដោយប្រយោលតាមរយៈសេចក្ដីថ្លែងការណ៍តាមសារព័ត៌មាន ឬក៏តាមរយៈសមាជិកក្រុមក្រុមគ្រួសាររបស់គាត់ ដែលថាមានតំណែងខ្ពស់នៅក្នុងប៉ៃលិន ជាអភិបាលនោះដែរ ។

ពិចារណាក្នុងរឿងអតីតកាលរបស់គាត់ និងគឺអានុភាពបច្ចុប្បន្នរបស់គាត់ នៅក្នុងអតីតខ្មែរក្រហម នៅក្នុងគ្រឿងម៉ាស៊ីនខ្មែរក្រហមហ្នឹង គឺថាវាមានជំងឺបាក់ស្បាតជាច្រើនចំពោះអ្នកនៅរស់រានមានជីវិត ។ ដូច្នេះ យើងមានមូលហេតុគ្រប់គ្រាន់និយាយថា នោះគឺថាជាការវត្តមានរបស់គាត់នៅក្នុងសង្គមគឺថា ដូចដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ហើយ គឺថាគាត់មានប្រវត្តិក្នុងសារព័ត៌មានធំធេងគឺថាអាចនឹងបង្ហាញការគំរាមកំហែងទៅដល់ភាគីដទៃទៀតចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ហើយនិងអ្នកដទៃទៀតដែលជិតស្និតនឹងនាងតាំងពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ដែលបានរួចរស់ជីវិតនោះដែលអាចផ្ដល់ព័ត៌មាន ដែលទាក់ទងទៅនឹងការពាក់ព័ន្ធរបស់គាត់ នៅក្នុងបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងប្រទេស និងនៅ ស-២១ គឺថាអាចនឹងប៉ះពាល់ដល់នីតិវិធីរបស់អ.វ.ត.ក ។

[១១:១៦:១៧]

ដូចដែលសហសេវិកខ្ញុំបានលើកឡើងគឺថា លទ្ធភាពរបស់ជនជាប់ចោទក្នុងការពិនិត្យសំណុំរឿងគឺថាជាច្រើនឆ្នាំមកហើយ ដើម្បីសាក្សីសំខាន់ៗដែលផ្ដល់សក្ខីកម្ម ដែលថា សំខាន់ក្នុងការដោះស្រាយនៅក្នុងដំណើរការស៊ើបអង្កេត ហើយនិងការជំនុំជម្រះ ។ ហើយនៅពេលដែលមេធាវីការពារនិយាយថាមិនមានសាក្សីណាមួយដែលបានបញ្ជាក់អំពីការភ័យខ្លាចទាក់ទងទៅនឹងការបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ននៃជនត្រូវចោទទេ ។ ប៉ុន្តែ ខ្លួនមិនបានលើកឡើងនូវ គេហៅថាសាក្សីផ្ទាល់មួយចំនួនមិនទាន់បានសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេតនៅឡើយទេ ។

មេធាវីការពារបានបញ្ជាក់នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនថា យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអន្តរជាតិ គឺថាមាននិយាយថា ហានិភ័យសម្ភាសន៍ទៅលើសាក្សី គឺត្រូវបានកាត់បន្ថយក្នុងការដំណើររឿងក្ដីវិវឌ្ឍន៍ទៅមុខ ។ ហើយកំណត់ហេតុសាក្សីត្រូវបានប្រមូល ។ ហើយខ្ញុំគឺថាលើកឡើងនៅក្នុងប្រទេសបារាំង ដូចនៅក្នុងរឿងក្ដី *ប៉ែលហ្ស៊ីម* បញ្ជាក់នៅកថាខណ្ឌ៦២ នៃបណ្ដឹងឧទ្ធរណ៍ ។

ក្រៅពីការរក្សាសិទ្ធិនូវអ្វីៗ នូវសេចក្ដីយោងមួយចំនួន នៅក្នុងយុត្តិសាស្ត្រមួយចំនួន នៅក្នុងរឿងក្ដីនេះ ហើយយើងគួរសង្កត់ថា មេធាវីមិនបាននិយាយទេថា កំណត់ហេតុជាច្រើនត្រូវបានប្រមូលនៅក្នុងរឿងក្ដីទីពីរ ដែលថាសាក្សីទាំងអស់ ដែលថាស្ថិតនៅក្រោមអតីតក្រសួងសង្គមកិច្ចនោះ គឺសាក្សីនោះគប្បីត្រូវបានសម្ភាសន៍ជាញឹកញាប់នៅក្នុងការសម្រេចនោះគឺថា តុលាការសិទ្ធិមនុស្សបានសម្រេចថា ការគាបសង្កត់លើសាក្សីត្រូវបន្តរហូតទាល់តែបានសម្ភាសន៍ជាច្រើនដងរួចមកហើយសិន ។

មេធាវីការពារក៏បានធ្វើសេចក្ដីយោងទៅរឿងក្ដី *ឡាប៊ីតា* សាលក្រមរបស់អ៊ីតាលីនៅក្នុងតុលាការសិទ្ធិមនុស្សអន្តរជាតិ គឺហានិភ័យនៃការដាក់សម្ពាធទៅលើសាក្សី ដោយសារកាលៈទេសៈមួយចំនួននោះវាខុសគ្នាពីករណីយើង ។ លោក *ឡាប៊ីតា* នោះគឺត្រូវបានសង្ស័យជា-- ស្ថិតនៅក្នុងក្រុមម៉ាសព្យ៉ា ដែលថាគេបានប្រមូលហេតុពីសាក្សីប្រាំ ហើយគឺជាអតីតនៅក្នុងក្រុមម៉ាសព្យ៉ា គឺថាសេចក្ដីថ្លែងការណ៍នោះគឺថាមិនអាចទទួលយកបាន គឺថាការសម្ពាធទៅលើសារព័ត៌មានមិនត្រូវបានគាំទ្រដូចប្រទេសអ៊ីតាលីទេ ។

[១១:១៨:៤២]

ដូច្នេះ ខ្ញុំសូមជម្រាបអង្គបុរេជំនុំជម្រះ ដើម្បីច្រានចោល ឬក៏នឹងមិនយកមកពិចារណានូវអ្វីដែលខ្ញុំលើកឡើងនេះ ។ ខ្ញុំបានបញ្ជាក់នៅក្នុងសវនាការដែលត្រូវពិចារណានោះ ពាក់ព័ន្ធទៅនឹងតម្រូវការដើម្បីឱ្យបន្តការឃុំខ្លួនជាបណ្ដោះអាសន្នឬទេ ដើម្បីរក្សាទុកនូវភស្តុតាងដែលថា កំណត់ហេតុគឺជាភស្តុតាងជាក់ស្ដែង ។ យើងមិនត្រូវបំភ្លេចនូវរបៀបរៀបរយសុវត្ថិភាពសាធារណៈ ហើយនិងសុវត្ថិភាពរបស់ជនត្រូវចោទ ។ ការដាក់ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ធ្វើឱ្យជនត្រូវចោទនឹងសម្ដែងនូវការគាបសង្កត់ការគំរាមកំហែងរបស់ខ្លួនទៅក្នុង តាមរយៈសារព័ត៌មានគឺជាហានិភ័យជាក់ស្ដែង គឺថាអាចនឹងប៉ះពាល់ទៅដល់របៀបរៀបរយសាធារណៈ ហើយនិងសន្តិសុខផ្ទាល់ខ្លួនអាចនឹងរងការគំរាម ។

ទាក់ទងទៅនឹងបញ្ហារបៀបរៀបរយសាធារណៈនិងសុវត្ថិភាព នៅក្នុងសេចក្ដីថ្លែងការណ៍នៅក្នុង*ញូវយ៉កថែមស៍* នៅក្នុងខែមិថុនានោះ ហើយនិងសាក្សីមួយចំនួននិងភាគី ។ ហើយនៅខែធ្នូ ២០០៨ នោះ នេះហើយគឺនៅមានហានិភ័យក្នុងការអំពើហិង្សាដែលថា ជនត្រូវចោទ និងភាគីទៅលើភាគី ឬក៏ អ.វ.ត.ក ដែលជាស្ថាប័នមួយ ឬក៏អាចជាស្ថាប័នផ្សេងទៀតដែលថានឹងរងហានិភ័យ ។

តាមពិតយើងមិនគាំទ្រអំពីសេចក្ដីថ្លែងការណ៍ចេញពីជនរងគ្រោះមួយចំនួន ដែលគេនិយាយថាគេចង់ឱ្យជនត្រូវចោទហ្នឹងទទួលរងការឈឺចាប់ដូចដែលខ្លួនៗបានរងក្នុងសម័យខ្មែរក្រហមនោះទេ ។

ប៉ុន្តែ យើងមានសេចក្តីសោកស្តាយណាស់ដែលថាត្រូវជនត្រូវចោទ ខៀវ សំផន ដែលបានទទួលរងអំពើនោះ ។ អ៊ីចឹងហើយគឺគេថ្កោលទោសអំពីអំពើដែលថា ជនរងគ្រោះត្រូវបានទទួលការគំរាម ។ ហើយយើងក៏កត់សម្គាល់ដែរថា គឺការវត្តមាននៃឧប្បត្តិហេតុនៃអំពើហិង្សានេះ គឺថាអាចនាំឲ្យមានសាក្សី ហ្នឹង ដែលមិនមានការសង្ស័យអ្វីទេ អនុលោមទៅតាមកត្តាផ្លូវចិត្ត និងកត្តាផ្លូវអារម្មណ៍នោះ ។

នេះហើយជាទស្សនៈ គឺថាវាឃ្លាតឆ្ងាយអំពីការ អំពីជំងឺបាក់ស្បាតក្រោយពីរបបនោះ ដែលថាវាមានភាពតានតឹងណាស់ចំពោះសាក្សីមួយចំនួននៅកម្ពុជា ។ យើងបានដឹងថា នីតិវិធីបច្ចុប្បន្ននេះ គឺផ្តល់ឲ្យមានដើបឡើងវិញនូវសង្គម ដើម្បីបំបាត់នូវជំងឺបាក់ស្បាតទាំងឡាយដូចកើតមាននោះ ។

នេះគឺជា គឺការកើតឡើងជាថ្មីនូវអំពើនេះ គឺថាអាចនឹងធ្វើឲ្យមានការអំពើហិង្សាឡើងវិញនៅក្នុងករណីដែលថា ដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំនោះ ។ ដូច្នេះវាប៉ះពាល់ទៅដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ និងរបៀបរៀបរយសាធារណៈនោះដែរ ។ ហើយគឺថា ហានិភ័យ គឺថាវាមានភាពជាក់ស្តែងទាក់ទងទៅនឹងឧប្បត្តិហេតុ ដែលយើងបានលើកឡើងខាងដើមនោះ ។

[១១:២១:៥២]

នៅក្នុងបរិបទ នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងថ្ងៃទី៩ ខែកក្កដា កន្លងទៅនេះ ។ ខ្ញុំក៏សូមយោងទៅរកការសិក្សាមួយដែលនិយាយថា យើងមិនដែលបំភ្លេចទេអតីតកាល ហើយមិនទាន់បានដាក់នៅក្នុងសំណុំរឿង ។ គឺថា ៩០ភាគរយនៃជនដែលគេបានសម្ភាសន៍នោះ គឺជឿជាក់ថាសមាជិកនៃខ្មែរក្រហមត្រូវតែយកមកជំនុំជម្រះសម្រាប់បទឧក្រិដ្ឋដែលគេបានប្រព្រឹត្ត ។ ហើយជាពិសេស គឺភាគច្រើននៃអ្នកដែលផ្តល់សម្ភាសន៍នោះបានបញ្ជាក់ថា គេមានការស្អប់ខ្ពើមទៅលើខ្មែរក្រហមជាអ្នកប្រព្រឹត្តបទល្មើស ដែលបានចោទនេះ ។ គឺថាភាគច្រើននោះគេនិយាយថា គេចង់ឲ្យអតីតមេខ្មែរក្រហមទទួលរងការឈឺចាប់ ដូចដែលគេរងចាប់ក្នុងសម័យនោះ ។ គឺថាមួយផ្នែកទៀត គឺគេចង់ថានឹងសងសឹកទៅលើនោះ បើសិនជាមានឱកាសនឹងសងសឹក ។

ប៉ុន្តែ អ្នកផ្សេងទៀតនិយាយថា អ្នកខ្លះគឺថាអាចនឹងផ្តល់ការលើកលែងទោសបាន ប៉ុន្តែភាគតិចទេ ។ ប៉ុន្តែ ការសិក្សាខាងលើនេះ ជាញ្ញើកញ្ជាប់ចំពោះអ្នកដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហម ហើយនិងអ្នកកើតក្រោយរបបហ្នឹង ក៏គេយើងអាចយល់បានដែរពីអារម្មណ៍នេះ ។

[១១:២៣:១១]

ដូច្នេះ ចំណុចទាំងនេះហើយ ដែលយើងជឿជាក់ថា ដែលគាំទ្រអ្វីដែលបានលើកឡើងពីខាងដើម

ហើយៗក៏គាំទ្រអ្វីដែលយើងពិនិត្យឃើញថានៅក្នុងសារព័ត៌មាន*ញូវយ៉កថែមស៍*ដែលក្នុងខែមិថុនានោះ ។

លោកប្រធាន លោកស្រីចៅក្រម! យើងសុំស្នើឲ្យអង្គបុរេជំនុំជម្រះច្រានចោលនូវការអះអាងរបស់មេធាវីការពារ ដែលថាមិនមានហានិភ័យជាក់ស្តែងនោះ ដែលថាស្ថានភាពទាំងអស់នេះមិនបង្ហាញមូលហេតុទេ ។ អ៊ីចឹងហើយ ចំណុចលក្ខខណ្ឌទាំងប្រាំនៅតាមមាត្រា ៦៣.៣(ក)ហ្នឹង គឺថាបានបំពេញហើយ ។

ប្រសិនបើឲ្យមានការដោះខ្លួនឲ្យនៅក្រៅឃុំបណ្តោះអាសន្ននោះ បណ្តឹងត្រូវយោងទៅរកលក្ខខណ្ឌមួយចំនួនដែលទាក់ទងទៅថា គប្បីតែដោះលែងឲ្យនៅក្រៅឃុំ ។ ដូច្នេះ ជាលក្ខខណ្ឌដែលមិនអាចទទួលយកបានទេ ដែលបានលើកឡើងហើយពីឆ្នាំទៅដែលថា ជនត្រូវចោទគឺថាអាចធ្វើដំណើរដោយសេរីបាននៅភ្នំពេញនោះ ដោយសារការឃុំខ្លួនបណ្តោះអាសន្នគឺចាត់ទុកជាសំខាន់ យ៉ាងហោចណាស់បំពេញតាមលក្ខខណ្ឌមួយនៃប្រាំ ដែលខ្ញុំលើកឡើងខាងដើមនោះ ។

មិនមានលទ្ធភាពណាមួយ ដើម្បីឲ្យការដោះលែងដែលមានលក្ខខណ្ឌ ដែលមិនមានបញ្ហាដែលថាកម្រិតណាមួយដែលថា ជាលក្ខខណ្ឌដែលត្រូវយកមកអនុវត្ត ដែលអាចនឹងធ្វើឲ្យយើងឲ្យមានការធានាដែលអាចធ្វើទៅបានទេ ដើម្បីការពារនូវសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ហើយដើម្បីធានានូវសុវត្ថិភាពសាធារណៈនោះទេ ។ គឺថាហានិភ័យនៃការគាបសង្កត់ទៅលើសាក្សីនិងជនរងគ្រោះ ហើយនិងហានិរភាពទៅលើការបំផ្លាញភស្តុតាង ។ ហើយនៅក្នុងសេចក្តីសន្និដ្ឋាននេះ យើងសូមស្នើ ហើយសូមស្នើជាម៉ឺងម៉ាត់ថា សូមឲ្យច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ហើយសូមឲ្យរក្សាការឃុំខ្លួនជាបណ្តោះអាសន្នជាបន្តទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គបុរេ៖**

លោកមេធាវីការពារក្តី លោកមានអ្វីឆ្លើយតបថាតើខាងមេធាវីការពារក្តីចង់ឆ្លើយតបទេ?

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គបុរេជំនុំជម្រះម្តងទៀត ហើយនឹងហើយនិងសូមគោរពអង្គសវនាការ គឺថាខ្ញុំបាទគឺត្រូវបានមានការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ ថាតើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា គឺថាសហព្រះរាជអាជ្ញាបរទេសបានលើកឡើងថា ក្នុងសំណុំរឿងលេខ០០១ របស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង ត្រូវបានសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឲ្យបញ្ចូលមកក្នុងសំណុំរឿង០០២ ហើយ ។

ឆ្លៀតឱកាសនេះ គឺខ្ញុំបាទសូមអនុញ្ញាត ដើម្បីបំភ្លឺជូននូវការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាថា គឺសហព្រះរាជអាជ្ញាបរទេសលើកហ្នឹង គឺមានសំអាងហេតុមិនត្រឹមត្រូវទេ មិនមានលក្ខណៈជាក់លាក់ទេ ។ បានសេចក្តីថានៅក្នុងចម្លើយរបស់ ឌុច នៅក្នុងសំណុំរឿងលេខ001 ដែលត្រូវបញ្ចូលមកសំណុំរឿងលេខ00២ហ្នឹងវាច្រើន ។ ប៉ុន្តែ ក្នុងចំណោមនោះឃើញថាមានតែចម្លើយសារភាពរបស់ឌុច ពីរតែប៉ុណ្ណោះ ដែលទាក់ទងដល់កូនក្តីខ្ញុំបាទ ។ ខ្ញុំបាទនឹងសូមអនុញ្ញាតបំភ្លឺជូនខាងក្រោយ ។

ជាពិសេសគាត់បានលើកឡើងថា នៅក្នុងឯកសារ D៨៨, D៨៨ បាននិយាយពាក់ព័ន្ធដល់កូនក្តីខ្ញុំបាទ គឺនៅក្នុង D៨៨ នេះចម្លើយរបស់ ឌុច គឺអត់មានប៉ះពាល់ដល់កូនក្តីខ្ញុំបាទទេ គឺមានតែចម្លើយដែលពាក់ព័ន្ធទៅដល់ នួន ជា, ពាក់ព័ន្ធដល់ ប៉ុល ពត ទាក់ទងដល់ សុន សេន អត់មានទាក់ទងទៅដល់ អៀង ធីរិទ្ធ នៅក្នុងD៨៨ទេ អត់មានសោះ ។ ការលើកទឡ្ហីករណ៍ ដែលគ្មានមូលដ្ឋានជាក់លាក់ គឺថាអាចធ្វើឲ្យអង្គសវនាការមានការភ័ន្តច្រឡំ ដោយសារសំណុំរឿងគឺថាសាធារណជនអត់បានសិក្សាលម្អិតហើយដល់អ៊ីចឹងទៅឮគាត់ថាដោយសង្ខេបអ៊ីចឹងទៅ ធាតុពិតវាអត់មាន អត់មានពាក់ព័ន្ធអ្វីជាក់លាក់ទេ ។ ចំណុចមួយទៀត ខ្ញុំបាទមិនដឹងថា អាចបង្ហាញនៅក្នុងខ្លឹមសារនេះបានដែរឬអត់? ពីព្រោះថាអីវាទាក់ទងទៅដល់ហៅថា សំណុំរឿង ទាក់ទងដល់អង្គសេចក្តី ។ ហើយបើប្រសិនជាអាចដែលធ្វើទៅកើត បើថាខ្ញុំអាចនិយាយ ខ្លាចតែប៉ះពាល់ទៅ វាជាសាធារណៈ ។ ខ្ញុំបាទសូមស្នើថាបើអាចធ្វើជាអសាធារណៈបានបែបល្អ ខ្ញុំបាទនឹងបង្ហាញឲ្យឃើញគ្រប់ជ្រុងជ្រោយទាំងអស់ ដោយហេតុដែលហៅថា សហព្រះរាជអាជ្ញាគាត់លើកឡើងហ្នឹង ។ ខ្ញុំបាទសំណូមពរមើលថាតើអាចធ្វើជាអសាធារណៈបានទេ?

[១១:២៩:០៦]

**ប្រធានអង្គបុរេ៖**

សូមលោកមេធាវីបញ្ជាក់ថា យើងបន្តសាធារណៈតបន្តទៅទៀត ហើយបន្ទាប់មកបើលោកស្នើសុំ សូមអសាធារណៈ យើងនឹងពិភាក្សាគ្នាតទៅទៀត ។

**លោក ផាត់ ពៅស៊ាង៖**

ពីព្រោះអ្វីដែលខ្ញុំបាទ បានលើកឡើងខាងដើម គោលបំណង *(ឮមិនច្បាស់)* ---បើលើកជាសាធារណៈ ខ្លាចវាប៉ះពាល់ទៅដល់វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

**ប្រធានអង្គប្រជុំ៖**

សូមលោកមេធាវីបន្តអ្វីដែលលោកសន្និដ្ឋានជាសាធារណៈ សូមឲ្យលោកបន្តទៅ រួចហើយបន្ទាប់មកទៀត សូមឲ្យជនត្រូវចោទឡើងឆ្លើយ ហើយនៅចុងបញ្ចប់បានយើងធ្វើសវនាការជាអសាធារណៈ ។

**លោក ផាត់ ពៅស៊ាង៖**

អ៊ីចឹងខ្ញុំបាទសូមអនុញ្ញាតនឹងបន្តការងារ ដែលការឆ្លើយតបហ្នឹងនឹងបន្តទៅទៀត ។ គឺថាចំពោះហៅថាអ្វីដែលហៅថាសហព្រះរាជអាជ្ញា លោកលើកឡើងហ្នឹង គឺវាគ្មានអំណះអំណាងពិតប្រាកដទេ ។ ដោយសារអំណះអំណាងមិនពិតប្រាកដអ៊ីចឹង លើកជាច្បោល លើកជាច្បោលៗអ៊ីចឹងទៅ គឺថានៅក្នុងករណីនេះ គឺមានករណីជាច្រើនដែលមានហៅថា ការឆ្លើយៗមកគឺថាវាអត់មានលក្ខណៈជាក់ស្តែងដល់វាមានលក្ខណៈជាទូទៅសហព្រះរាជអាជ្ញា គាត់បានលើកឡើងហើយថា ថ្វីត្បិតតែមិនបានដៅឈ្មោះរបស់កូនក្តីខ្ញុំបាទឲ្យបានជាក់លាក់ ក៏ប៉ុន្តែគេអាចកាត់យល់ថា ជាកូនក្តីខ្ញុំបាទ ។

[១១:៣១:៤៩]

ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនថា បើសិនជាការកាត់យល់ ជាការកាត់ស្មាននឹងហ្នឹងគឺថាមិនត្រឹមត្រូវទេ បើការកាត់យល់ ការកាត់ស្មានហ្នឹងវាក្លាយទៅជាវិមតិសង្ស័យហើយ ។ ដូច្នេះកន្លែងហ្នឹងគឺថាវាមានលក្ខណៈមិនប្រាកដប្រជា ។ ហើយទន្ទឹងទន្ទឹមនឹងនោះចម្លើយនីមួយៗ គឺវាមានចម្លើយហៅថា ខ្ញុំបាទនឹងឆ្លើយ-- នឹងអនុញ្ញាតបំភ្លឺ នូវនៅអសាធារណៈឲ្យបានជាក់លាក់ជាងហ្នឹង តែពេលនេះគឺថាខ្ញុំបាទមាននិយាយតែជាលក្ខណៈច្បោលៗ ជាលក្ខណៈមួយហៅថាត្រួសៗនៅឡើយ ។

គឺបានន័យថា ចម្លើយមួយចំនួនបានឆ្លើយមកដាក់កូនក្តីខ្ញុំបាទខ្លះ ហើយដោយផ្អែកទៅតាមហៅថាចម្លើយសារភាពអ៊ីចឹងទៅហូរហែ គេក៏បានចាប់អ្នកដែលធ្វើការនៅក្រសួងសង្គមកិច្ច ។ ដល់ការគេចាប់បាននៅក្រសួងសង្គមកិច្ច វាមានបទប្បញ្ញត្តិរបស់វាមួយ គឺថានៅសម័យហៅថាកម្ពុជាប្រជាធិបតេយ្យ គឺគេមានបទប្បញ្ញត្តិរបស់គេមួយ ។ គឺមានហៅថាសេចក្តីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន ។

ដូច្នេះ គឺថាសេចក្តីសម្រេចហ្នឹង គឺចេញនៅថ្ងៃទី៣០ ខែ៣ ឆ្នាំ៧៦ ក្នុងករណីនេះគេបានរៀបរាប់លម្អិតអំពីតួនាទីសិទ្ធិសម្រេច បាទសិទ្ធិសម្រេច ។ ដូច្នេះ នៅក្នុងករណីនឹងហ្នឹងសិទ្ធិសម្រេចអី? សិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ ។ ដូច្នេះ នៅពេលអសាធារណៈ ខ្ញុំបាទនឹងលើកបង្ហាញឲ្យបានជាក់ជាក់ច្បាស់ជាងនឹងហ្នឹងតទៅទៀត ។

ទន្ទឹមងនឹងនោះក៏មានចម្លើយមួយចំនួនរបស់ ឡូរ៉ង់ ពិច ចម្លើយរបស់ ឡូរ៉ង់ ពិច បានឆ្លើយប៉ះពាល់មួយចំនួនតិចតួចដល់កូនក្តីខ្ញុំបាទ ប៉ុន្តែត្រូវបដិសេធចោលដោយចម្លើយរបស់ប្តីគាត់ [redacted] ។ [redacted] បានបដិសេធនូវចម្លើយរបស់ ឡូរ៉ង់ ពិច ហើយថាមិនមានលក្ខណៈជាក់លាក់និងត្រឹមត្រូវទេ ។ ហើយទន្ទឹមនឹងនោះនុ៎ង គឺថាក្នុងករណីនេះខ្ញុំសូមអនុញ្ញាតជម្រាបជូនថា ឡូរ៉ង់ ពិច គឺគាត់ធ្វើការជាបុគ្គលិកនៅក្នុងក្រសួងប-១ (“ប-១ គឺក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ”) ។

ដល់អ៊ីចឹងទៅ គឺគាត់បានជួបជាមួយកូនក្តីរបស់កូនក្តីខ្ញុំបាទហ្នឹងនឹងតិចតួចណាស់ ហើយចម្លើយរបស់គាត់ដែលប៉ះពាល់ដល់កូនក្តីរបស់ខ្ញុំបាទហ្នឹងតិចតួចណាស់ តិចតួចបំផុត ។ លើសពីនេះទៅទៀត ការសំអាងរបស់សហព្រះរាជអាជ្ញា ដែលបានសំអាងថាមានការចាប់ខ្លួនបុគ្គលិកនៅក្រសួងសង្គមកិច្ចហូរហែហ្នឹង ខ្ញុំបាទបានពិនិត្យនៅលើហៅថាចម្លើយសារភាព និងចម្លើយរបស់សាក្សី រហូតទៅដល់ថាសហចៅក្រមស៊ើបអង្កេតបានសួរចម្លើយរបស់សាក្សីជាង១០០នាក់ ។

ខ្ញុំបាទក៏តាមដានពិនិត្យនៅក្នុងហ្នឹងនឹងដែរ ពិនិត្យសិក្សានៅក្នុងសំណុំរឿងហ្នឹង គឺការឆ្លើយដាក់មកលើកូនក្តីរបស់ខ្ញុំបាទហ្នឹងតិចតួច ដោយសារកូនក្តីរបស់ខ្ញុំ អត់មានសមត្ថកិច្ចធំធេងនៅក្នុងរឿងហ្នឹងទេ ក្រៅអំពីតួនាទីជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចតែប៉ុណ្ណោះ ។

[១១:៣៥:០០]

ដូច្នេះ អ្វីដែលខ្ញុំបាទឆ្លើយតបទៅនឹងហៅថាអ្វីដែលជាសាធារណៈ គឺខ្ញុំបាទបញ្ចប់ត្រឹមហ្នឹង ហើយខ្ញុំបាទនឹងសូមអនុញ្ញាតសាជាថ្មី ធ្វើជាអសាធារណៈបន្ត ។

[១១:៣៦:២៤]

**ប្រធានអង្គបុរេ៖**

ជនត្រូវចោទអ្នកស្រី---

*(ចៅក្រមពិភាក្សា)*

ជនត្រូវចោទអ្នកស្រី អៀង ធីរិទ្ធ អញ្ជើញមកមុខតុលាការ ។

[១១:៣៧:៤៨]

**ចៅក្រម រ៉ូវ៉ាន់ ដោននីង៖**

ខ្ញុំចង់លើកសំណួរសម្រាប់មេធាវីការពារក្តីជាតិ តើជាការត្រឹមត្រូវទេ ដែលនៅក្នុងសារណាឧទ្ធរណ៍របស់លោក លោកមិនបានស្នើ ឬក៏បានលើកឡើងពីចំណុចក្នុងការដាក់ឲ្យឃុំខ្លួននៅគេហដ្ឋាន?

ខ្ញុំមិនបានមើលឃើញចំណុចនេះនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់លោកទេ ។

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គប្រជុំជំនុំជម្រះ! ខ្ញុំបាទពិតជាមិនបានសរសេរនៅក្នុងបណ្ដឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរនាពេលនោះមែន ប៉ុន្តែ គឺខ្ញុំបាទលើកនៅពេលនេះគឺហៅថាដោយផ្អែកទៅលើហៅថាការស្នើសុំដោយផ្ទាល់មាត់ ។

**លោក វ៉ូវ៉ាន់ ដោននីង៖**

សូមអរគុណ។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលវិធានផ្ទៃក្នុងលេខ៦៥ ទាក់ទងការឲ្យនៅក្រៅបណ្ដោះអាសន្ន និងមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហើយប្រសិនជាបើលោកអាចធ្វើការបង្ហាញមកដល់តុលាការនេះ ក្នុងការចេញដីកាបញ្ជាឲ្យនៅក្រៅឃុំបណ្ដោះអាសន្ននោះ។

**លោក ផាត់ ពៅស៊ាង៖**

សូមគោរព! គឺថាខ្ញុំបាទអត់យល់អំពីសំណួរដែលថា ចេញសេចក្ដីសម្រេចបញ្ជា ខ្ញុំបាទអត់យល់សំណួរ សូមអនុញ្ញាតម្ដងទៀត ។

**លោក វ៉ូវ៉ាន់ ដោននីង៖**

ប្រសិនបើលោកមើលវិធានផ្ទៃក្នុង៦៥ ដែលចែងអំពីដីកាបង្គាប់ដាក់ឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ គឺមានសេចក្ដីយោងទៅនឹងបទប្បញ្ញត្តិពីលក្ខខណ្ឌមួយចំនួនដែលចាំបាច់ដើម្បី-- អំពីការវត្តមានរបស់ជនត្រូវចោទចំពោះនីតិវិធីរបស់តុលាការ ។ ថាតើវាទាក់ទងដូចម្ដេចទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រង់មាត្រា២២៣? បើតាមពិតគឺវាមានការទាក់ទងគ្នារវាង (២)បញ្ញត្តិទាំងពីរនេះថាតើអំណាចហ្នឹងវាចេញមកពីណា ដែលថាអំណាចសាលាក្ដីដើម្បីក្នុងការបង្គាប់ឲ្យមានការគំហាត់លំនៅបានន័យថា ឃុំខ្លួននៅក្នុងលំនៅដ្ឋានរបស់ជនត្រូវចោទនោះ?

តើលោកមានលទ្ធភាពក្នុងការពន្យល់ថា តើអង្គជំនុំជម្រះនេះមានអំណាចក្នុងការសម្រេចយកជម្រើសនេះជាការឆន្ទានុសិទ្ធិរបស់ខ្លួនទេ តាមច្បាប់និងវិធាននេះ?

[១១:៤២:៤០]

**លោក ផាត់ ពៅស៊ាង៖**

សូមអរគុណ ។ ខ្ញុំបាទសូមអនុញ្ញាតបំភ្លឺជូនថា ដោយផ្អែកទៅតាមហៅថា ក្រមស្ដីពីនីតិវិធី

ព្រហ្មទណ្ឌ និងហៅថាវិធានផ្ទៃក្នុង គឺបានន័យថាតុលាការ ត្រូវសម្រេចសេចក្តីដោយផ្អែកទៅតាមការបញ្ញត្តិរបស់ច្បាប់ ។ គឺថាក្នុងករណីហ្នឹង គឺនៅក្នុងសេចក្តីសន្និដ្ឋានការពាររបស់ខ្ញុំ ក៏ដូចជាហៅថាបណ្តឹងឧទ្ធរណ៍លើកមុន ខ្ញុំបាទបានដាក់ជូននូវលក្ខខណ្ឌមួយចំនួន គឺថាដែលកូនក្តីខ្ញុំបាទត្រូវតែមានកាតព្វកិច្ចគោរពនៅក្នុងករណីដែលតុលាការសម្រេចឲ្យកូនក្តីខ្ញុំបាទនៅក្រៅឃុំ គឺខ្ញុំបាទបានដាក់នៅតាំងពីថ្ងៃទី០២ ខែមករា ឆ្នាំ២០០៨ គឺក្នុងហ្នឹងមានមួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរចំណុច ជូនថាអង្គបុរេជំនុំជម្រះដើម្បីពិចារណា ។

ប៉ុន្តែ អ្វីដែលហៅថាខ្ញុំបាទបានលើកឡើងជាផ្ទាល់មាត់ ដែលហៅថាការដាក់ឃុំខ្លួននៅក្នុងគេហដ្ឋាននេះ ដោយផ្អែកទៅតាមច្បាប់របស់កម្ពុជា គឺថាអត់បានចែងអំពីហៅថាចំណងជើងនេះឲ្យបានច្បាស់លាស់ទេ ។ ក៏ប៉ុន្តែ គ្រាន់តែដាក់ឲ្យហៅថានៅក្រៅឃុំក្រោមការត្រួតពិនិត្យរបស់តុលាការ ។

គឺថាមាត្រា២២៣ និងមាត្រា៦៥ នៃវិធានផ្ទៃក្នុងហ្នឹងបានចែងអំពីហៅថាការឲ្យនៅក្រៅឃុំក្រោមការត្រួតពិនិត្យរបស់តុលាការ ។ គឺកូនក្តីខ្ញុំបាទបានធ្វើហៅថាលក្ខខណ្ឌដោយសន្យាដោយច្បាស់លាស់ថា៖

ចំណុចទីមួយ គឺកូនក្តីខ្ញុំបាទហ្នឹងគឺរស់នៅជារៀងរាល់ថ្ងៃយប់នៅក្នុងផ្ទះរបស់កូនស្រីគាត់ ដែលមានអាសយដ្ឋាននៅក្រុងភ្នំពេញ ។ ខ្ញុំបាទសូមអនុញ្ញាតលើកអំពីហៅថាលក្ខខណ្ឌដែលគាត់លើកឡើង គឺគាត់សន្យាថាគាត់រស់នៅតែផ្ទះដែលគេចាប់ខ្លួនគាត់ហ្នឹង គឺផ្ទះលេខ៤៧បេ ផ្លូវ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន នៅក្នុងករណីដែលហៅថា អង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យគាត់នៅក្រៅឃុំ ។

ហើយគាត់នឹងបន្តរស់នៅរាជធានីភ្នំពេញគ្រប់ពេលវេលា គាត់អត់ទៅប៉ៃលិនទេ គាត់អត់ទៅកន្លែងណាផ្សេងទៀតទេ បើសិនជាហៅថា អ.វ.ត.ក ឲ្យគាត់នៅក្រៅឃុំ ។ ហើយក៏អត់មានបំណងធ្វើដំណើរទៅកន្លែងណាផ្សេងក្រៅពីទីក្រុងភ្នំពេញដែរ ។

ទន្ទឹមនឹងនោះ ចំណុចទីបី គាត់បានលើកឡើងថា រាល់ឯកសារដែលធ្វើដំណើរ គឺថាគាត់មិនសុំប៉ាស្ព័រ បានសេចក្តីថាប៉ាស្ព័រខាង អ.វ.ត.ក បានដកលិខិតឆ្លងដែនអីសម្រាប់ចេញទៅក្រៅប្រទេសអស់ហើយ គាត់សន្យាថាមិនសុំលិខិតឆ្លងដែនទៀតទេ ។

ចំណុចទីបួន គឺថាគាត់សន្យាថាក្នុងរយៈពេលពីម៉ោង៨ល្ងាច ដល់ម៉ោង៧ភ្លឺ គឺគាត់អត់មានទៅណាទេ បើថាក្នុងករណីចាំបាច់គាត់ត្រូវទៅពេទ្យអីៗយ៉ាងណា គឺគាត់គោរពពេលវេលាថាម៉ោង៨ គឺគាត់ចូលមកដល់ផ្ទះហើយ ម៉ោង៧ភ្លឺ គឺគាត់ពិតជានៅក្នុងផ្ទះហើយ ។

ចំណុចទីប្រាំ គាត់ថាគាត់ទៅរាយការណ៍នៅកន្លែងនគរបាលប៉ុស្តិ៍ រៀងរាល់ថ្ងៃ ដែលនៅកន្លែងដែលគាត់ស្នាក់នៅ បានន័យថាដើម្បីបញ្ជាក់អំពីវត្តមានរបស់គាត់ ។

ចំណុចទីប្រាំមួយ គឺថាគាត់បានសន្យាថាមិនធ្វើការទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយសាក្សីឬជនរងគ្រោះណា ដែល អ.វ.ត.ក ឬមួយក៏ជាទូទៅដែល អ.វ.ត.ក កំណត់ ឬមួយក៏ជាទូទៅ គឺគាត់មិនទាក់ទងទេ ។ ហើយក្នុងករណី ដែលហៅថាបើសិនគាត់ធ្វើដំណើរ មានការរនឹករឭកទៅកូន ចង់ធ្វើដំណើរ ទៅខេត្តអី ដើម្បីសួរសុខទុក្ខកូនហ្នឹង គាត់នឹងជូនដំណឹងៗទៅឲ្យអាជ្ញាធរ ដែលនៅទីនោះឲ្យដឹងច្បាស់ថា តើគោលដៅរបស់គាត់ត្រូវទៅទីណា ដើម្បីឲ្យគេដឹងថាគាត់ត្រូវទៅកន្លែងណាគោលដៅដើម្បីគេរកគាត់ឃើញ ។ ក្នុងករណីហ្នឹងគាត់បានលើកអំពីហេតុផល និងលក្ខខណ្ឌទាំងអស់ជូនអង្គបុរេជំនុំជម្រះ ធ្វើការពិចារណាតាំងពីលើកមុនហើយ ។

[១១:៤៧:១០]

**លោក វ៉ូវ៉ាន់ ដោននីង៖**

តើខាងសហព្រះរាជអាជ្ញាមានអ្វីចង់លើកឡើងតបទៅនឹងការលើកឡើងនេះទេ?

**លោក វ៉ាំងសង់ ឌឺ វ៉ាលជ័ ដេស្សាងលេ៖**

ខ្ញុំបានធ្វើរួចហើយ ហើយជាសង្ខេប ។ ប៉ុន្តែខ្ញុំគិតថា បញ្ហានេះដែលបានលើកឡើងទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍ បើសិនជានេះមិនមែនជាករណីដែលបានលើកឡើងទេ ។ ខ្ញុំចង់ឲ្យពិចារណាទៅលើវិធាន៦៥ ហើយប្រសិនបើសិនជាចំណុចនេះ មិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទេ យើងមិនត្រូវលើកចំណុចនេះមកពិចារណាទេ នៅក្នុងសវនាការនេះ ។

ទាក់ទងទៅនឹងលក្ខខណ្ឌ ដែលបានលើកឡើង ប្រសិនបើលក្ខខណ្ឌនៃវិធាន៦៣.៣ ត្រូវបានបំពេញនោះ អ៊ីចឹងយើងត្រូវបានគិតថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាកត្តាចាំបាច់ មិនមានហេតុផលអ្វីជាការពិត ដែលខ្ញុំបាននិយាយថា វាគ្រប់គ្រាន់រួចហើយសម្រាប់ការបដិសេធនូវការឲ្យដាក់ឃុំខ្លួននៅគេហដ្ឋានឬមួយយ៉ាងណានោះ ។ សូមអរគុណ ។

**ប្រធានអង្គបុរេ៖**

លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ?

**លោក ហុង គឹមសួន៖**

សូមគោរពលោកប្រធានអង្គបុរេជំនុំជម្រះ ។ ខ្ញុំបាទមិនសន្និដ្ឋាន ឬក៏លើកឡើងទាក់ទងជាមួយ

នឹងសវនាការដែលយើងដាក់សារណានោះទេ ប៉ុន្តែខ្ញុំបាទសូម--

**ប្រធានអង្គបុរេ៖**

លោកសន្និដ្ឋានទាក់ទិននឹងបញ្ហាដែលមេធាវីជនត្រូវចោទបានលើកឡើង ហើយនិងព្រះរាជអាជ្ញាបានលើកឡើង?

**លោក ហុង គីមសួន៖**

បាទៗ, វាទាក់ទងជាមួយនឹងការស្នើសុំដែលមិនមែនជាលាយលក្ខណ៍អក្សរ អ៊ីចឹងបើគាត់-- មេធាវីការពារគាត់មានសិទ្ធិ ប្រើសិទ្ធិនិយាយសុំសន្និដ្ឋានដោយផ្ទាល់មាត់ ។ អ៊ីចឹង ខាងខ្ញុំបាទដែលអង្គបុរេបានហាមឃាត់រួចនោះហើយក៏សុំសិទ្ធិដូចគ្នាដែរ ។

ពីព្រោះថានៅក្នុងសវនាការនេះ អង្គបុរេជំនុំជម្រះបានណែនាំរួចហើយ អំពីភាគីដែលមិនបានដាក់សារណា គឺមិនអាចឡើងសន្និដ្ឋានបាន ។ ហើយមានតែការដាក់សារណាទេ ទើបសន្និដ្ឋានឬអង្គហេតុថ្មីដែលយកមកដាក់ ។ អ៊ីចឹង លោកមេធាវីការពារដែលគាត់លើកអំពីរឿងសុំឲ្យនៅក្រៅឃុំដោយមានការត្រួតពិនិត្យតាមតុលាការ អ៊ីចឹង ខ្ញុំបាទសុំសិទ្ធិនិយាយដោយមិនបានដាក់សារណាដូចគ្នាដែរ ។ ព្រោះនៅក្នុងនេះ ដូចខាងលោកសហព្រះរាជអាជ្ញាគាត់មានប្រសាសន៍មិញអ៊ីចឹង គាត់លើកឡើង យើងនិយាយតែអំពីការបន្តឃុំខ្លួនបណ្តោះអាសន្ន ។ អ៊ីចឹងទាក់ទងជាមួយនឹងការសុំឲ្យអង្គបុរេជំនុំជម្រះ--

**ចៅក្រម ខាទីនខា ឡាហ្វ៊ីស៖**

លោកបានស្នើសុំការអនុញ្ញាត ដើម្បីធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ ។ មានន័យថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងទៅនឹងការឃុំខ្លួននៅគេហដ្ឋានមែនឬទេ? ដែលនេះជាចំណុចថ្មីបានលើកឡើងនៅក្នុងអំឡុងពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍នេះ?

**លោក ហុង គីមសួន៖**

បាទត្រឹមត្រូវហើយ ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ីស៖**

យើងបានឯកភាព បើសិនជាលោកកំណត់ និយាយតែត្រឹមផ្នែកនេះតែប៉ុណ្ណោះ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកស្រីចៅក្រម ។ អ៊ីចឹង ខ្ញុំបាទសូមគោរពលោកប្រធាន និងអង្គសវនាការម្តងទៀត ។ ក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងថ្ងៃនេះ លើកតែពីចំណុចមួយដែលលោក

អនុញ្ញាត ។ ទាក់ទងជាមួយនឹងការស្នើសុំដោយផ្ទាល់មាត់របស់លោកមេធាវីការពារជនត្រូវចោទ អៀង ធីរិទ្ធ សុំឲ្យនៅក្រៅឃុំក្នុងផ្ទះ ក្រោមការត្រួតពិនិត្យរបស់តុលាការនេះ ខ្ញុំបាទយល់ឃើញថា មិនសមស្របទេ ហើយក៏មិនអាចទទួលយកបានដែរ ដោយហេតុថា ទាក់ទងជាមួយនឹងរយៈពេលកន្លងមក ជនត្រូវចោទ អៀង ធីរិទ្ធ ដែលនៅក្នុងផ្ទះរបស់គាត់ទីក្រុងភ្នំពេញ មិនបានបង្ហាញខ្លួនជាសាធារណៈទេ ។ ការរស់នៅក្នុងផ្ទះរបស់ក្រុមគ្រួសារកូនរបស់គាត់ រយៈកាលកន្លងមកនោះ ប្រជាពលរដ្ឋ ឬក៏មហាជននៅជិតខាងមិនបានដឹងទេ ឬមិនដែលឃើញទេ ។ ហើយការចេញដំណើររបស់គាត់ទៅ ខាងក្រៅ ក៏មិនមែនការបង្ហាញមុខជាសាធារណៈដែរ គឺត្រូវប្រើយានយន្ត ឬក៏ជិះនៅក្នុងរថយន្តដែលបិទជិត ។

អ៊ីចឹង ការដែលការពារខ្លួនរបស់គាត់ ទោះនៅក្នុងផ្ទះ ទោះធ្វើដំណើរ ដែលលោកមេធាវីការពារអះអាងថាជាការរស់នៅដោយគ្មានបង្ហាញហានិភ័យ ឬក៏បង្ហាញខ្លួនជាសាធារណៈនោះ គ្រាន់តែជាការលើកឡើងទេ ប៉ុន្តែបើតាមការពិត មិនមានប្រជាពលរដ្ឋនៅជិតខាង ឬអ្នកឆ្ងាយណាបានឃើញ បានដឹង បានឃើញជាសាធារណៈនោះទេ ។ ត្រង់នេះបង្ហាញថាការលើកឡើងនេះមិនអាចទទួលយកបានទេ ។

[១១:៥៣:២៤]

ខ្ញុំបាទសូមឲ្យអង្គសវនាការ សម្រេចទាត់ចោលនូវការស្នើសុំផ្ទាល់មាត់ អំពីការសុំនៅក្រៅឃុំ ដោយក្រោមការត្រួតពិនិត្យរបស់តុលាការ ។ ព្រោះសវនាការដែលទាក់ទិនជាមួយនឹងមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងចំណោមជនត្រូវចោទប្រាំនាក់នេះ ជិតដល់ពេលសវនាការរបស់លោក ឌុច ហើយ ។ ដូច្នេះ សុំឲ្យបន្តការឃុំខ្លួនបន្តទៅទៀតបាទ ។ សូមអរគុណ ។

**ប្រធានអង្គបុរេ៖**

ជនត្រូវចោទលោកស្រី អៀង ធីរិទ្ធ តើលោកស្រីមានអ្វីបន្ថែមទៀតទេ មានយោបល់អ្វីបន្ថែមទៀតទេ? សូមអញ្ជើញ ។

**ជនត្រូវចោទ៖**

ខ្ញុំគ្មានអីបន្ថែមទេ-- ខ្ញុំចង់តែបញ្ជាក់អំពីឋានៈរបស់ខ្ញុំឲ្យបានច្បាស់លាស់ ។ ខ្ញុំគ្មានជំពាក់ជំពិនអីជាមួយ ឌុច ទេ យកខ្ញុំទៅភ្ជាប់ជាមួយ ឌុច ហ្នឹង មិនត្រូវជាដាច់ខាត ។ ខ្ញុំគ្មានពាក់ព័ន្ធទេ ទៅស៊ើបមើលខ្លួនឯងទៅខ្ញុំគ្មានពាក់ព័ន្ធទេ ។

កន្លងមកខ្ញុំទៅផ្សាយវិទ្យុនៅហាណូយ ព្រោះនៅភ្នំពេញទម្លាក់គ្រាប់បែក ។ ខ្ញុំផ្សាយវិទ្យុនៅ

ហាណូយអស់បីឆ្នាំ កូនសិស្សទៅតាមខ្ញុំរាប់រយនាក់ ។ ឆ្នាំ១៩៧៥? អ៊ីចឹង ៧៥ ក៏ខាងលោក ប៉ុល ពត គាត់ហៅឲ្យពួកខ្ញុំនិងក្រុមខ្ញុំ ចូលមកស្រុកវិញចុះៗមកតាមប្រទេសចិន ។ ពេលនោះដោយមានសមមិត្ត ចិនអ្នកដឹកនាំមកស្រុកខ្មែរមុន ខ្ញុំក៏ជិះកប៉ាល់ហោះពិសេស ជាមួយសមមិត្តចិនម្នាក់ឯង ។ ហើយស្អែក ឡើងបានពួកក្មួយៗ ប្រុសៗ និងស្រីទាំងអស់ហ្នឹង នាំគ្នាជិះកប៉ាល់ហោះមកដល់ស្រុកខ្មែរក្រោយខ្ញុំមួយ ថ្ងៃ ខ្ញុំសូមជម្រាប ។ ដូច្នេះ ខ្ញុំគ្មានជំពាក់ជំពាក់ជំពន្ធអី ជាមួយរឿង នួន ជា រឿងអីខ្ញុំគ្មានទេ ។ ប៉ុន្តែខ្ញុំដឹង នួន ជា ធ្វើអីខ្ញុំដឹង ។ សម្លាប់មនុស្សម៉េច ខ្ញុំដឹងទាំងអស់ ។

[១១:៥៥:៥៦]

ខ្ញុំសូមជម្រាបប៉ុណ្ណឹង ខ្ញុំដឹងៗថា មនុស្សដែលស្លាប់នៅហ្នឹង ។ អ្នកណាអ្នកបញ្ជាឲ្យសម្លាប់? អ្នកណាបញ្ជា កាំង ហ្កេកអ៊ាវ ឲ្យសម្លាប់? អាហ្នឹងខ្ញុំដឹង ។ ក្នុងនេះកូនសិស្សដែលមកជាមួយខ្ញុំ សុទ្ធតែមហាវិទ្យាល័យមកពីប្រទេសបី មកពីរុស្ស៊ី ម៉ូស្គូ មកពីបារាំង-- មកពីខាងប្រទេសបារាំង ។ ពេលដែលខ្ញុំមក គេមកជាមួយខ្ញុំទាំងអស់ គេមកនៅភ្នំពេញជាមួយខ្ញុំ ។

ពេលហ្នឹងហើយបានកើតមានរឿងចាប់កូនសិស្សខ្ញុំយកទៅសម្លាប់ចោល គឺ នួន ជា ។ ខ្ញុំសូមប្រាប់មួយម៉ាត់ប៉ុណ្ណឹងឲ្យបានច្បាស់ ។ យកឡានចិនស្អាតយកមកដឹកគ្នា យកទៅសម្លាប់ចោល ។ ពេលនោះ ខ្ញុំទៅជួសជុលមន្ទីរធំរបស់យើងនៅនេះ? គេហៅអី? នៅមាត់ទន្លេទៅខាងណោះ វាខ្ទេចខ្ទីអស់រលីងទៅ គឺថាមន្ទីរពេទ្យធំៗ ។

ខ្ញុំមកដល់ភ្លាម គេឲ្យទទួលសង្គមកិច្ច អ៊ីចឹងយើងមិនត្រូវមើលអ្នកជំងឺ! ដល់ពេលទៅដល់អ្នកជំងឺដេកដី ដេកស្អី វេទនា អ៊ីចឹង ។ ខ្ញុំក៏សម្រេចចិត្តថា ខ្ញុំនឹងជួសជុលមន្ទីរពេទ្យនុ៎ង ។ មហាជននៅហ្នឹង គេឲ្យកម្មករគេមកជួយខ្ញុំទាំងអស់ ។ ទោះបីថា នៅភ្នំពេញកាលហ្នឹង មហាជននៅតិចក៏ដោយ តែកម្មករជំនាញគាត់ឲ្យមកជួយខ្ញុំទាំងអស់ ដូច្នេះខ្ញុំម្នាក់ឯងជាមួយកម្មករទៅជួសជុលមន្ទីរពេទ្យ ។ ព្រោះអ្នកជំងឺអត់កន្លែងដេកទៅហើយ ។

ឯកូនសិស្សវិញ គ្នាសុំជួសជុល រៀនជួសជុលរោងចក្រផលិតថ្នាំៗគឺនៅជិតមន្ទីរខ្ញុំដេកជាង ។ ខ្ញុំគេឲ្យកង់មួយ រដ្ឋមន្ត្រី-- កង់កញ្ចាស់មួយ ។ ខ្ញុំជិះកង់ទៅហ្នឹង ខ្ញុំហូបជាមួយកម្មករអីទាំងអស់ ព្រលប់បានខ្ញុំត្រឡប់មកវិញ ។ ហើយកូនសិស្សខាងណោះ ខំធ្វើការងារខាងរោងចក្រផលិតថ្នាំ ។ រោងចក្រផលិតថ្នាំបួននៅភ្នំពេញទៅស៊ើបមើលទៅ ។ មានអ្នកជំនាញការចិន មួយរោងចក្រពីរៗ តាមបញ្ជារបស់លោកនាយក ជូ អេនឡាយ ឲ្យមកជួយខ្ញុំ ។ ជួយបង្រៀនផលិតថ្នាំ អាហ្នឹងទៅសួរទៅ ខ្ញុំសូមជម្រាបអ៊ីចឹង ។

[១១:៥៨:១០]

តែពេលដែលកូនសិស្សខ្ញុំហ្នឹង ដែលនៅសល់ប៉ុន្មានទៅរៀនផលិតថ្នាំហ្នឹង ។ នួន ជា បានឲ្យឡានចិនរលោងស្រិល ទៅចាប់គ្នាដាក់-- យកទៅចូលគុក កាំង ហ្គេកអ៊ាវ សម្លាប់ចោល ។ នៅពេលនេះ វាជាឱកាសល្អណាស់ ។ ខ្ញុំត្រូវអ៊ីចឹង នួន ជា វាសម្លាប់កូនសិស្សខ្ញុំអស់រលីង ។ ខ្ញុំនិយាយ កុំមកចោទខ្ញុំខ្លាំងពេក។ ខ្ញុំជាអ្នកការពារកូនសិស្សខ្ញុំ ។ កុំមកចោទខ្ញុំផ្ដេសផ្ដាស ខ្ញុំមិនមែនអ្នកនេះទេ-- ខ្ញុំអ្នកមានពូជតាំងពីដើមមក ។

លោកតាខ្ញុំធ្វើចាងហ្វាងសាលាវិនិច្ឆ័យ ឪពុកខ្ញុំក៏ធ្វើចាងហ្វាងនៅបាត់ដំបង សុទ្ធតែអ្នកកាន់នេះទាំងអស់ ហើយខ្ញុំមិនមែនមនុស្សអនាថាឯណា ទៅសម្លាប់គេលេងៗអ៊ីចឹង ។ ខ្ញុំខំរៀនម្នាក់ឯង អង់គ្លេស ។ ខ្មែរមិនទាន់ចេះអង់គ្លេស ខ្ញុំទៅរៀនយកលីហ្សង់អង់គ្លេសម្នាក់ឯង ខំទាំងត្រដាបទាំងត្រដួសខំមែនទែន ។ ខ្ញុំធ្វើអ្វីសម្រាប់ជាតិខ្ញុំ សម្រាប់ប្រជាជនខ្ញុំ មកដល់នេះយកកូនសិស្សខ្ញុំអស់រលីង យកសុទ្ធតែឡានចិនមកញាត់គ្នាទៅ ។ យកទៅឲ្យ កាំង ហ្គេកអ៊ាវ សម្លាប់ ។ ទៅសួរ កាំង ហ្គេកអ៊ាវ ។

អាហ្នឹង ខ្ញុំប្រាប់ពីរឿង នួន ជា ឲ្យច្បាស់ ហើយកុំយក នួន ជា មកដាក់ខ្ញុំ ។ កុំយក នួន ជា មកដាក់លើខ្ញុំ ។ ខ្ញុំរងគ្រោះដោយសារ នួន ជា ។ កូនសិស្សខ្ញុំរងគ្រោះ ។ អយុត្តិធម៌ណាស់! បើធ្វើរបៀបហ្នឹង! គឺយ៉ាប់ណា មិនដឹង នួន ជា ជាស្អីផង ។ នួន ជា និយាយប្រាប់អីចេះតែជឿៗ វានិយាយប្រាប់ភរ វាអ្នកធ្វើ ។ វាអ្នកចាប់កូនសិស្សទាំងអស់ ឡានចិនខ្មៅរលោងស្រិលបន្តិមហាជន គ្នាស្មានតែភ្ញៀវកិត្តិយស ។ យកសុទ្ធតែឡានចិនមកដឹកគ្នាយកទៅសម្លាប់ចោល ។

ខ្ញុំមិនដែលស្គាល់គុកហ្នឹងនៅណាទេ? ស-២១ ខ្ញុំមិនដែលស្គាល់ទេ ព្រោះខ្ញុំស្អប់តាំងពីដើមមក។ សូមជម្រាបអស់លោកឲ្យជ្រាប ។ កុំមកចោទខ្ញុំថា ឃាតករ! ឃាតអី! គឺថាប្រយ័ត្នចុះនរកប្រាំពីរជាន់ងើបមិនរួច ។

ហួសហេតុពេកធ្វើបាបគ្នាអ៊ីចឹង ។

[១២:០០:១៨]

**ចៅក្រម ខាទីនខា ឡាហ្វ៊ូស៖**

អ៊ីចឹង! តើលោកស្រីបញ្ចប់នូវសុន្ទរកថាចុងក្រោយរបស់លោកស្រីហើយឬ?

តើលោកស្រីចង់បន្តនិយាយទៀតទេ បើលោកស្រីចង់និយាយបន្តទៀត សូមលោកស្រីចុច *មីក្រូហ្វូន* ។ បើសិនលោកស្រីចង់បន្តទៀត សូមលោកឡើងនិយាយដោយចុច *មីក្រូហ្វូន* ។

**អ្នកបកប្រែ៖**

ជនត្រូវបាននិយាយថា "ខ្ញុំមិនបានឮទេ" ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ូស៖**

បើអ៊ីចឹង តើលោកស្រីចង់ថ្លែងបន្តទៀត ឬក៏លោកស្រីចង់បញ្ឈប់ត្រឹមនេះ?

**ជនត្រូវចោទ(ភាសាអង់គ្លេស)៖**

នេះគឺជាអ្វីដែលខ្ញុំចង់ប្រាប់ទៅលោកស្រី ពីព្រោះលោកស្រីមិនបានដឹងៗ ។ ខ្ញុំចង់ឲ្យអស់លោកទាំងអស់គ្នាហ្នឹង បានដឹងអំពីការពិត មិនចាំបាច់ឲ្យខ្ញុំចំណាយពេលវេលានោះទេ ។ ដោយគ្មានសម្រាប់អ្វីនោះ ។

ខ្ញុំទៅរៀនភាសាអង់គ្លេស ពីព្រោះនៅពេលហ្នឹងមិនមាននរណាគេចេះភាសាអង់គ្លេសទេ ។ អ៊ីចឹងខ្ញុំត្រូវរៀនភាសាអង់គ្លេស ហើយដើម្បីយកមកបង្រៀនភាសាអង់គ្លេសហ្នឹងដល់ប្រជាជនខ្មែរ ។ អ្វីដែលខ្ញុំបានធ្វើទាំងអស់ហ្នឹង គឺដើម្បីមាតុភូមិរបស់ខ្ញុំ ។

លោក លោកស្រី ត្រូវដឹងអំពីមនុស្ស ។ មនុស្សគ្រប់គ្នាអ្នកណានិយាយនេះ អ្នកនេះនិយាយអំពីនេះ អ្នកនេះនិយាយអំពីនោះ ។ អ៊ីចឹង គឺថាលោកស្រីត្រូវដឹងអំពីមនុស្សឲ្យបានច្បាស់លាស់ ។

**ចៅក្រម ខាទីនខា ឡាហ្វ៊ូស៖**

បើអ៊ីចឹង តើនេះគឺជាពាក្យចុងក្រោយនៃការថ្លែង នៅក្នុងបណ្តឹងឧទ្ធរណ៍របស់លោកស្រីឬ? ពីព្រោះខ្ញុំនឹងធ្វើការប្រកាសថា យើងនឹងផ្អាក ។

**ជនត្រូវចោទ(ភាសាអង់គ្លេស)៖**

តើនរណាគេជាឃាតករនោះ? ខ្ញុំចង់ដឹងដូច្នេះ ។ ខ្ញុំទើបតែត្រឡប់មកពីប្រទេសចិន នៅពេលនោះ ហើយនៅពេលនុ៎ងឯង ខ្ញុំបានទៅៗជួសជុល--

**អ្នកបកប្រែ(ប្រែពីខ្មែរមកភាសាអង់គ្លេស)៖**

*...to repair, sorry I forget the location that was bombarded by bombs.*

**ជនត្រូវចោទ៖**

លោកបកប្រែឲ្យខ្ញុំបណ្តោយទៅ ។

**អ្នកបកប្រែ៖**

*No, I think the interpreter can not hear because the microphone right before Ieng Thirith switched off.*

**ចៅក្រម ខាទីនខា ឡាហ្វ៊ែស៖**

លោកមេធាវី បើសិនជាកូនក្តីរបស់លោកចង់បន្តនិយាយទៀត ។ បាទសូមឲ្យគាត់ប្រើ *មីក្រូហ្វូន* ហើយលោកស្រីអាចនិយាយភាសាខ្មែរ ដូច្នេះនឹងអាចធ្វើការបកប្រែទៅជាភាសាដទៃទៀតបាន ។ ពីព្រោះខ្ញុំមើលទៅដូចជាមានបញ្ហា ដូចជាមិនដឹងច្បាស់លាស់ថា តើគាត់ចង់បញ្ចប់ ឬក៏គាត់ចង់បន្តទៀតទេ ។

**ជនត្រូវចោទ៖**

*[សំឡេងមិនចូលក្នុងឧបករណ៍សោតទស្សន៍]*

ហេតុផលដែលខ្ញុំខំមកនិយាយពេលនេះ ខ្ញុំទ្រាំអស់រាប់ឆ្នាំហើយ ។ ខ្ញុំឈឺចាប់ណាស់ យកឈ្មោះខ្ញុំទៅដាក់ក្នុងជួរអ្នកមានទោស អ្នកអី! ។ ខ្ញុំមិនដែលធ្វើទោសសោះ ខ្ញុំវេទនាមែនទែន ខ្ញុំខំប្រឹងជួយកូនចៅខ្ញុំ កូនសិស្សខ្ញុំ ។ ចង់ជម្រាបអ៊ីចឹង ហើយទៅស៊ើបមើល តើពិតឬមិនពិត? ខ្ញុំមិនដែលស្គាល់ កាំង ហ្កេកអ៊ាវ នៅណាទេ? ខ្ញុំមិនដែលស្គាល់ហ្នឹង ខ្ញុំខ្ពើម ខ្ញុំស្អប់ណាស់ ។ ហើយខ្ញុំក៏មិនដែលនិយាយរក កាំង ហ្កេកអ៊ាវ ដែរ តាំងពីដើមមក ។

ទើបតែចុងក្រោយទេ ដែល នួន ជា យកកូនសិស្សខ្ញុំ ទៅដាក់ឲ្យ កាំង ហ្កេកអ៊ាវ សម្លាប់ចោល ។ កូនសិស្សដែលកំពុងធ្វើការក្នុងរោងចក្រនោះ យកគ្នាទៅសម្លាប់ចោលអស់ហើយ គ្មានសល់អីទេ នៅសល់តែម្នាក់ទេ ភស្តុតាងនៅសល់ម្នាក់ទេ ។ ម្នាក់ៗដែលខ្ញុំឲ្យចាំការិយាល័យខ្ញុំនេះ ។ អ្នកដែលបានចេញទៅប្រតិបត្តិការខំរៀនសូត្រខាងរោងចក្រ អ្នកដែលទៅជួសជុលមន្ទីរពេទ្យចាប់អស់ហើយ ។ ហើយមិនមែនចាប់តែកូនសិស្សខ្ញុំទេ ចាប់ទាំងអ្នកជំនាញការដែលមកជួយកូនសិស្សខ្ញុំ ។

ដែលបងប្អូនខ្ញុំ អ្នកដឹកនាំនៅភ្នំពេញគេល្អនេះ គេបញ្ជូនមនុស្សគេអ្នកចេះឲ្យមកជួយណែនាំជាមួយនឹងចិនហ្នឹង ។ លោកដឹងហើយ រោងចក្របួនដែលពួកខ្ញុំបានជួសជុល លោកបានឃើញទេ នៅភ្នំពេញហ្នឹង ។ ហើយខ្ញុំទៅជួសជុលមន្ទីរពេទ្យម្នាក់ឯង ខ្ញុំទៅម្នាក់ឯងខ្ញុំជិះកង់ ។ គេឲ្យតែកង់មួយ រដ្ឋមន្ត្រី តែកង់តែមួយទេ ដើម្បីកុំឲ្យយើងធ្វើអីកើត ។

លោកមិនដឹងផ្ទៃក្នុងខ្មែរយ៉ាងម៉េច? លោកចេះតែចាប់ទទឹងទទែងអញ្ចឹង ឲ្យល្អទៅមានទោស ។ ឲ្យអាក្រក់ទៅអ្នកដែលគ្នាខំប្រឹងប្រែងចង់ងាប់នេះ ។ ខ្ញុំឈឺចាប់ណាស់ ខ្ញុំទ្រាំមិនបានទេ ខ្ញុំសូមទោស ។ ខ្ញុំនិយាយនេះ មិនមែនខ្ញុំមិនស្គាល់ច្បាប់ទម្លាប់ទេ ខ្ញុំរៀនបានច្រើនដែរ ។

ប៉ុន្តែ ខ្ញុំនិយាយនេះ ដើម្បីប្រទេសជាតិខ្ញុំ កុំឲ្យទៅចាប់ប្រសេចប្រសាចខុសមនុស្សទាំងអស់ហ្នឹង ហៅមកហ្នឹង ខ្ញុំមានធ្វើ-- ខ្ញុំដែលធ្វើអាក្រក់ពីអង្កាល់? ខ្ញុំជាឧក្រិដ្ឋករពីកាលណាបានហៅខ្ញុំមក? ឯឧក្រិដ្ឋករនោះយ៉ាងម៉េច?

ខ្ញុំមិនដែលនិយាយរកអាសម្លាប់គេទេ ។ ឈ្មោះអី? អាអ្នកដែលសម្លាប់គេរាល់ថ្ងៃហ្នឹងឈ្មោះអី? តាមបញ្ជា នួន ជា ឈ្មោះអីអាអន្ទិតនៅ--

ទាក់ទងជាមួយ កាំង ហ្គេកអ៊ាវ ពីកាលទេ? តាំងពីដើមមកខ្ញុំមិនទាក់ទងនឹង កាំង ហ្គេកអ៊ាវ ទេ ។ កាំង ហ្គេកអ៊ាវ ហើយនិង នួន ជា គឺតែមួយ ។ កាំង ហ្គេកអ៊ាវ ធ្វើតាមបញ្ជា នួន ជា ទាំងអស់ ។ ការកាប់សម្លាប់ហ្នឹង គឺតាមបញ្ជា នួន ជា ទាំងអស់ ។ ខ្ញុំត្រូវនិយាយអ៊ីចឹង ខ្ចិលណាស់ ។

ខ្ញុំសូមជម្រាបថា ដោយសារខ្ញុំមិនមែនជាអ្នកច្បាប់ទម្លាប់អីទេ ប៉ុន្តែខ្ញុំស្រឡាញ់ការពិត ឮសួរនិយាយអ៊ីចេះ ខ្ញុំធុញទ្រាន់ណាស់ ។ ដូច្នេះ ខ្ញុំសូមជម្រាបការពិតដល់អស់លោក ព្រោះខ្ញុំគោរពស្រឡាញ់អស់លោក ចង់ឲ្យលោកកាត់សេចក្តីឲ្យត្រឹមត្រូវ ។

ខ្ញុំមិនមែនចង់អីណាផ្តន្ទាទោសអ្នកណាទេ ។ ស្រេចតែអស់លោកគិតមើលទៅ ហើយមកប៉ះលើខ្ញុំ ។ ខ្ញុំទើបមកម៉ើកៗហ្នឹង-- គឺខំប្រឹងចង់ងាប់ ។ កង់មួយម្ទេតៗ រាល់ថ្ងៃហ្នឹង ។ ហើយចាប់លើកខ្ញុំទៅខ្ញុំជាមេអីណា? ឃាតករអីណា? ខ្ញុំមិនដែលសម្លាប់នរណាខ្ញុំ ។

អាហ្នឹងខ្ញុំសូមជម្រាបច្បាស់ ជាពិសេសលោកពូន៎ែ! គួរតែស្គាល់ខ្ញុំហើយ ។ ស្គាល់ឪពុកខ្ញុំហើយ លោកតាខ្ញុំហើយ សុទ្ធតែកាន់ខាងក្តីទាំងអស់ ។ កូនអ្នកមានពូជទាំងអស់ ។ លោកតាខ្ញុំ លោកតាអ៊ុក ចាងហ្វាងសាលាក្តីនៅភ្នំពេញហ្នឹង ។ ឪពុកខ្ញុំចាងហ្វាងសាលាក្តីនៅបាត់ដំបង ។

ដូច្នេះ ខ្ញុំចង់ជម្រាបពូជពង្សខ្ញុំឲ្យច្បាស់លាស់ ។ ខ្ញុំមិនមែនអន្សុតិរ្ថិយពីណាមក! មកសម្លាប់គេលេងៗអ៊ីចឹងទេ ។ ខ្ញុំមានហេតុផលអីសម្លាប់ ។ ហេតុអ្វីបានខ្ញុំខំយកកូនសិស្សមកបង្រៀន? ហើយយកគ្នាមកដល់ដាក់ឡានចិនបន្តឹមហាជនឲ្យច្រឡំ ដាក់សុទ្ធតែឡានចិនក្រុងរលោងស្រិលយកគ្នាទៅដាក់គុក

កាំង ហ្កេកអ៊ាវ ឯណោះ ។ ខ្ញុំសូមជម្រាបឲ្យច្បាស់ ដែលអស់លោកមិនទាន់ដឹង ខ្ញុំជម្រាបឲ្យច្បាស់ ។

ទោះបី ជាជនជាតិខ្មែរក៏ដោយ ។ បើខ្មែរតិរច្ឆាន១ យើងត្រូវតែថាវាតិរច្ឆានអ៊ីចឹងទៅ ។ ហើយយកគេអ្នកល្អ មកថាតិរច្ឆាន ធ្វើម៉េចគេសុខចិត្ត? សុំឲ្យច្បាស់ទៅខ្ញុំធ្វើអ្វីខ្លះ? ខ្ញុំមិនដែលស្គាល់ទេណា! គុក កាំង ហ្កេកអ៊ាវ ខ្ញុំដែលអត់ដែលស្គាល់ទេ ។ ខ្ញុំស្អប់ខ្ពើមណាស់ តែខ្ញុំមិនដឹងធ្វើម៉េច? ខ្ញុំមានសិទ្ធិអីទៅប្រឆាំងនឹងគេអ្នកដឹកនាំនោះ ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង ខ្ញុំអស់ហើយ ។

សូមអរគុណ ។

[១២:១០:០៦]

**ចៅក្រម ខាទីនខា ឡាហ្វ៊ូស៖**

បន្ទាប់មកទៀត គឺខាងអង្គបុរេជំនុំជម្រះនឹងធ្វើការប្រកាសថា ពេលនេះសវនាការសាធារណៈហ្នឹង បានបញ្ចប់ហើយ ហើយយើងនឹងបន្តសវនាការអសាធារណៈ ។ យើងធ្វើការកត់សម្គាល់ផងដែរថា អង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់ឃើញថា ប្រហែលជានៅសល់ម៉ោងដប់នាទីទៀតសម្រាប់អាចធ្វើការឆ្លើយតបរបស់ខាងមេធាវីការពារក្តី ។

ដូច្នេះឥឡូវហ្នឹង តើយើងគួរតែបន្តនៅពេលនេះ ឬសម្រាករយៈដប់នាទីទៀត ឬមួយក៏យើងត្រូវរៀបចំសម្រាប់រយៈពេល-- នៅពេលក្រោយទៀត នៅពេលរសៀល? ឬមួយក៏យើងនឹងបើកធ្វើសវនាការបន្តទៀត បន្ទាប់ពីសម្រាកពិសារអាហារថ្ងៃត្រង់រួច?

សំណើហ្នឹងគឺថា យើងធ្វើការសម្រាកបន្តិចរយៈពេលខ្លី ហើយយើងបន្តទៀតបន្ទាប់ពីដប់នាទី ។ ពីព្រោះខាងមេធាវីការពារក្តីជាភាគីដែលត្រូវនឹងឡើងនិយាយ ។ អ៊ីចឹងគ្រប់គ្នាងក់ក្បាលឯកភាពទេ បើសិនជាអ៊ីចឹងខ្ញុំគិតថាទាំងអស់បានឯកភាពហើយ ។ អ៊ីចឹងអង្គសវនាការនឹងបន្តទៀតក្នុងរយៈពេលដប់នាទី បើជាសាលសវនាការអសាធារណៈ មានន័យថា សាធារណជនអាចនឹងធ្វើការចាកចេញពីបន្ទប់ស្តាប់បាន ពីព្រោះយើងនឹងមិនធ្វើការផ្សាយជាសាធារណៈនោះទេ ។

**ប្រធានអង្គបុរេ៖**

អ៊ីចឹងយើងសូមអញ្ជើញសម្រាក ។

**លោក ជួន សុរាសី៖**

សូមអញ្ជើញក្រោកឈរ!

[អង្គសវនាការសម្រាកចាប់ពីម៉ោង ១២:១១នាទី រហូតដល់ ១២:៣១ នាទី]

[សវនាការជាអសាធារណៈនៅម៉ោង១២:៣១នាទីដល់ម៉ោង១២:៤៩នាទី
(ចាប់ពីទំព័រ៦០ដល់ទំព័រ៦៥ត្រូវបានដកចេញ)]